ឧបករណ៍សម្រាប់ព្យាបាល



បណ្ណាល័យវិទ្យាសាស្ត្រ ឃុន សុវណ្ណ នៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ
ក្នុង Library of Cambodia ឆ្នាំ ២០១៥

ព្យាករណ៍សាស្ត្រ

ឆ្លួន ~ ឃ្លុត

ប្រមូលចងក្រង



ចោះពុម្ពលើកទី ៨

មានបន្ថែមគម្រោងច្រើនទៀត

១៩៩៩

អារម្ភកថា

✧ ✧ ✧

មូលហេតុដែលនាំអោយខ្ញុំរៈរកក្បួនតម្រាបុរាណផ្សេងៗ មកប្រៀបធៀងចោះពុម្ពនេះ ដោយខ្ញុំឃើញថានៅប្រទេសកម្ពុជាយើងក្នុងសម័យបច្ចុប្បន្ននេះ ខ្សត់ខ្សោយក្បួនតម្រាពេកណាស់ ដែលជាក្បួនសម្រាប់មើល សំរាប់ទាយលក្ខណៈរបស់មនុស្ស ។

តម្រាទាំងនេះ ឃើញនៅមានតែដោយស្តីកវីត ក្រាំង ឬ ស្បៃវែកចាស់ៗបចរិល រដាច់រដោចស្ទើរមើលពុំកើត ទើបខ្ញុំខំព្យាយាមប្រមូលក្បួនតម្រាបុរាណទាំងនោះ យកមកប្រៀបធៀងចោះពុម្ពផ្សាយ ដើម្បីអោយងាយដល់ណាក-អ្នកដែលត្រូវការមើលផង និងដើម្បីរក្សាក្បួនតម្រាបុរាណនេះទុក កុំអោយវិនាសចាត់បង់ទៅផង ។

ខ្ញុំកំនត់តម្រានេះ អោយឈ្មោះថា : ព្យាករណ៍សាស្ត្រ (ប្រែថា) " ក្បួន ឬ តម្រា សំរាប់ទាយនូវហេតុភេទផ្សេងៗ " ។

ព្យាករណ៍សាស្ត្រនេះ ជាតម្រាមួយយ៉ាងវិសេស សំរាប់ពិសោធមើលលក្ខណៈ និងហេតុភេទផ្សេងៗរបស់មនុស្ស ព្រោះថាមនុស្សជាតិនីមួយៗទោះប្រុសក្តី ស្រីក្តី ដែលកើតមកហើយសុទ្ធតែមានលក្ខណៈ គឺជាគំនូសជាគ្រឿងសំគាល់ផ្សេងៗពីគ្នា អាចអោយអ្នកហោរាសាស្ត្រ គេសង្កេតដឹងបានថាមនុស្ស ល្អ ឬអាក្រក់, មានបុណ្យ ឬ ឥតបុណ្យ ជាដើម ។

ហេតុនេះអស់លោក-អ្នក គួរតែមានព្យាករណ៍សាស្ត្រ នេះទុកនៅប្រចាំខ្លួន ឬ ប្រចាំផ្ទះគ្រាន់នឹងបានពិសោធមើលលក្ខណៈ និងហេតុហេតុរបស់ខ្លួនដែលកើតឡើង ពុំនោះ-សោតលោក-អ្នកទុកដូចជាមានគ្រូ ឬ ហោរាម្នាក់យ៉ាងជំនាញនៅប្រចាំការ សម្រាប់ទាយជូនអស់លោក-អ្នកជានិច្ច ។

ភ្នំពេញ នៅថ្ងៃពុធ ខែវិសាខ ឆ្នាំច ចត្វាសក៌ ស្រួនិងថ្ងៃទី ជ្រាំពីរ ខែ ឧសភា ឆ្នាំមួយពាន់ជ្រាំបួនរយហាសិបពីរ ។

ឆួន ប៊ុត

ម្ចាស់បណ្ណាគារ ប៊ុត ឆាង

បញ្ជីរឿង

មាតិការឿង	ទំព័រ
១- លក្ខណៈសុបិន្តនិមិត្ត	1
២- សុបិន្តព្យាករណ៍ចាប់៤១យ៉ាង	4
៣- សុបិន្តនិមិត្តបែកខាងល្អ ៧៣ យ៉ាង	11
៤- សុបិន្តនិមិត្តបែកអាក្រក់ ៣០ យ៉ាង	17
៥- សុបិន្តនិមិត្តបែកបុរាណ ៥៥ យ៉ាង	20
៦- តម្រាមើលលក្ខណៈនៃរាងកាយ	27
៧- លក្ខណៈចាតដៃ ៨ យ៉ាង	27
៨- លក្ខណៈអក្សាញដៃ ២៤ យ៉ាង	30
៩- កំណត់ឋានគ្រឿងសំគាល់នៃអក្សាញដៃ ៩ យ៉ាង	33
១០-អធិប្បាយលក្ខណៈនៃចាតដៃ ៩ យ៉ាង	34
១១- លក្ខណៈឋានទី ១	35
១២- លក្ខណៈឋានទី ២	36
១៣- លក្ខណៈឋានទី ៣	36
១៤- លក្ខណៈឋានទី ៤	37
១៥- លក្ខណៈឋានទី ៥	37
១៦- លក្ខណៈឋានទី ៦	37

១៧- លក្ខណៈបំានទី ៧ 38

១៨- លក្ខណៈបំានទី ៨ 38

១៩- លក្ខណៈបំានទី ៩ (កណ្តាលបាតដៃ) 39

២០-លក្ខណៈមើលសុខ-ទុក្ខ 40

២១- លក្ខណៈមើលមនុស្សគ្រុន 40

២២-លក្ខណៈម្រាមដៃ 41

២៣-អធិប្បាយលក្ខណៈម្រាមទាំងត្រាំតាមលំដាប់ 44

២៤- មើលលក្ខណៈគូថខ្មៅ 46

២៥- មើលលក្ខណៈក្រចក 47

២៦-លក្ខណៈប្រជ្រុយរបស់ប្រុស១៨ចំាង 48

២៧-លក្ខណៈប្រជ្រុយរបស់ស្រី១៥យ៉ាង 51

២៨-ក្បួនសង្កត្រោះ 54

២៩-ក្បួនអង្គត្រោះ 55

៣០-ក្បួនធព្យត្រោះ 57

៣១-សម្តែកនាមសត្វនៃឆ្នាំទាំង១២ 58

៣២-ពាក្យសម្តែក (ទាយពីដំណើរមនុស្ស) 58

៣៣-ស្តាប់សូរក្អែកបូល 62

៣៤- ស្តាប់សូរអុកឡែ 63

៣៥- ស្តាប់សូរកណ្តុរយំ 65

៣៦- មើលកណ្តុរកាត់សំពត់ 67

៣៧- បេក្ខណៈនៃសត្វដែលវារកាត់ 69

៣៨- មើលលក្ខណៈពីងពាងគោះទ្រូង 71

៣៩- មើលពាក់ស្លាក-ដៃ-ច្រមុះ-ត្រចៀក ។ល។ 73

៤០- ទំនាយសត្វធ្លាក់ 75

៤១- សត្វជីងចក់ ឬ តុកកែធ្លាក់ 77

៤២- មើលលក្ខណៈសត្វធ្លាក់ 78

៤៣- ទំនាយមនុស្សភ្លាត់មាត់ និងជីងចក់ធ្លាក់ក្នុងទីជាឱកាស 83

៤៤- ពិធីមើលលក្ខណៈសត្វទុំផ្ទះ 84

៤៥- តម្រាមើលជីពចរល្អ-អាក្រក់ 85

៤៦- តម្រាមើលថ្ងៃកាត់សក់ 88

៤៧- តម្រាមើលថ្ងៃកាត់សក់ (កាព្យពាក្យ៧) 89

៤៨- តម្រាមើលថ្ងៃអ៊ុតសក់ 89

៤៩- តម្រាមើលថ្ងៃកាត់ក្រចក (កាព្យពាក្យ៧) 90

៥០- តម្រាមើលថ្ងៃកាត់ក្រចក (បទភាគតិ) 90

៥១- ដង្ហើមរស់ប្រចាំទិស 91

៥២- ដង្ហើមស្លាប់ប្រចាំទិស 91

៥៣- ថ្ងៃអធ្យាប្រចាំឆ្នាំកំណើត 91

៥៤- ថ្ងៃអណ្តែត-លិច-កណ្តាល 92

៥៥- ពណ៌សំពត់ស្លៀកតម្រូវតាមថ្ងៃ 93

៥៦- កំលាំងថ្ងៃ 94

៥៧- ជោគល្អ-អាក្រក់ស្លៀកសំពត់ថ្មី 94

៥៨- អោយរបស់ផ្សេងៗទៅអ្នកដទៃ 95

៥៩- មើលសីរីរាសីនៅប្រចាំថ្ងៃ 95

៦០-មើលរាសីប្រចាំកាយ 96

៦១- គប្បីបតិបត្តិដើម្បីឱ្យមានសីរី 97

៦២-មើលជួលចាវប្រើប្រាស់ 98

៦៣-តម្រាធ្វើស្រែ 99

៦៤- ផែនទីដាំដើមឈើប្រចាំទិស 101

៦៥- គំរូផែនទី (មើលស្លៀកពាក់,ឱ្យរបស់,ដាំដើមឈើ,រាសីប្រចាំកាយ
ឈោះចាវប្រើ,ទទួលប្រាក់មាស,បំបួសនាគ 103

៦៦- គំរូផែនទី (មើលកាតសក់,ស្តប្រែង,កាត់ក្រចក,ដេរសំពត់,
កណ្តុរកាត់សំពត់,សង់ផ្ទះ 104

៦៧-តម្រាសង់គ្រឹះស្ថាន 105

៦៨- ពិធីរាប់អាយុមនុស្ស 108

៦៩- ទំនាយតម្រាចាក់ផ្សង 109

ពាក្យសម្ដែក

-ជើនទេញ

-ធ្មេញល្អិត

-ស្លឹកត្រចៀកក្រពុិត

-អំណើរប៉ែលចៅល

ទាយថា :មនុស្សណាបើប្រកបព្រមដោយលក្ខណៈទាំង៤យ៉ាងនេះ ឈោកថាអ្នកនោះឯងច្រើនមានពុតរបិញរបួញ និយាយការអ្វីច្រើនពុំសូវទៀង ។

ពាក្យសម្តែង

-ជម្ពូរសិង្ហ

-សម្តីងខ្ចា

-សំលេងស្អា

-ភ្នែកមាន់ព្រៃ

ទាយថា : មនុស្សណាបើប្រកបព្រមដោយលក្ខណៈខ្ញុំទាំង៤

យ៉ាងនេះលោកថា : " អ្នកនោះឯង នឹងមានបុណ្យ

មានសំណាង មានវាសនា ចិត្តមុត " ។

សុបិន្តព្យាករណ៍

លក្ខណៈសុបិន្តនិមិត្ត

គ្រានេះនឹងសំដែងក្នុងលក្ខណៈសុបិន្តនិមិត្តជាមុន ដែលមានក្នុងគម្ពីរសារត្ថ សង្គហ ថា បុគ្គលណានិមួយ ដែលនឹងយល់សប្តិឃើញ រមែងប្រកបដោយលក្ខណៈ ៤ប្រការ គឺ : ធាតុក្ខោភៈ ១, អនុភូតបុព្វ១, ទេវតូបសំហរៈ១, បុព្វនិមិត្ត ១ ។

១. ឯការយល់សប្តិឃើញ ដោយអំណាចធាតុណានីមួយក្នុងខ្លួន កម្រើកធ្វើកាយ និងចិត្តមិនអោយស្ងប់ជាប្រក្រតី លុះដេកលក់ទៅ ក៏បណ្តាលឱ្យយល់សប្តិឃើញ វិបរិត ផ្សេងៗ គឺអោយឃើញធ្លាកដហាក់ដូចជាធ្លាក់ពីលើភ្នំ ពីលើដើមឈើ ពុំនោះធ្លាកដ ហាក់ដូច ជាគេចាប់ខ្លួនចោះទៅលើអាកាស, ពុំនោះសោតឃើញពាលម្រឹគមានដំរី ខ្លា ឬចោរជាដើម មកដេញតំរាមអោយតក់ស្លុត ភិតភ័យ អំពាលនេះចាត់ជាលក្ខណៈនៃធាតុក្ខោភៈ ។

២.កាលពីមុំលាមុន ខ្លួនធ្លាប់បានសោយអារម្មណ៍យ៉ាងណាមួយរបស់ខ្លួន រមែង ប្រព្រឹត្តទៅញយៗក្នុងអារម្មណ៍នោះ, ដូចយ៉ាងពីថ្ងៃខ្លួនបានធ្វើការអ្វីមួយ លុះដល់ដេកលក់ ទៅ ក៏យល់សប្តិឃើញការនោះ នេះចាត់ជាលក្ខណៈនៃអនុភូតបុព្វ ។

៣.ការយល់សប្តិដោយអំណាចទេវតា មកបណ្តាលឱ្យចូលចិត្តជាការល្អក្តី អាក្រក់ ក្តី, នេះចាត់ជាលក្ខណៈនៃទេវតូបសំហរៈ ។

៤.ការយល់សប្តិឃើញដោយអំណាចកុសល ឬអកុសលចិត្ត បណ្តាលឱ្យឃើញ ជានិមិត្តល្អ ឬ អាក្រក់ទៅតាមហេតុ ដូចយ៉ាងព្រះសុបិននិមិត្ត នៃព្រះនាង សិរិមហា

មាយា ក្នុងការទ្រង់ព្រះគភ៌ ឬ ព្រះសុបិន្តនិមិត្តនៃព្រះមហាបុរស ក្នុងកាលព្រះទ្រង់ ដែលនឹងបានត្រាស់សម្មាសម្ពោធិញ្ញាណ នោះដើម្បីអោយដឹងហេតុ ដែលនឹងមានមកក្នុងកាលខាងមុខថាដូចម្តេច, នេះចាត់ទុកជាលក្ខណៈនៃ បុព្វនិមិត្ត ។

ការយល់សប្តិឃើញដោយអំណាចធាតុក្តោក : (ធាតុកំរើក និងដោយអនុភូតបុព្វ : ដែលផ្តាច់សោយអារម្មណ៍មកពីជាតិមុននោះ) មិនបានជាការទៀងទាត់ទេ ទោះយល់សប្តិឃើញថាល្អ ក៏មិនបានល្អ, ទោះយល់សប្តិថា អាក្រក់ ក៏មិនបានអាក្រក់ ។

ការយល់សប្តិឃើញដោយអំណាច ទេវតូបសំហរៈ (ដែលបណ្តាលមក) នោះពិតក៏មាន មិនពិតក៏មាន គឺជួនកាលទេវតាគាប់ចិត្តអ្នកនោះក្រាថ្នានឹងឱ្យប្រយោជន៍ ក៏បណ្តាលអោយយល់សប្តិឃើញពិតតាមហេតុទៅ ជួនកាលទេវតាក្រោធក្រាថ្នានឹងអោយវិនាសអន្តរាយ ដោយឧបាយណាមួយផង់ខ្លួន ក៏មកបណ្តាលអោយយល់សុបិន្តក៏មាន ។ ឯការយល់សប្តិ ដោយអំណាចកុសល ឬ អកុសល ដែលធ្វើអំពីកាលពីមុនៗមក គឺសុទ្ធតែទៀង សុទ្ធតែពិតទាំងអស់ ។

ក្នុងគម្ពីរសារត្ថសង្គហៈថា បុគ្គលដែលយល់សប្តិឃើញ មិនមែនឃើញក្នុងវេលាលក់ស្កប់ស្កល់នោះទេ ឃើញក្នុងវេលានិទ្រាគ្របសង្កត់ សឹងមានអាការដូចជាការងេកលក់នៃពានរ គឺលក់ស្តាក់ស្តើរ ចិត្តនោះភ្ញាក់ពីភវង្គៈហើយ ។

ភាលទស្សនាបិ ឧស្សិនោ ន សមេតិ ម្យ៉ាងទៀត លោកថា យល់សប្តិក្នុងវេលាងេកថ្ងៃ ឬ ក្នុងបឋមយាម និង មជ្ឈិមយាម នៃរាត្រីពុំសូវទៀង បើយល់សប្តិក្នុងបច្ឆិមទៀបនឹងភ្លឺនោះ ច្រើនទៀងរុតទោះ យល់សប្តិល្អ ក៏នឹងបានទទួលផលល្អ, យល់សប្តិ អាក្រក់ ក៏នឹងបានទទួលផលអាក្រក់ ពិតប្រាកដមែន ។

នัយមួយទៀតថា

យល់សប្តិថ្ងៃអាទិត្យ = ផលល្អ ឬ អាក្រក់រមែងបានដល់ស្តេច ឬ ចៅហ្វាយនាយ ។

យល់សប្តិថ្ងៃចន្ទ = បានដល់បង ឬ ប្អូន ។

យល់សប្តិថ្ងៃអង្គារ = បានដល់មាតាបិតាបង្កើត ឬក្មេក ។

យល់សប្តិថ្ងៃពុធ = បានដល់កូន ឬ ក្មួយ ឬ ចៅឯណាមួយ ។

យល់សប្តិថ្ងៃព្រហ. = បានដល់គ្រូចាស្យាយ ។

យល់សប្តិថ្ងៃសុក្រ = បានដល់សត្វចិញ្ចឹម ។

យល់សប្តិថ្ងៃសៅរ៍ = បានដល់ខ្លួនឯង ។

ការដែលកំណត់ថ្ងៃដូច្នេះ នរជនគប្បីដឹងថា " មានទៀងជាច្រើន ប៉ុន្តែ មិនមែនសុទ្ធតែទៀងទាំងអស់នោះទេ " ។

រឿងយល់សប្តិ ដែលនឹងពិណិនាទៅនេះ បុរាណាចារ្យលោកបានសង្កេតមក ឃើញពិតជាច្រើន ទើបលោកប្រមូលចងជាចាប់គាថា ហៅថា " សុបិនព្យាករណ៍ចាប់ " សំរាប់អោយអ្នកចេះពាលីស្វាធ្យាយ ងាយចាំក៏មាន, ប្រមូលជាសម្រាយហៅថា: « ទំនាយសុបិននិមិត្ត » ក៏មាន, ដូចមានរោលតទៅខាងមុខនេះ ÷

សុបិន្តព្យាករណ៍ចាប៧៤១យ៉ាង

ទេវិន្ទព្រហ្មារ ទិការចន្ទោ, ជាសាធនាថោ, មណិ, រាជរាជី, មញ្ជាសនេ, សក្កបនត្តរច្ឆី តាលាធិ, តិរី តីណាសច្ឆីសន្ទោ ។ ពុទ្ធាធិរូបេ ចេតិយេ, ទិហារេ, ចក្កាតុធា រោ, ធរណិញ្ច ខាធិ, តថិន្ទហាយស្សរថស្សតាតី, នាកិន្ទបកក្ខ័, ខុសកញ្ច សីហោ ។ ខ័ន្ទធិទាមចុថាណិកាធរយោ, រមយោ, សុភ័រជោ ,ថនមំសកុញ្ជិ, សេតាករណាទក្ត, សុឆត្តរូធី, ធជា, សុទណ្ឌី, បទុមាធិត តន្ធោនធិញ្ច នាទំ តរត្តំ សមុន្ទោ, កុមារណារកោ, បធិជា ,ទិមានំ, សសា ច កុម្ភី មយុរី ច សិប្បំ, កុម្ភិញ្ច បច្ចំ, កិមិ គុថ ជុដ្ឋា ។ នកច្ច័មានេ គរុទេណិ កញ្ញា អលច្ច័រោន្ធា សុមនញ្ច មាល្យម ,បទុមបត្តេ សុថលេ ចកុម្ភី មយុរិ ចសិប្បរុក្ខំ, រត្តចន្ទសារ ។ ឥសាកិរម្ចេន នគរេ សុបិនា, សុទណ្ឌហច័្ច កិន្នរី អរញ្ញំ, បកិរណាន្ត សីសច្ចេទហាត្តំ, សុធោទនា សច្ច័លិកាធិតន្ធា ។ សុសា ប ទន្ត ពហុរលេកិលាកោ, ធនានិ សុខា គុលាតុដ្ឋិ តេថ ឥរាយ និព្ភយា អរោគំ, បសិទ្ធិ កាម្ចំ បត្តនញ្ច តុដ្ឋិ ។

សេចក្តីអធិប្បាយ

១- ឧទិន្នព្រហ្មា យល់សប្តិឃើញព្រះឥន្ទ្រ ព្រះព្រហ្ម នូវទេវតាទាំងឡាយ ទំនាយថាជាមង្គលសុបិន្តដ៏ប្រសើរ អ្នកនោះនឹងបានសុខក្រៃពេក បានទ្រព្យលាភ នឹងបានជាធំជ្រាកជ ។

២-វេទីកាចន្ទា យល់សប្តិឃើញបានចាប់ កាន់ ឬ បានឈប ព្រះអាទិត្យ, ព្រះចន្ទ្រ នឹងផ្តាយ អ្នកនោះនឹងមានតេជានុភាពដ៏ច្រើនលើសលែង ទោះបីមនុស្សកំសត់ ក៏គង់បានជាធំលើផែនដី, បើស្ត្រីនឹងបានជាអគ្គមហេសីស្តេច ដូចនាងបញ្ចាជាធីតា អ្នកទុគ៌ត ក៏បានជាអគ្គមហេសីស្តេច ដល់ទៅពីរនគរួមគ្នា ហើយមានអំណាចឈ្នះអស់មារសត្រូវទាំងពួង ។

៣-ជាសាធនាវេថា យល់សប្តិឃើញ បានឡើងលើប្រាសាទ នឹងបានជាចៅ-ហ្វាយស្រុក ជាទីស្រឡាញ់ពេញចិត្តនៃអ្នកទាំងពួង ។ ន័យមួយទៀត ថាបើអ្នកមាន បណ្តាសក្តិ នឹងអោយលាភ ។ បើសប្តិថា បានទីពុំនាក់យ៉ាងណានិមួយ អ្នកនោះនឹង បានសុខបិតថែរ ចិរកាលតទៅ ។

៤-មណិយល់សប្តិបានកែវ នឹងបានបុណ្យដូចយ៉ាងស្តេចចន្ទរាជ កាលនៅ ជាពាណិជ្ជ ។ យល់សប្តិឃើញតាបសយកកែវមួយមកអោយដល់ដៃ ជំលោក្រោយមក ក៏បានជាស្តេច ។ ន័យមួយទៀតថា នឹងមានបុត្រដ៏មានបុណ្យ មានវាសនាច្រើន ។

៥- រាជវាជី យល់សុប្តិឃើញប្រទះព្រះមហាក្សត្យ និង ព្រះអគ្គមហេសី ទំនាយ នេះល្អណាស់ទុកដូចជាបានឃើញទេវតាដែរ ព្រោះក្សត្រលោកទុកដូចជាទេវតា ។

៦- ឃញ្ញាសរេន យល់សប្តិបានឡើងលើ អាសនៈ មានគ្រែជាដើម អ្នកនោះ នឹងបានសេចក្តីសុខច្រើន ។

៧-សក្កបនក្ករេន្ទ្រី យល់សប្តិបានឡើងលើបាននស្ទគិ និងបានឡើងសក្តិពីតូចទៅធំ ។ ន័យមួយទៀតថា យល់សប្តិបានឡើងលើភ្នំ នឹងបានយសធំ ។ យល់សុប្តិថាមានរស្មីចេញពីខ្លួន នឹងមានតេជានុភាពផ្សាយទៅក្នុងទីទាំងពួង ។

៨- តាលាធិ កេរិឥណសន្ថសន្ថោ យល់សប្តិបានឮសូរសព្ទតូរ្យតន្ត្រី ឬ បានឮសំលេងរគាំង គង, ស្គរ, ពិណ, សង្ខ ជាដើម នឹងបានជាធំជាងជនដ៏ទៃទាំងពួង និងមានកិត្តិគុណខ្ចរខ្ចាយក្នុងទីទាំងពួង ។

៩- ពុទ្ធាធិរូបរេចគិរេយ យល់សប្តិថាបានបូជាព្រះចេតីយ ឬ ព្រះពុទ្ធរូប ជាដើម នឹងបានលាភជាមង្គលដ៏ប្រសើរ ហើយនឹងមានតេជៈតេជៈ ។

១០-ឥរេហារេរា យល់សប្តិថា បានចូលទៅក្នុងព្រះវិហារ នឹងបានទីពឹងពុំនាក់ នៅជាសុខហោង។

១១- ចក្កាតុធា រេថា យល់សប្តិថា បានឃើញ បានចាប់ បានកាន់អាវុធ មានចក្រជាដើម ទោះនឹងពិតឧបាយច្រាជូយ៉ាងណាៗ នឹងនឹងបានសម្រេចតាមប្រាថ្នា យ៉ាងនោះ គ្រប់ប្រការ ព្រោះបញ្ញាលោកប្រៀបដូចជាអាវុធ ។

១២- ធរណិញ្ច ខាធិ យល់សុបិន្តថាបានស៊ីផែនដី នឹងបានជាធំ មានអំណាចផ្សាយទៅលើផែនដី ។

១៣- កឌិន្ទហាយស្សរេថស្សគាឌី យល់សប្តិថាបានជិះដំរី បានជិះសេះ ឬ

រថ នឹងមានជាសេនាអាមាត្យ ។ បើយល់សប្តិថា បានជិះមេគោ ទេវតានឹងរក្សាឱ្យសុខ

១៤- នាគនូបភក៍ យល់សប្តិថាបានឃើញនាគមកពាំនូវខ្លួន នឹងបានធារីដ៏មានបណ្តាសក្តិមកជាភរិយា ។ យល់សប្តិថា បានបក្សី មានសារិកាជាដើម ទំនាយថា នឹងមានស្រីស្រលាញ់ ។

១៥- ឧសភញ្ច សីហោ- យល់សប្តិថាបានឃើញបាន ជិះគោឧសភរាជក្តី ឬរាជសីហ៍ក្តី អ្នកនោះបើជាអ្នកកំសត់ នឹងបានជាមន្ត្រី បើជាមន្ត្រី នឹងបានជាសេនាបតី ឬ ចៅហ្វាយស្រុក ខេត្តឯណាមួយពុំលែងឡើយ ។

១៦- ខិរន្នធីនា មធុ ផាណិតាឧយោ យល់សប្តិថា បានបរិភោគទឹកដោះ ទធិ ទឹកឃ្មុំ ឬ ទឹកអំពៅឯណានិមួយ នឹងបានសេះស្បើយរោគក្នុងខ្លួន ។

១៧- រមយា យល់សប្តិថាបានលេបមេឃ នឹងបានជាធំ នឹងឈ្នះអស់មារសត្រូវ នឹងញាំញីអស់ពួកនិគ្រន្ថតិរ្ថីយ៍ទាំងពួង អោយចាលចាញ់ ហើយនឹងបានទំនុកបំរុងព្រះពុទ្ធសាសនាអោយបានរុងរឿងតទៅ ។

១៨-សុរាមេរ យល់សប្តិថាបានផឹកសុរា និង សេជាអស់រោគទាំងពួងក្នុងខ្លួន

១៩- ឯនមំសភុញ្ជិ យល់សប្តិថាបានបរិភោគសាច់មនុស្ស នឹងបានជាចៅ-ហ្វាយស្រុកខេត្ត។

២០- សេតាករណាទក្ខ យល់សប្តិថា បានស្លៀកពាក់ស និងប្រដាប់ដោយគ្រឿងអម្ពរ ស និង មានបុណ្យនៅជាសុខអស់កាលជាយូរអង្វែង។

២១-សុធក្ករូធិ យល់សប្តិថា ចាំងរស្មី និងបានជាអ្នកមានគេជួយឧបត្ថម្ភហើយ

នឹងបានជាធំ ។

๒๒-ឆដ្ឋា យល់សប្តិថាបានឃើញបានកាន់ទង់ជ័យ នឹងបានជាអ្នកមានអំណាច ឈ្នះអស់សត្រូវ ហើយចាប់បានឈ្លើយជាច្រើន ។

๒๓-សុឧណ្ហី យល់សប្តិថាបានឃើញមាស បានច្រាក់ ទំនាយថា នឹងបាន បុត្រាបុត្រី ដ៏ជាទីគាប់ចិត្ត ។

๒๔-បទុមាធិគន្ធោ យល់សប្តិថា បានគ្រឿងក្រអូប មានផ្កាឈូក ជាដើម នឹងបានជួបជុំបងប្អូន ឬញាតិ ដែលនៅឆ្ងាយដោយគេនឹងមករក ។

๒๕-នទិញ្ច នាវំ តរន្តំ សមុទ្ទោ យល់សប្តិថាបាន ជិះទូក ជិះសំពៅឆ្លង ទន្លេ ឬ ឆ្លងសមុទ្រទៅដល់ត្រើយ ទោះនឹងធ្វើការអ្វី នឹងបានសំរេចដូចប្រាថ្នាគ្រប់ប្រការ

๒๖-កុមារលាភោ យល់សប្តិថា បានកុមារ និងបានទាសា ទាសី ពុំនោះសោត នឹងបានមាសច្រាក់ ។

๒๗-បទិជ្ជា យល់សប្តិថា បានឃើញ រឺបានកាន់ប្រទីប នឹងបានមិត្តសំឡាញ់ ជា អ្នកប្រាជ្ញ មកបំភ្លឺអោយបានល្អ ។

๒๘-ទិវានំ យល់សប្តិថា បានឡើងទៅលើវិមាន នឹងបានជាចាវ៉ាយស្រុក ឬ ខេត្តឯណានិមួយ។ ។

๒๙-សសាធ កុម្ភី អាយុ បយុរី ច សិប្បំ យល់សប្តិថា បានឃើញ ឬ បានចាប់ទន្សាយ, ក្រពើ, ក្អែក និងពស់ណាមួយ នឹងបានភរិយានូវទាសាទាសី ហើយ នឹងឈ្នះអស់មារ សត្រូវទាំងពួង ។

៣០-កុម្ភិញ្ញ មច្ឆំ យល់សប្តិថា បានអណ្តើក កន្ធាយ ឬត្រី នឹងបានមាសប្រាក់ច្រើន (ទោះយល់សប្តិថា បានក្តាមខ្យងក៏ដូចគ្នាដែរ) ។

៣១-កិមិ គូថ ផុដ្ឋា យល់សប្តិថា បានប៉ះពាល់ត្រូវគំនរដង្កូវ ឬគំនរលាមក នឹងបានទ្រព្យមានវិញ្ញាណ ឬ ឥតវិញ្ញាណយ៉ាងរាប់ ។

៣២-នភង្គមានេ គរុឧណ្ណ កញ្ញា យល់សប្តិថា បានហោះទៅលើអាកាស នឹងមានយសប្រសើរជាងជនទាំងពួង ។ បើយល់សប្តិបានឃើញ បានប្រទះគ្រូអាចារ្យ នឹងបានជាទីគោរពនៃជនទាំងពួង ហើយនឹងបានអ្នកប្រាជ្ញមកជាកល្យាណមិត្រ ។ យល់សប្តិថា បានស្រីក្រមុំ បើជាសមណៈអ្នកឃ្យានសូត្រ នឹងចេះដឹងព្រះត្រៃបិដកជ្រៅជ្រះ បើជាគ្រហស្ថ នឹងបានលាភប្រកបដោយធម៌ ។

៣៣-អលង្គរោរន្ធា សុមនញ្ច មាលញ្ច យល់សប្តិថា បានប្រដាប់គ្រឿងអម្ពរ ឬ ប្រដាប់ផ្កាម្លិះ ឬកម្រងផ្កា បើជាស្រីក្រមុំ នឹងបានស្វាមីដ៏ជាទីគាប់ចិត្ត បើមានស្វាមីហើយនឹងបានបុត្រដ៏ជាទីគាប់ចិត្តទៀត បើជាប្រុសនឹងមានភរិយាដ៏ជាទីពេញចិត្ត ។

៣៤-បទុម បត្តេ សុថលេ ចកុញ្ចិ យល់សប្តិថា បានបរិភោគក្រអៅឈូក ស្ពឺឈូក ឬផ្លែឈើដ៏មានឱជារស នឹងសះជាអស់រោគក្នុងខ្លួន ហើយនឹងមានកំលាំងមាំមួន

៣៥-សុភប្បរុភក្ខំ យល់សប្តិថា បានឃើញជើមកល្បព្រឹក្ស ទោះនឹងគិតការអ្វីៗ នឹងបានសំរេចដូចសេចក្តីប្រាថ្នា ។

៣៦-រត្តចន្ទសារា យល់សប្តិថា បានលាបលំអិតខ្លឹមចន្ទន៍ ស-ក្រហម នឹងបានជាទីស្រឡាញ់នៃជនទាំងពួង ហើយនឹងបានសះជាអស់រោគក្នុងខ្លួន ។

៣៧-ឥសាភីរេហ្ម ឧគរេ សុមិនា យល់សប្តិថា បានជួបនឹងសមណៈព្រាហ្ម

ណាចារ្យ អ្នកស្វែងរកសីលាទិគុណ និងមានទេវតាមកអភិបាល ។ យល់សប្តិថាបានចូលទៅអាស្រ័យនៅក្នុងនគរ នឹងបានទីពឹងដ៏ក្សេមក្សាន្ត ហើយនឹងមានសេចក្តីសុខច្រើន ។

៣៨-សុវណ្ណហង្សា កិន្នរ អរញ្ញាំ យល់សប្តិ ត្រូចទៅក្នុងព្រៃចាប់បានហង្ស និងកិន្នរី នឹងមានអ្នកបរទេសនាំលាភមកអោយ ។ ន័យមួយទៀត នឹងបានភរិយាដ៏មានបណ្តាសក្តិ ។

៣៩-បកិរណេន្តេ សីសេច្ឆេទ ហតំ យល់សប្តិថា បានឆ្លាយពោះវៀនខ្លាត់ខ្លាយ ឬត្រូវកាត់ក្បាល កាត់ដៃ កាត់ជើង នឹងបានឡើងជាធំ បើជារាស្ត្រសាមញ្ញ នឹងបានជាមន្ត្រី, បើមន្ត្រីនឹងបានជាស្តេចគ្រងផែនដី, បើក្សត្រនឹងមានអំណាចផ្សាយទៅក្នុងទីទាំងពួងដូចយ៉ាងព្រះចន្ទរាជា ជាកូនអ្នកកំសត់បានគ្រងនគរពារាណសី ។

៤០-សុនោខិនា សង្ខ័លិកភាជិតា យល់សប្តិថា ត្រូវចំណងមានជាប់ឃ្លាងខ្លោះ ច្រវាក់ជាដើម នឹងបានយសសក្តិធំ បើជាមន្ត្រី នឹងបានឡើងយសសក្តិ បើជារាស្ត្រ សាមញ្ញ នឹងបានជាអ្នកគ្រាន់បើជាងគេ ។

៤១-សុសាបិនន្តេ ៣ហុះលកិលារកោ ។ល។ បសិទ្ធិភកម្មំ បត្តនញ្ច ទុទ្ធ្យ រឯសុបិន្តនិមិត្តទាំងឡាយ ដែលបានពោលមកនេះ សុទ្ធតែជាសុបិន្តនិមិត្តមង្គលដ៏ប្រសើរទាំងអស់ ជាហេតុអោយបានលាភ បានទ្រព្យសម្បត្តិចំរើនគុណ និងតេជានុភាព ប្រាសចាកទុក្ខភ័យរោគាព្យាធិទាំងពួង និងធ្វើអ្វីក៏រមែងបានសំរេចដូចបំណងគ្រប់ប្រការ ហោង ។ ព្រះអដ្ឋកថាចារ្យ អ្នកឈ្លាសដែក្នុងគម្ពីរសុបិន្តព្យាករណ៍ចាប់បានសង្កេត ឃើញពិតដូច្នេះហើយ ទើបចងក្រងទុក ដើម្បីជាប្រយោជន៍ដល់សត្វលោក អស់សេចក្តីតែប៉ុណ្ណេះ ។

សុបិននិមិត្តបែកខាចល្អ ៧៣យ៉ាង

ក្បួនយល់សប្តិ ក្រៅអំពីបែបដែលលោកចងជាគាថានោះ ឃើញថាទៀងទាត់ក្តីនឹងយកជាគតិបាន ដូចមានតទៅនេះគឺ :

១-យល់សប្តិថា បានបង់សំណាញ់ ឬស្នូចត្រី ទោះនឹងធ្វើការអ្វីគង់នឹងបានសំរេចដូចប្រាថ្នា ។

២-យល់សប្តិថា ឃើញអសនីបាត[1] ធ្លាក់មក នឹងបានមាសប្រាក់ ។

៣-យល់សប្តិថា បានចូលស្រកក្រោមដើមឈើធំ នឹងបានជាធំ ។

៤-យល់សប្តិថា ឃើញគេរាំ នឹងបានរៀបការសុខ ។

៥-យល់សប្តិថា បានជិះខ្លា នឹងត្រូវចេញទៅស្រុកឆ្ងាយ ។

៦-យល់សប្តិថា ចាប់បានកូនខ្លា និងកូនម្រឹគ នឹងបានទឹកដែនដំណែលល្អ នឹងមានកេរ្តិ៍ឈ្មោះ ។

៧-យល់សប្តិថា បានប្រជល់ដី មិនសូវល្អ (លោកអោយយកទឹកពាក្អមស្រោចនៅកណ្តាលផ្លូវ ទើបប្រែជាល្អវិញ) ។

៨-យល់សប្តិថា ដេកកណ្តាលទឹកហូរចូលមាត់ នឹងមានលាភចូលមកយ៉ាងរហ័ស

៩-យល់សប្តិថា ជិះរទេះក្របី ស្តេច ឬ មន្ត្រីនឹងអោយលាភ ។

១០-យល់សប្តិថា ជិះក្របីប្រជល់គ្នា (ឱ្យយកទឹកពាក្អមមកស្រោចខ្លួន សឹមកាត់សប្តិនោះទើបល្អ) ។

១១-យល់សប្តិថា ដេកនៅកណ្តាលដី នឹងបានភរិយាល្អ ។

១២-យល់សប្តិថា ជិះគ្រែស្នែង មានគេសែង ទោះនឹងប៉ងធ្វើការអ្វីនឹងបានសំរេច ដូចសេចក្តីប្រាថ្នា ។

១៣-យល់សប្តិថា គេអោយសំពត់អាវ នឹងមានលាភ ។

១៤-យល់សប្តិថា គេធ្វើទោសខ្លួន នឹងបានរីស្រុកនៅជាសុខ ។

១៥-យល់សប្តិថា សត្វត្រកួតឡើងផ្ទះ នឹងបានអ្វីម្យ៉ាងៗ ។

១៦-យល់សប្តិថា គេបក់អោយ នឹងបានធ្វើជាចៅហ្វាយនាយគេ ។

១៧-យល់សប្តិថា បានឃើញ ឬចាប់មនុស្សស្លាប់ (សព) នឹងបានមាសប្រាក់ ។

១៨-យល់សប្តិថា ទ្រព្យរបស់បាត់ បើនឹងទៅស្រុកឆ្ងាយ នឹងបានលាភដ៏ប្រសើរ

១៩-យល់សប្តិថា បានសូត្រធម៌ នឹងបានប្រាសចាកចង្រៃទាំងពួង ។

២០-យល់សប្តិថា បាននិមន្តព្រះពុទ្ធរូបទៅតំកល់ទុកឯវត្ត នឹងបានបុត្រភរិយា ឬខ្ញុំកំដរដ៏ជាទីគាប់ចិត្ត ។

២១-យល់សប្តិថា ឡើងផ្ទះថ្មី នឹងបានយសសក្តិ រឺ បានគ្រាន់បើម្យ៉ាងៗ ។

២២-យល់សប្តិថា បានដើរឆ្លងស្ពានទៅរហូត ទោះគិតការអ្វីៗ គង់នឹងបានសំរេចគ្រប់ប្រការ ។

២៣-យល់សប្តិថា បានសំលាប់ខ្លួនឯង នឹងឈ្នះអស់មារសត្រូវ ។

២៤-យល់សប្តិថា ឃំ នឹងមានលាភដ៏ជាទីពេញចិត្ត ។

២៥-យល់សប្តិថា បានឡើងដំបូល ឡើងភ្នំ នឹងបានឡើងយសសក្តិ ។

២៦-យល់សប្តិថា ដំរីព្រៃជ្រូ ខ្មោចក្នុងផ្ទះ នឹងថែរក្សា ។

២៧-យល់សប្តិថា មិត្រសំឡាញ់ស្លាប់ ទោះនឹងគិតការអ្វីៗ នឹងបានសំរេច ។

២៨-យល់សប្តិថា មានចាស់ព្រឹទ្ធាចារ្យដឹកដៃឡើងទៅកាន់ដំណេក នឹងបានលាភ

២៩-យល់សប្តិថា មានមនុស្សស្លាប់ក្នុងផ្ទះ នឹងមានលាភមកដល់ផ្ទះតែម្តង

៣០-យល់សប្តិថា បានឡើងដើមឈើធំ នឹងមានលាភដ៏ប្រសើរ រីនឹងបានជាមន្ត្រី

៣១-យល់សប្តិថា ឈ្លើងទាម ឬពស់ចឹក នាគព័ន្ធ នឹងបានគូរស្រករថ្មី ។

៣២-យល់សប្តិថា បានសំលាប់ខ្លួនឯងស្លាប់ ហើយត្រឡប់រស់ឡើងវិញ នឹងបាន ទ្រព្យច្រើន ។

៣៣-យល់សប្តិថា ព្រះចរចារផង ជាមហាមង្គលដ៏ប្រសើរ នឹងបានចំរើនដោយ ពរទាំង៤ប្រការ ។

៣៤-យល់សប្តិថា បានដើរទៅទិសឫតា៌ បើមានជំងឺឈឺ នឹងបានជាសះស្បើយ ។

៣៥-យល់សប្តិថា បានងូតទឹកជំរះកាយ នឹងរម្ងាស់អស់គ្រោះថ្នាក់ ។

៣៦-យល់សប្តិថា បានយកដំរីមកទីមរនេះ នឹងបានគ្រូអាចារ្យមកប្រដៅខ្លួន នឹងបានទីលំនៅ?ជាសុខ ។

៣៧-យល់សប្តិថា បានឃើញខ្លា នឹងមានតេជៈ តែបើយល់សប្តិថា ខ្លាប្រុងនឹង ខាំ នឹងមានសត្រូវប៉ងប្លែតប្លែន ។

៣៨-យល់សប្តិថា បានតាក់តែងគ្រឿងបរិភោគ និងសុរា មិត្រសំលាញ់នឹងនាំ លាភមកអោយ ។

៣៩-យល់សប្តិថា ជិះរថសេះ ឬរទេះគោ អ្នកធំនឹងអោយយសសក្តិ ។

៤០-យល់សប្តិថា ជិះសេះ នឹងមានព្រឹទ្ធាចារ្យ អាណិតជួយសង្គ្រោះ ។

៤១-យល់សប្តិថា ស្រមោច ស្រមើលឃាមខ្លួន នឹងបានបរិវារ ។

៤២-យល់សប្តិថា អង្គុរពេញផ្ទះ នឹងមានញាតិមករក ។

៤៣-យល់សប្តិថា បានកាត់ក្បាលមនុស្ស នឹងមានតេជៈឈ្នះអស់មារសត្រូវទាំងពួង

៤៤-យល់សប្តិថា ខ្លួនស្លាប់មានគេសែងទៅ នឹងមានលាភ ។

៤៥-យល់សប្តិថា ដេកកណ្តាលដី ក្បាលផ្តាក់រហូតទៅម្ខាង ជើងផ្តាក់រហូតទៅម្ខាង នឹងមានអំណាចផ្សាយទៅក្នុងទីទាំងពួង ។

៤៦-យល់សប្តិថា គេអារសាច់ខ្លួន នឹងបានជាមន្ត្រី ។

៤៧-យល់សប្តិថា សែនអោយខ្មោច នឹងបានទឹកឆ្អែង ។

៤៨-យល់សប្តិថា ដើរទៅក្នុងវត្ត នឹងបានអាស ព្រាក់ ។

៤៩-យល់សប្តិថា ទឹកថ្នាំ នឹងជាអស់ឈាតទាំងពួង ។

៥០-យល់សប្តិថា មនុស្សចាស់កោរ ក្រកជុតដូចកូនក្មេង នឹងមានលាភ ។

៥១-យល់សប្តិថា ផ្តាក់លាម ផ្តាក់ខ្ទុះ នឹងបានមាសប្រាក់ ឬរបស់ជាទីគាប់ចិត្ត

៥២-យល់សប្តិថា ឃើញព្រះអាទិត្យ ព្រះចន្ទ, ឃើញមនុស្ស ទោះនឹងទៅទីណាៗ នឹងបានជ័យជំនះ ។

៥៣-យល់សប្តិថា ឪណ្តាំបាយស៊ីនឹងសាច់ត្រី នឹងមានបងប្អូនយកលាភមកអោយ

៥៤-យល់សប្តិថា គេលើកអោយជិះដំរី ជិះសេះ ឬជិះស្មែង នឹងមានគេជួយឧបត្ថម្ភ នឹងបានយសសក្តិ ។

៥៥-យល់សប្តិថា គេចងកខ្លួនភ្ជាប់ទៅនឹងអ្នកដ៏ទៃ នឹងបានភរិយា ឬរយសសក្តិ

៥៦-យល់សប្តិថា គេហែខ្លួនទៅ នឹងបានលាភ ។

៥៧-យល់សប្តិថា អុំទូកទៅលើគោក ទោះនឹងគិតការអ្វីៗ នឹងបានសំរេច បើកើតក្តី នឹងឈ្នះគេ ។

៥៨-យល់សប្តិថា បានស៊ីផ្លែឈើអ្វីៗ នឹងបានរុងរឿង មានកេរ្តិ៍ឈ្មោះល្អ ។

៥៩-យល់សប្តិថា ប្រច្បៀវអកទុំផ្ទះ នឹងមានទេវតាថែរក្សា ។

៦០-យល់សប្តិថា តល់ឈើអណ្តែតមក នឹងមានលាភ ។

៦១-យល់សប្តិថា ឡើងស៊ីបាយលើកំពូលភ្នំ នឹងមានគេនាំទ្រព្យមកអោយ ពុំនោះសោត នឹងបានយសសក្តិធំ ។

៦២-យល់សប្តិថា បានស្លៀកពាក់ស ចុះងូតទឹក ហើយនឹងបានបេះផ្កាឈូកជាដើម នឹងបាននៅជាសុខស្រួល បើមានរោគាព្យាធិ នឹងជាសះស្បើយ ។ ន័យមួយទៀតថា នឹងបានគូស្រករ ។

៦៣-យល់សប្តិថា ដើរលើទឹក ឬ បានឆ្លងទឹកទៅ ដោយអ្វីៗក្តី ទោះបើនឹងគិតការអ្វីនឹងបានសំរេច ។

៦៤-យល់សប្តិថា បានស្បៃតប្រដាប់ផ្កា នឹងបានជាទីស្រឡាញ់នៃជនទាំងពួង ឬក៏នឹងបានគូរស្រករ ។

៦៥-យល់សប្តិថា ឃើញពោធិព្រឹក្ស ព្រះវិហារ នឹងស្បើយទុក្ខភ័យ ។

៦៦-យល់សប្តិថា បានស៊ីទឹកឃ្មុំ នឹងមានសិរីសួស្តី ហើយនឹងមានយសសក្តិ ។

៦៧-យល់សប្តិថា បានឡើងលើផ្ទះកខ្ពស់ នឹងបានជាមន្ត្រី ។

៦៨-យល់សប្តិថា បានស៊ីក្បាលមនុស្សស្រស់ៗ នឹងបានចៅហ្វាយស្រុក ឬខេត្ត ។

៦៩- យល់សប្តិថា បានទឹក បានឈេចឱសថ ឬ ស៊ីបង្អែម នឹងបានជាសះអោគាព្យាធិក្នុងខ្លួន ។

៧០- យល់សប្តិថា បានម្ជុលមាស នឹងបានកូនប្រុស ជាតិជាអ្នកប្រាជ្ញ ឬ ទោះនឹងគិតការអ្វី គង់នឹងបានសំរេច ។

៧១- យល់សប្តិថា បានឃើងកង្កែបឈេបព្រះអាទិត្យ ព្រះចន្ទ ល្អណាស់ នឹងមានបុណ្យ ។

៧២- យល់សប្តិថា បានឆ្លុះកែវឆ្លុះ ទោ នឹងគិតការអ្វី ឬប្រាថ្នាចង់បានអ្វី គង់នឹងបានសំរេចដូចសេចក្តីប្រាថ្នា ។

៧៣- យល់សប្តិថា ឃើងក្រមី ឬ ជីរ នឹងមានស្លាំង ន័យមួយទៀតថា ឃើញក្រមី នឹងមានខ្មោចព្រាយហិសាចប៉ងចៀតចៀន ។

សុបិន្តនិមិត្តបែកខាងអាក្រក់ ៣០យ៉ាង

១- យល់សប្តិថា ធ្មេញចាក់បើគ្មានឈាម ថានឹងមានមនុស្សដែលជាប់ជាសាច់ញាតិស្លាប់ បើមានឈាមថានឹងមានញាតិរបស់ខ្លួនស្លាប់ ន័យមួយថា បើចាក់ធ្មេញលើឪពុក ឬញាតិខាងឪពុកនឹងស្លាប់ បើចាក់ធ្មេញក្រោម មាតា ឬញាតិខាងមាតាស្លាប់ ។

២- យល់សប្តិថា ភ្លើងឆេះនៅក្នុងចង្ក្រាន ឬនៅក្នុងផ្ទះ នឹងមានប្បីងនាំអោយវិវាទនៅក្នុងផ្ទះ ។

៣- យល់សប្តិថា ឃើញផ្សែងភ្លើង នឹងលេចឮដំណឹង ដែលជាប្បីងនាំអោយភ្ញៅក្រហាយ តែនឹងរម្ងាប់ទៅវិញឯង ។

៤- យល់សប្តិថា សំពត់ដែលខ្លួនស្លៀកដាច់ផ្ទុះធ្លាយ ឬឃើញអាក្រាតកាយនឹងមានគេនិយាយដើមពីខ្លួន ។

៥- យល់សប្តិថា ឃើញស្រីដែលស្គាល់ឈ្មោះអាក្រាត ឆាងនោះនឹងមានគេនិយាយដើម ។

៦- យល់សប្តិថា បានឃើញ ឬចាប់បានពីងពក់ នឹងមានគេស្អប់ខ្ពើម ។

៧- យល់សប្តិថា ដើរលុយភក់ ចាប់កម្មរបស់ខ្លួននឹងអោយផល ។

៨- យល់សប្តិថា បានស៊ីផ្លែឆ្មោត ផ្លែពោត ឬផឹកទឹកឆ្មោត នឹងមានគេកុហក ឬគេបញ្ឆោតយករបស់ទ្រព្យ ។

៩- យល់សប្តិថា ជិះរទេះក្រចី នឹងមានសត្រូវប៉ងប្លែតប្លែន ។

១០- យល់សប្តិថា ជិះរទេះគោ ទោះនឹងគិតការអ្វីៗ ឬមានដំណើរទៅណា នឹងអាក់ខាន ។ (ន័យមួយទៀតថា : មានស្តេច ឬ មន្ត្រីធំអោយយសសក្តិ)

១១- យល់សប្តិថា ឃើញយក្ស អាបព្រាយនឹងប្លែតប្លែន ។

១២- យល់សប្តិថា ឃើញតាឋឺ ឬ ឱម៉ាល់ទិច អោយប្រយ័ត្នខ្លួន នឹងមានសត្រូវប៉ងប្លែតប្លែន ។

១៣- យល់សប្តិថា ស្លៀកពាក់សំពត់ក្រហម នឹងកើតរឿងក្តៅក្រហាយ ។

១៤- យល់សប្តិថា រន្ទះចាញ់ខ្លួន មិនល្អច្រើនប្រការ ឃើញរន្ទះចាញ់ផ្ទះ ម្ចាស់ផ្ទះនឹងស្លាប់, ឃើញចាញ់ដើមឈើក៏មិនល្អដែរ ឱ្យរៀបចំជានឹងត្រឡប់ជាល្អវិញ ។

១៥- យល់សប្តិថា មេដំបូលផ្ទះ ឬ ក៏សសរកន្លោងចាក់ខ្ចាត់ខ្ចាយ អ្នកមេផ្ទះនឹងស្លាប់ បើធ្លាក់ចាក់គ្រឿងឯទៀតអ្នកតូចក្នុងផ្ទះនោះនឹងស្លាប់ ។

១៦- យល់សប្តិថា ពានគ្រឿងសស្ត្រាវុធ មានសេចក្តីទំនាយជា ៤ យ៉ាងគឺ :

ក. ថានឹងឈ្នះអស់មារសត្រូវ ។

ខ. ថានឹងកើតបញ្ញាអារកាត់ប្រស្នាបាន ។

គ. ថានឹងបានបុត្រដែលមានសតិបញ្ញាល្អ ។

ឃ. ថាអោយប្រយ័ត្ន នឹងមានអ្នកធំគិតប្លែតប្លែន ។

១៧- យល់សប្តិថា ឃើញឥន្ទធ្នូចុះធីកទឹក នឹងមានគេមកសម្លាប់ខ្លួនអោយស្លាប់បង់ស្បែត ។

១៨- យល់សប្តិថា សក់ជ្រុះរលោះអស់ពីលើក្បាល នឹងកើតសេចក្តីអប្រិយដល់ខ្លួន ឬក៏ខ្លួននឹងត្រូវស្លាប់ ។

១៩- យល់សប្តិថា ចូលទៅក្នុងទីងងឹត មានគូហាជាដើម ឬក៏យល់សប្តិថាឃើញរាត្រីងងឹតចូលមក នឹងកើតទុក្ខព្រួយជាទម្ងន់ ។

២០-យល់សប្តិថា ជាវេលាថ្ងៃទេរ តែភ្នែកខ្លួនឃើញជាងងឹតហាក់ដូចជាយប់ នឹងមានទុក្ខយ៉ាងធំ ដោយហេតុក្មួនសំឡាញ់ជាដើម នឹងស្លាប់ចោល ។

២១- យល់សប្តិថា ឃើញភ្លៀងធ្លាក់ងងឹតអួរអ័ព្ទទាំងអាកាស នឹងមានញាតិមិត្តស្លាប់ក៏នឹងមានទុក្ខព្រួយដោយរឿងឯណានីមួយជាពុំខាន ។

២២-យល់សប្តិថា ឃើញខ្លួនងុះស្លាប មិនល្អ អោយទៅកាត់សប្តិក្នុងព្រះវិហារ ឬនៅកណ្តាលស្ពាន ហើយច្រឹបសក់របស់ខ្លួនបន្តិចចោលទៅ អាក្រក់នឹងបែរទៅជាល្អវិញ ។

២៣-យល់សប្តិថា ទឹកជន់មកលិចភូមិឋាន នឹងត្រូវចេញចាកទីលំនៅទៅនៅទីដទៃ

២៤- យល់សប្តិថា ទ្វារបស់ខ្លួនអណ្តែតទឹកទៅ អោយប្រយ័ត្ននឹងមានអន្តរាយទ្រព្យសម្បត្តិ ។

២៥- យល់សប្តិថា ស្លៀកសំពត់ខ្មៅ នឹងមានសត្រូវប៉ងមកប្លែតប្លែន ។

២៦- យល់សប្តិថា ស្រូវពេញក្នុងផ្ទះ នឹងកើតមានរឿងស្លៀបរមាស់ក្នុងឋាន ។

២៧-យល់សប្តិថា ឃើញឃាយស្រូវ នឹងកើតរមាស់កម ។

២៨-យល់សប្តិថា ជិះជ្រូក នឹងកើតរោគ ន័យមួយទៀតថា នឹងត្រូវចេញចាកទៅស្រុកឆ្ងាយ ។

២៩- យល់សប្តិថា ពាក់ជីនតាវែលាយប់ ភ្នែកខ្លួននឹងងងឹត ។

៣០- យល់សប្តិថា ចុះពីលើភ្នំ នឹងថយយសថយរាសី ។

សុបិន្តនិមិត្តបែកខាចបុរាណ៥៥យ៉ាង

សុបិនព្យាករណ៍របស់បុរាណមកឈ្វេរហើយដូចមានសំដែងតទៅនេះ :

សិទ្ធិការ្យ : នេះជាស្រដីនិរមិត្តនៃជនផង

១- ទោះយល់សប្តិ ឃើញព្រះពុទ្ធរូប នឹងមានទេវតា នឹងមានទេវតាដ៏មានឫទ្ធិ មកថែរក្សា ឱ្យម្យុបរណ្តាប់ឫជាដោយផ្កាភ្ញីទៀនធូប នឹងមានលាភក្រៃពេក ។

២- ទោះយល់សប្តិ ឃើញព្រះសង្ឃ ទេពតា ខ្មោច អារក្ស ខាងក្រៅ នឹងមករក្សា អោយម្យុបរណ្តាប់ឫជាដោយផ្កាភ្ញីនឹងមានលាភហោង ។

៣- ទោះយល់សប្តិ ឃើញដីរឈ្នាល សក្តិ ខ្មៅក្តី ត្រូវឫជាធ្វូសំពត់ស ដូង ស្ពា ម្ទូ ប្រេង ម្សៅ ទៀន ធូប ផ្កាភ្ញី នឹងមានលាភច្រើនហូរចូលមក ។

៤- ទោះយល់សប្តិ ឃើញដីរ ក្របី គោញី នឹងមានលាភជាពេកកន្តង ។

៥- ទោះយល់សប្តិថា បានស៊ីបាយ ឬអាហារផងទាំងពួង នឹងរម្ងាប់អស់រោគ គាព្យាធិទាំងពួង ។

៦- ទោះយល់សប្តិ ចាបស៊ីស្ករ ល្ង, ទឹកឆ្ពោត, ទឹកឃ្មុំ, ទឹកអំពៅ ឯណា នីមួយ ត្រាជ្ញាផុលផុសរុងរឿងឡើង ត្រូវបង្កាត់ភ្លើងអោយឆេះឡើង ហើយ សឹមអោយស្រាយត្រាប់គេជាហោង ។

៧- ទោះយល់សប្តិថា បានឃើញគេមកឆ្កៀលភ្នែកយើងទាំងពីរក្រលាកម្រតែងផ្ទៃ

ក្រោម នឹងអោយលាភចាន់ស្រុកហោង ។

๘- ទោះយល់សប្តិថា បានស៊ីសាច់ក្តី ស៊ីត្រីក្តី នឹងមានញាតិព្រៀងលានស្តាប់ហោង ។

๙- ទោះយល់សប្តិថា បានឃើញដំរីឈ្មោលក្តី ញីក្តី នឹងបានជាធំហោង ។

๑๐- ទោះយល់សប្តិថា ជិះសេះ នឹងមានអំណោយបានជានាយពលហោង ។

๑๑- ទោះយល់សប្តិថា បានឡើងភ្នំក្តី ឡើងប្រាសាទក្តី រាជមន្ទីរក្តី សឹងបានជាធំក្រៃលែងជាងអ្នកផង ។

๑๒- ទោះយល់សប្តិថា បានអារសាច់ទាំងឆ្អឹងក្តី សាច់ត្រីក្តី នឹងមានទុក្ខធ្ងន់ហោង

๑๓- ទោះយល់សប្តិថា ឃើញគេចាប់ក្តី, ចងក្តី, កាប់ក្តី ដាក់ជ្រួលច្រវាក់ក្តី ជាញ់ក្តី ឬត្រូវដំរីព្រៃជ្បក្តី នឹងមានលាភប្រសើរពេកតែអោយឫជាពលិការរួច ហើយសឹមស្រាយប្រាប់អ្នកដ៏ទៃ នឹងមានលាភបានយសសក្តិជាធំហោង ។

๑๔- ទោះយល់សប្តិថា ធ្មេញបាក់ នឹងមានអាសន្នស្មើរស្លាប់ខ្លួន ពុំនោះសោត នឹងមានមេចាញាតិតាបងប្អូនស្លាប់បង់ ។

๑๕- ទោះយល់សប្តិថា បានកាត់សក់ខ្លួនឯងក្តី កាត់ដែងជើងខ្លួនឯងក្តី និរមិត្តទាំង ๓ នោះពុំជា នឹងស្លាប់ ឬព្រាត់ប្រាស់បងប្អូនមិត្រសំឡាញ់ហោង ។

๑๖- ទោះយល់សប្តិថា បានកាន់ ឬបានឈប ព្រះអាទិត្យ ព្រះចន្ទ្រឬផ្កាយក្តី ជាលាភនិរមិតធំ អោយរៀបបូជាដោយទៀនធូបផ្កាភ្ញីម្រេងក្រចេះចន្ទ ហើយសឹមស្រាយប្រាប់អ្នកមានចំណេះប្រាជ្ញា រួច[illegible]ត្រូវបូជាទាំងនោះទៅបណ្តែតកណ្តាលទឹកបឹង នឹងបានជាធំហោង ។

១៧- ទោះយល់សប្តិថា ពាក់ទិញ្ញាំងឥតត្បូង និងមានប្រពន្ធក្មេង ហើយមានកូនស្រី ។

១៨- ទោះយល់សប្តិថា បានចារសាស្ត្រាក្តី, សរសេរសំបុត្រក្តី, ច្រៀងក្តី, សេចក្តីនិមិត្តទាំង ៣ ជំពូកនេះ នឹងកើតក្តីក្តាំ ប្រកែកធំ ជជែកខឹងសម្បានឹងគ្នាពុំជា អោយស្រាយច្រាប់នៅស្ត្រី ទើបមានលាភមកហើយស្តេះខាកកំហាក ៩ ដងជាហោង ។

១៩- ទោះយល់សប្តិថា បានឃើញក្របីដេញក្តី ឃើញជ្រូក ឆ្កែ ពពែ ស្វា ឱម៉ាល់, ឃ្មុំ ស្រាំង, វាជល់ ខាំ ទិចក្តី ពុំជានឹងមានសត្រូវមកប្បៀតប្បៀនថាបើពុំបានដល់ ខាំ-ទិចទេ នោះជាអោយស្រាយច្រាប់នៅទីព្រៃ នឹងមានលាភមកច្រើន អាច ធ្មប់ ក៏ពុំអាចនឹងធ្វើទោសយើងបានឡើយ ។

២០- ទោះយល់សប្តិថា ខ្លាខាំក្តី, នាគខាំឬព័ន្ធព័ទ្ធក្តី ពស់ខាំឬព័ន្ធព័ទ្ធក្តី ឬដេញបានខាំក្តី នឹងមានស្រីស្រឡាញ់ ស្នេហា នឹងបានភរិយាហោង បើពស់នោះមានពិសក្តី ឥតពិសក្តីគប្បីដឹងដោយនិរមិតថា: ស្រីអ្នកស្រឡាញ់ នោះមានសក្តិឥតសក្តិហោង បើពស់នោះដេញទាន់ក្តី ពុំទាន់ក្តី បានខាំក្តី គប្បីដឹងដោយ និរមិតថា នឹងបានឬពុំបាន បើពស់នោះក្មេងក្តី ចាស់ក្តី គប្បីយល់តាមនិរមិតថា ស្រី នោះ ក្រមុំ សាវតៃ មេម៉ាយហោង ។

២១- ទោះយល់សប្តិថា បានឃើញពស់ក្រាយដេញ តែពុំទាន់ក្តី ដេញទាន់បានខាំក្តី ឬព័ន្ធក្តី ពស់ចង្រៃអាក្រក់ពុំជួនកាលដូច្នេះ ពុំជា នឹងមានសត្រូវប៉ងប្បៀតប្បៀនអោយស្រាយច្រាប់នៅទីព្រៃ មានលាភមកច្រើន នឹងជាវិញ្ញហោង

២២-ទោះយល់សប្តិថា បានឃើញខ្លាខាំអ្នកដទៃ ពុំជាអោយបកស្រាយច្រាប់គេ នៅទីព្រៃ មានលាភមកច្រើន នឹងជារឿញហោង ។

២៣-ទោះយល់សប្តិថា បានឃើញក្អែក កុំអោយចុះទៅកំពង់ទឹក, កុំអោយធ្វើដំណើរតាមផ្លូវជើងទឹក ក្រែងត្រូវក្រពើ ឬនាគវាខាំ ឬព័ន្ធព័ទ្ធជុំជាឡើយ អោយស្រាយ ច្រាប់គេនៅទីព្រៃ មានលាភ នឹងជារឿញហោង ។

២៤-ទោះយល់សប្តិថា បានឃើញត្រកួតក្តី, ទន្សាយក្តី, តុកកែក្តី, បង្គួយក្តី ជាសក្តី ក្រពើក្តី ជីងចក់ក្តី ពុំជា នឹងមានក្តៅក្នុងចិត្ត អោយស្រាយច្រាប់គេ នៅទីមានលាមក នឹងជារឿញហោង ។

២៥-ទោះយល់សប្តិថា បានពាក់ចិញ្ចៀនមានត្បូង នឹងបានប្រពន្ធជាអ្នកធំ ហើយមានកូនប្រុសហោង ។

២៦-ទោះយល់សប្តិថា បានរាយអំតងក្តី ស្គរក្តី ពាត្យាក្តី នឹងមានយសជាធំហោង ។

២៧-ទោះយល់សប្តិថា បានផ្ទុំត្រែ សង្ខ នឹងមានសព្ទពាត្យាន នឹងមានយសធំ

២៨-ទោះយល់សប្តិថា បានសំពត់ចាស់ នឹងបានប្រពន្ធចាស់ហោង ។

២៩-ទោះយល់សប្តិថា បានសំពត់ថ្មី នឹងបានប្រពន្ធអំបូរខុនណាងក្រមុំហោង។

៣០-ទោះយល់សប្តិថា ឈ្នឹងខាំ នឹងបានទ្រព្យភ្ញាសំណាញ់ហោង ។

៣១-ទោះយល់សប្តិថា បានឃើញសូរ្យគ្រាស និរមិតឧត្បាតផ្ទៃក្រោមអ្នកធំ នឹងព្រួយហោង ។

៣២-ទោះយល់សប្តិថា បានឃើញទឹកឡើងក្តី ឃើញទឹកត្រជាំងក្តី ឃើញទឹកល្អក់

ក្តី ឃើញភ្លៀងកក់ ទទឹកសំពត់អាវក្តី និរមិតអំបាលនោះពុំជា គេនឹងស្រដីដើម គេនឹងយកខ្លួនចេញពីស្រុក នឹងមានទុក្ខអំពល់អោយស្រាយប្រាប់គេនៅទីព្រៃ នឹងមានលាភមក នឹងត្រឡប់ល្អវិញហោង ។

៣៣-ទោះយល់សប្តិថា បានឃើញទឹកស្រក ហើយឃើញខ្សាច់ត្រួស នឹងស្បើយជំងឺដម្កាត់ ទុក្ខសោកទាំងពួង ឱ្យអង្គុយបែរមុខទៅទិសបូព៌ ហើយស្រាយប្រាប់គេ នឹងមានលាភហោង ។

៣៤-ទោះយល់សប្តិថា បានឃើញដើមឈើ មានមែកត្រសុំ សាខាខ្ពង់ខ្ពស់ ហើយមានផ្លែផ្កា នឹងមានលាភ អ្នកធំនឹងអោយសក្តិទ្រព្យសម្បត្តិ តែឱ្យឃកទៀន ធូបភ្ញីបូជាព្រះពុទ្ធ ហើយសឹមស្រាយប្រាប់គេមានលាភជាហោង ។

៣៥-ទោះយល់សប្តិថា បានឡើងដើមឈើខ្ពស់ក្តី ឡើងដើមអ្វងបានទាំងធីផ្លែក្តី ឡើងលើប្រាសាទក្តី វិមានក្តី ឡើងទៅកណ្តាលអាកាសក្តី និរមិតទាំង៥យ៉ាងនេះ ជាមង្គល នឹងបានឡើងយស នឹងបានទ្រព្យសម្បត្តិនៅជាសុខហោង

៣៦-ទោះយល់សប្តិថា បានឃើញស្បែតផ្កាស្អិតស្អាងអាត្មាឯងក្តី ឃើញស្លៀកសំពត់ក្រហមក្តី ឃើញខ្លួនឯងលុងធីតរាយក្តី ឃើញឆ្កែកញ្ជក់ក្តី សេចក្តីនិរមិតទាំង៥យ៉ាងនេះ ពុំជានឹងមានឃាតាព្យាធិអោយឬជាតាមដូចនិរមិតនេះ ហើយអោយស្រាយប្រាប់ អ្នកមានចំណេះវិជ្ជាជាហោង ។

៣៧-ទោះយល់សប្តិថា ខ្លួនឯងស្លាប់ក្តី ទោះស្លាប់ដោយជីវព្រោះក្តី អោយយកចេកអំបូងឬជា ហើយអោយស្រាយប្រាប់អ្នកធំ នឹងមានលាភប្រសើរពេកហោង ។

៣៨-ទោះយល់សប្តិថា ពស់ចឹក បើប្រុសមានស្រីស្រឡាញ់ បើស្រីនឹងមានប្រុសស្រឡាញ់វិញហោង ។

៣៩-ទោះយល់សប្តិថា កោរសក់ក្តី កាត់សក់ក្តី ពុំជាអោយស្រាយច្រាប់នៅទីព្រៃ និងមានលាមក រីច្រាប់នៅផ្ទះវិញ្ញា ហើយយកបន្លាសង្កត់និងជារិញហោង ។

៤០-ទោះយល់សប្តិថា បានឡើងដូងរួចដល់ចុង ទោះបានបេះផ្លែក្តី ពុំបានបេះផ្លែរីក្តី ជាពេកអោយស្រាយច្រាប់អ្នកមានចំណេះ និងមានលាភបានធីស្រុកធំហោង ។

៤១-ទោះយល់សប្តិថា បានស្វាក្តី បានកូនពពែក្តី និងមានលាភបានកូនក្រមុំគេប្រសើរពេក ឱ្យស្រាយច្រាប់គេក្នុងទីដំណេក និងបានអ្វីៗដូចចិត្តប្រាថ្នាហោង

៤២-ទោះយល់សប្តិថា បានឃើញមន្ត្រី, ឧកញ៉ា, ពញ្ញា, ព្រះក្តី អោយស្រាយច្រាប់អ្នកសំឡាញ់ភ្ញាជាពេក គេនឹងមកឱ្យរបស់ទ្រព្យយើងហោង ។

៤៣-ទោះយល់សប្តិថា បានឃើញឈើធំមានសង្ហារឡើងក្តី ឃើញខ្លួនឡើងបេះផ្កាអ្វីៗ ទាំងពួងក្តី អោយយកទៀនធូបផ្កាភ្ជាបូជាព្រះពុទ្ធ និងបានលាភប្រសើរពេកហោង ។

៤៤-ទោះយល់សប្តិថា បានឃើញជិះដំរីឈ្មោលក្តី ញីក្តី និងបានជាធំ និងមានលាភច្រើន ពួកមន្ត្រីអ្នកមានបណ្តាសក្តិ និងស្រឡាញ់ពេកហោង ។

៤៥-ទោះយល់សប្តិថា ជិះសេះ និងបានជានាយពលហោង ។

៤៦-ទោះយល់សប្តិថា ឡេកលើផ្ទះធំក្តី ឬ លើទីរាជអាសនៈមន្ទីរប្រាង្គប្រាសាទ

ក្តី នឹងបានជាធំក្រៃលែងជាងអ្នកផង ។

៤៧-ទោះយល់សប្តិថា បានស្រីក្រមុំមកនៅ កុំអោយទៅកំពង់ទឹកឡើយ ក្រែង សត្វទឹកនឹងធ្វើទោសហោង ។

៤៨-ទោះយល់សប្តិថា គេស្រដីដើម ជាពាក្យអាក្រក់ ពមុជួនកាលនឹងបានក្តីជាវិញហោង ។

៤៩-ទោះយល់សប្តិថា គេសរសើរយើង ពុំជាវិញហោង ។

៥០-ទោះយល់សប្តិថា សំពត់ខ្លួនដាច់ក្តី យល់សប្តិឆីម្ខ ផងទាំងពួងក្តី នឹងមាន អ្នកផងស្រដីដើម ឱ្យស្រាយច្រាប់គេនៅព្រៃ នឹងមានលាភមកជាវិញហោង ។

៥១-ទោះយល់សប្តិថា ឃើញឃ្មុំហើរ នឹងបានមហ៌ពលចូលច្រើនពេកហោង ។

៥២-ទោះយល់សប្តិថា បានកាន់ព្រះ នឹងមានអំណាចស្មើស្តេចតមិយអោយឃ្យប បូជា នឹងមានលាភ ពុំនោះក្រែងមានមេចាឈឺថ្កាត់ ។

៥៣-យល់សប្តិឃើញដង្កូវនីខ្លួន នឹងបានស្វែតច្ឆត្រហោង ។

៥៤-ទោះយល់សប្តិថា ឃើញខ្លួនមានដំបៅទឹករងៃ ខ្ទុះពេញអស់ទាំងពួង នឹងមាន យសប្រសើរក្រៃលែងជាងអ្នកផង ។

៥៥-ទោះយល់សប្តិថា ឫទ្ធិច ក្រែងនឹងត្រូវអំពើអំពាន់ចំរុងគេអោយស្រាយច្រាប់ គេនៅផ្លូវមានព្រៃជាហោង ។

តម្រាកាត់សប្តិទាំង៥៥យ៉ាងចប់តែប៉ុណ្ណោះ ។

តម្រាមើលលក្ខណៈនៃរាងកាយ

សិទ្ធិការ : តម្រាពិចារណាលក្ខណៈនៃរាងកាយរបស់បុគ្គល អោយបានដឹងថា កាច ឬ ជានោះ មានច្រើនយ៉ាងច្រើនប្រការណាស់ បានចំឡងតាមតម្រាចាស់ប្រាណ ទាំងមានអ្នកដែលបានសិក្សាមកហើយ បានពិចារណា ទាយអោយបណ្តាជនមិនសូវមានខុស ជាតម្រាដែលគួរជឿបាន តែខ្ញុំចំលងយកតែត្រង់ដែលល្អ នឹងត្រង់ដែលមើលងាយស្រួល ហើយចំលងយកសេចក្តីតែដោយសង្ខេប គ្រាន់តែជាគ្រឿងប្រដាប់បញ្ញានៃអ្នកដែលចូលចិត្តមើលលក្ខណៈផ្សេងៗ ជាគុណប្រយោជន៍ ដែលនឹងអោយដឹងថាល្អ ឬ អាក្រក់ តែបើមានខុសឆ្គងយ៉ាងណាមួយ ក៏ព្រោះតែអ្នកដែលមើលនោះពិចារណាមិនគ្រប់គ្រាន់ ទើបទាយលក្ខណៈនោះខុសទៅ ។

លក្ខណៈបាតដៃមាន៨យ៉ាង

១-លក្ខណៈបាតដៃដែលសំខាន់នោះគឺ មានសាច់នឹងឆ្អឹងសមនឹងគ្នា បើឆ្អឹងដុះស្តួចឡើងមកមិនល្អ បើបាតដៃមានសាច់ស្រោបឆ្អឹងមិនជិត ទាយថា មិនល្អច្រើនអភ័ព្វ បើសាច់ចេញក្រាស់ឋិរឫណ៍ល្អណាស់ បើឆ្អឹងច្រើន សាច់តិច អ្នកនោះនឹងពឹងញាតិមិនបានឡើយ ។

២-លក្ខណៈបាតដៃល្អនោះគឺ បាតដៃទន់ល្មើយដូចសំឡី សម្បុរល្អិតដូចសម្ពត់សម្ពល់អណ្តោញដៃមានខ្សែតូចដូចសូត្រពណ៌ក្រហម ស្រវែងនឹងជាតិហិង្គុល, ក្តៅខ្លួនៅ

ជានិច្ច មិនត្រជាក់ស្រេង ខ្លងដៃកំពង់ដូចខ្លងរណ្តៅក កណ្តាលចាតដៃខូចដូចសំបកស៊ុត មាន់ ឆ្អឹង និងថ្នាំងដៃរលើងស្អាត មិនដុះចោង ស្បែកធូរសាច់ក្រាស់ បើជនណាមានចាតដៃដូច្នេះ គង់នឹងមានបុណ្យវាសនា បើមិនដូច្នេះទេ គង់នឹងបរិបូណ៌ដោយទ្រព្យសម្បត្តិ ។

៣-លក្ខណៈចាតដៃអាក្រក់នោះគឺ ចាតដៃរីង, គគ្រាត ពណ៌ស្វិត ស្លេក ក្រៀម ខ្លោចស្រអ៊ូព្ងន្ទៅ មិនស្រស់ថ្លា សរសៃចំឡោល ឆ្អឹងធំកោងខ្ពស់ សាច់តិចជាងឆ្អឹង ចាតដៃស្តើង លក្ខណៈដូចពោលមកនេះ ច្រើនបានសេចក្តីលំបាកទាំងអាយុក៏មិនយឺនយូរ

៤-ចាតដៃធំ ម្រាមតូច កាលអាយុនៅតិច ទុកទ្រព្យសម្បត្តិមិនគង់, ចាតដៃពណ៌ដូចថ្លើមជ្រូក ច្រើនបានទៅក្នុងទ័ពសឹក បើមិនដូច្នោះទេ ច្រើនចាកចោលទីលំនៅ, បើមនុស្សស្តើមចាតដៃស្តើងមិនជាអ្វីទេ មនុស្សស្តើម ចាតដៃធាត់ល្អណាស់, មនុស្សធាត់ចាតដៃមិនមានសាច់ មិនល្អ, មនុស្សធាត់ ចាតដៃក្រាស់មានសាច់ច្រើន ជាណាស់ហោង ។ បើចាតដៃល្អ តែអត្ថាញ្ញូដៃអាក្រក់ កាលនៅតូចទ្រព្យសម្បត្តិនឹងវិនាសខ្ចាត់ខ្ចាយ, បើលក្ខណៈអត្ថាញ្ញូដៃល្អ តែចាតដៃអាក្រក់ អស់ចាស់នឹងមានទ្រព្យតែល្មមប្រមាណ ចាតដៃសម្បូរល្អិតតែច្រ ទោះនឹងមានក៏ត្រូវធ្វើឈឺឈប់ឈួយ, ចាតដៃមានប្រជ្រុយអាំដែង នឹងមានទ្រព្យសម្បត្តិ ហើយនឹងមានបុណ្យផង, បើចាតដៃមានអត្ថាញ្ញូដ៏ប្លែកចំឡែក អ្នកនោះគង់នឹងមានយសសំតិ, បើសរសៃតាមឆ្អឹងខ្លួនឡើងស្ទុង អ្នកនោះខ្លួនជាសុខ តែចិត្តជាទុក្ខ បើថ្នាំងច្រវាងធំ ប្រហោងម្រាមដៃឃ្លាតគ្នា អ្នកនោះច្រើនខ្ជិលច្រអូស បើចាតដៃពណ៌ឈ្លីងត្រជាក់ដូចទឹក អ្នកនោះច្រើនឈប់សប្តិអាក្រក់ ហើយស្រេវរំខ្លាចភិតភ័យ បើចាតដៃក្តៅឧណ្ហៗ ពណ៌ឈាមក្រហម អ្នកនោះមានតាំងពីតូចដល់ធំ មិនសូវលីអាម៉ាប់

បើបាតដៃឆ្វេងកាត់ ដៃស្តាំមិនកាត់ អ្នកនោះមានញាតិតិច បើកាត់ទាំងសងខាង ច្រើនឃ្លាតពីញាតិហោង ។

៥-លក្ខណៈបាតដៃដែលសមគួរនោះគឺមនុស្សស្តមដៃស្តើង មនុស្សធាត់ដៃក្រាស់, មនុស្សធំដៃធំ, មនុស្សតូចដៃតូច, មនុស្សល្អដៃល្អ, មនុស្សអាក្រក់ដៃអាក្រក់ បើក្រហមចាស់ស្រស់ អញ្ជាញដៃខ្សែតូចជ្រៅល្អះល្អ គង់នឹងមានបុណ្យវាសនាប្រាកដហោង ។

៦-លក្ខណៈបាតដៃដែលមិនសមគួរនោះគឺ បាតដៃចំរាមខ្លី អ្នកនោះច្រើនត្រូវគេនិន្ទា, ឆ្អឹងធំ សរសៃអណ្តែត អ្នកនោះបានសុខតិច មានទុក្ខច្រើន, ខ្នងដៃឆ្អឹងឡើងខ្ពស់ អ្នកនោះតាំងពីតូចដល់ធំ ត្រូវធ្វើយព្រួយច្រើន កាយតូច ដៃធំ ច្រើនអ្នកចាយវាយប្រាក់កាស ។

៧-ពណ៌សាច់បាតដៃដែលសមគួរដល់រដូវកាលនោះ គឺរដូវក្តៅមានញើស រដូវភ្លៀង ស្រស់ថ្លា មិនស្ងួតក្រៀម, រដូវរងា ស្ងួតក្រៀម, ដូច្នេះទើបត្រូវតាមរដូវកាល អ្នកនោះនឹងមានសេចក្តីសុខសប្បាយ ។ បើរដូវក្តៅត្រឡប់ទៅជាស្ងួតក្រៀម រដូវរងាត្រឡប់ទៅជាមានញើស អ្នកនោះនឹងពិបាកមិនមានសតិបញ្ញាអ្វីឡើយ ។

៨-បើខ្នងដៃសរសៃឡើង បាតដៃសាច់រឹង អ្នកនោះជាមនុស្សមាំមួន ឧស្សាហ៍តែធ្វើយព្រួយច្រើន បើសរសៃរមៀបរយ សាច់ណែនឹងមានទ្រព្យស្តុកស្តម្ភ, បាតដៃ ខ្នងដៃមានពណ៌សាច់ដូចគ្នា ជាលក្ខណៈដ៏វិសេសណាស់ ។ បើបាតដៃពណ៌ផ្សងផង់ ល្អជាងខ្នងដៃ អ្នកនោះនឹងមានទ្រព្យច្រើន, បើបាតដៃខ្មៅជាងខ្នងដៃ ជាអ្នកខ្សត់ទ្រព្យហោង ។

លក្ខណៈអញ្ជាញដៃ

សិទ្ធិការ្យ : នឹងពោលលក្ខណៈអញ្ជាញដៃ ជនទាំងឡាយ អ្នកដែលមានអញ្ជាញដៃល្អ ប្រៀបដូចជាព្រឹក្សាជាតិដែលមានឆ្ងុត និងឡាយដ៏ល្អ បើឈើណាមានឡាយល្អហើយ ឈើនោះនឹងជាទីស្រឡាញ់នៃជនទាំងឡាយ ខនេះ ដូចម្តេចមិញ ជនទាំងឡាយឯណាមានអញ្ជាញដៃដ៏ល្អហើយ ក៏ជាទីរាប់អាននៃជនទាំងឡាយដូច្នោះដែរ ។

លក្ខណៈអញ្ជាញដៃមាន២៤យ៉ាងគឺ

១-បើអ្នកណាគេមានអញ្ជាញដៃជ្រៅល្អិត ក៏ដឹងបានថា អ្នកនោះជាមនុស្សជាន់ខ្ពស់ មានបញ្ញាស្មារតីដ៏ល្អ ។ បើអ្នកណាមានអញ្ជាញដៃគ្រោតគ្រាតអញ្ជាញដៃរាក់សរសៃគ្រោតគ្រាត ឬមិនមានជាស្តាមអញ្ជាញឡើយ ក៏ដឹងបានថា អ្នកនោះជាមនុស្សជាន់ទាប មានបញ្ញាស្មារតីអន់ថយហោង ។

២-គន្លងអញ្ជាញដៃលក្ខណៈដែលល្អនោះ គឺសរសៃល្អិត គន្លងជ្រៅ មិនគរ មិនជាច់ មិនបែក គន្លងល្អះល្អជារូបអ្វីនីមួយ ឬជារូបត្រា ជាតួអក្សរ ឬជារូបសត្វផ្សេងៗ ទាំងនេះសុទ្ធតែល្អ ។ លក្ខណៈដែលអាក្រក់នោះគឺសរសៃធំ គន្លងគ្រោតគ្រាត គន្លងរាក់ គន្លងជាប់ គន្លងបែក គន្លងមិនជារូបអ្វី គន្លងមិនល្អះល្អ លក្ខណៈទាំងនេះសុទ្ធតែអាក្រក់ ។

៣-បើអញ្ជាញដៃច្រេះជ្រៃទៅច្រើន អ្នកនោះមានទុក្ខច្រើន បើអញ្ជាញដៃគ្រោតគ្រាត ទទឹងច្រើន អ្នកនោះមានបញ្ញាប្រាជ្ញាស្មារតីតិច បើអញ្ជាញដៃសរសៃត្រង់ៗលូកចូលទៅក្នុងម្រាម អ្នកនោះបើធ្វើការអ្វីៗ នឹងបានសំរេចដូចសេចក្តីប្រាថ្នាហោង ។

៤-បើអណ្តាញដៃសរសៃដូចសូត្រប្រទាក់ឆ្លាក់គ្នា អ្នកនោះមានសតិបញ្ញា បើអណ្តាញដៃត្រោតត្រាត តន្តងត្រើមៗ ដូចដែកឆាប អ្នកនោះច្រើនឡើយព្រួយ រហូតអស់មួយជាតិ បើអណ្តាញដៃជាក្រឡាដូចរាយអង្គាម មានពេញទៅទាំងបាតដៃ អ្នកនោះមានសេចក្តីសុខរហូតអស់មួយជីវិតហោង ។

៥-បើអណ្តាញដៃដូច្នេះ X X + + + ឬ + + + + + + មានទៅបន្តាប់ ក្រោមម្រាមទាំង៣ ចុះមក គឺពីបានទី៥-៦-៧ ទំនាយថា អ្នកនោះនឹងមានសេចក្តីសុខសប្បាយច្រើនណាស់ហោង ។

៦-បើអណ្តាញដៃដូច្នេះ ^^^ មានទៅក្នុងរវាងបានទី២ ទាយថា អ្នកនោះជាមនុស្ស មានបុណ្យវាសនា ហើយតរង្សត្រកូលមកបានច្រើនដំណ ។

៧-បើអណ្តាញដៃដូច្នេះ X + X ទាយថា អ្នកនោះជាអ្នកមានសតិបញ្ញាច្រើន នឹងបានជាធំហោង ។

៨-បើអណ្តាញដៃដូច្នេះ X ខាងក្រោមម្រាមទាំងពីរចុះមក ទាយថាអ្នកនោះនឹងបានពឹងឈាកអ្នកដ៏ទៃ ហើយនឹងយកអ្នកដ៏ទៃមកជាញាតិ រឺ បើមានកូនតូចចិញ្ចឹមនឹងបានពឹងកំលាំងហោង ។

៩-បើមានអណ្តាញដៃដូច្នេះ ដូចស្រកាត្រី ទាយថាអ្នកនោះនឹងមានបញ្ញា ។

១០-បើអណ្តាញដៃដូច្នេះ ដូចស្រកាត្រី ទាយថាអ្នកនោះនឹងបានពឹងបងប្អូនខាងឯខ្លួន នឹងមានចិត្តស្រឡាញ់រាប់អានណាស់ហោង ។

១១-បើមានរូបដូចកន្ទុយត្រី មានទៅនឹងម្រាមមេដៃ ទាយថាអ្នកនោះនឹងស្តុកស្តម្ភបរិបូណ៌ដោយទ្រព្យសម្បត្តិហោង ។

๑๒-បើមានអញ្ចាញដៃដូច្នេះ ទាយថាអ្នកនោះនឹងមានវាសនាច្រើន ហើយនឹងមានទ្រព្យច្រើនណាស់ហោង ។

๑๓-បើអញ្ចាញដៃមានរូបជាជើងក្អែកដូច្នេះ X មានពាសពេញទាំងបាតដៃ ទាយថា អ្នកនោះនឹងសម្បូរហូរហៀរដោយទ្រព្យ ព្រមទាំងមានអំណាចផង ។

๑๔-បើអញ្ចាញជារូប๔ជ្រុង មានទៅកណ្តាលបាតដៃ ជារូបល្អច្បាស់លាស់ មិនដាច់ ទាយថា អ្នកនោះនឹងមានវាសនាពីកាលនៅក្មេង ។

๑๕-បើអញ្ចាញដៃរូប๔ជ្រុងរៀបគ្នាជាលំដាប់ ជាជាន់ៗ ទាយថាអ្នកនោះនឹងបានជានាហ្នឹនធំហោង ។

๑๖-បើអញ្ចាញដៃជាក្រឡាចត្រង្គ នៅក្រោមម្រាមដៃត្រង់ឋានទី๓ ទាយថា អ្នកនោះជាអ្នកមានទុក្ខ ឧស្សាហ៍ត្រិះរិះ ទោះបីគ្មានហេតុអ្វី តែត្រូវក្នុងដួងចិត្ត ក៏ត្រូវតែត្រិះរិះពិចារណាអោយកើតទុក្ខព្រួយនៅជានិច្ច ។

๑๗-បើអញ្ចាញដៃមានរូបដូច្នេះ ទាយថា អ្នកនោះនឹងមានទ្រព្យ សម្បត្តិ មានបុណ្យហោង ។

๑๘-បើអញ្ចាញដៃមានរូប๔ជ្រុងដូច្នេះ ប្រួប๓ជ្រុងដូច្នេះ ប្រួប ខ្លែង ដូច្នេះ និងហៅរូបត្រា បើអ្នកណាមានរូបត្រានៅកណ្តាលបាតដៃ ទាយថា អ្នកនោះនិយាយម្យឿងអ្វីៗជាទីជឿបានតាំងពីតូចដល់ធំ មិនមានឧបាគភ័យអន្តរាយ ជាអ្នកមានចិត្តក្លាហាន មិនខ្លាចខ្មោចបិសាចត្រប់យ៉ាង, បើសេពគប់នឹងអ្នកធំនឹងមានអំណាច បើរូប๓ជ្រុងមាននៅលើបាតដៃឡើងទៅត្រង់ឋានទីពីរ ឬជារូបខ្លែងប៉ាក់ចៅ អ្នកនោះលោភដោយកាមគុណ, បើនៅបន្តាប់ម្រាមកូនដៃចុះមក ពុំល្អឡើយ ។

១៩-បើអញ្ជាញដៃមានរូបដូច្នេះ គួសត្រង់ឡើងទៅ នៅត្រង់កណ្តាលចាតដៃ ទាយថាអ្នកនោះមានអាយុយឺនយូរ បើចុះរហូតហួសថ្នាំងម្រាមកណ្តាលត្រង់ឡើងទៅ ទាយថា នឹងមានបុណ្យមានទ្រព្យច្រើន ។

២០-បើម្រាមទាំង៥ មានអញ្ជាញត្រង់ តាំងពីចាតដៃចុះរហូតឡើងទៅទាំង៥ម្រាម ទាយថា ល្អណាស់ អ្នកនោះនឹងបរិបូណ៌ត្រប់ប្រការហោង ។

២១-បើអញ្ជាញដៃមានរូបដូច្នេះ ≡ ទាយថានឹងបានពឹងកំលាំងស្រីល្អហោង។

២២-បើអញ្ជាញដៃមានរូបដូច្នេះ បីរមធ្យឹងគ្នា ល្អណាស់ហោង ។

២៣-បើអញ្ជាញដៃមានរូបសំណចដូចត្រាផ្សេងៗ ឬជាតួអក្សរណានិមួយក្តី តែអោយឃើញច្បាស់ទែង គ្មានបែក គ្មានតគ្មានជ្រៀច គ្មានស្រអាប់ ទាយថា អ្នកនោះនឹងបរិបូណ៌មួយជាតិ ល្អណាស់ហោង ។

២៤-បើអញ្ជាញដៃមានរូបដូច្នេះ ▭ ហៅថារូបមឈូស អាក្រក់ណាស់ អញ្ជាញដៃបែបនេះចំណាំតែមានរាល់ឆ្នាំកើតក្នុងរវាងបន្ទាប់ក្រោមម្រាមមេដៃចុះមកត្រង់ឋានទី៣ ទីត្រង់នោះមានសាច់ច្រើន អញ្ជាញបែបនេះ ចំណាំតែមានសាច់ច្រើន អញ្ជាញបែបនេះច្រើនកើតក្នុងទីនោះញយៗ បើរូបដាច់ ឬ មានអញ្ជាញដៃប្រទាក់ឆ្លាត់ឆ្លាយមើលមិនច្បាស់ ក៏មិនមានទោស បើចំជារូបមឈូស ហើយទីនោះជាពណ៌ខ្មៅឡើងមក ឬជាពណ៌ស ទាយថាអាក្រក់ណាស់ បើកើតមានឆ្នាំណា អោយទោសឆ្នាំនោះ, បើកើតរូបតែមួយទាយថា នឹងធ្វើការអ្វីច្រើនមានឧបសគ្គត្រឿងទាក់ទាម មានសេចក្តីក្តៅចិត្តជាញឹកញយ បើមានពីររូប ទាយថា នឹងបង់ញាតិមិត្រដែលជាទីស្រឡាញ់, បើមាន៣រូប ទាយថា នឹងត្រូវមានទុក្ខសោកឈាតភ័យផ្សេងៗ បើមាន

៤រូប ទាយថាអស់អាយុ បើអញ្ជាញដៃជារូបមនុស្ស និង មានរូបតូចខ្មៅនៅលាយជាមួយផង ទាយថា អ្នកនោះនឹងសម្លាប់ខ្លួនឯង ។

កំណត់ឋានត្រឿងសំគាល់នៃអញ្ជាញដែលមានប្រយោជន៍គឺ

សិទ្ធិការ្យ : អាចារ្យមួយពោលថា បើនឹងមើលលក្ខណៈអញ្ជាញដៃឱ្យល្អិតល្អន់ ត្រូវមើលតាមចំណែក៩ឋានក្នុងរូបនេះ ចំណែកជាតដៃ ចែកចេញ៩ចំណែក តាមរូបដៃដែលមានរូចខាងលើនេះ ។



អធិប្បាយលក្ខណៈនៃចាតដែ

លក្ខណៈបាទទី១ : ចានដល់មាតាបិតា និងញាតិចាស់ទុំ

- ២ : ចានដល់ភោគទ្រព្យវង្សត្រកូលជាដើម
- ៣ : ចានដល់បងប្អូន និងស្រែចំការ
- ៤ : ចានដល់ភរិយាគូចធំ
- ៥ : ចានដល់លាភផល ដែលខ្លួននឹងគប្បីរកចាន
- ៦ : ចានដល់យស និងបុណ្យសក្តិ
- ៧ : ចានដល់កូនប្រុសស្រី
- ៨ : ចានដល់ខ្ញុំកំដរបរិវារ
- ៩ : បើកណ្តាលចាតដែចានដល់អួងចិត្តរបស់មនុស្ស ។

លក្ខណៈបាទទី១

១-បើលក្ខណៈបាទទី១នោះទាប ឬមានស្លាកស្លាម ពិការ ទាយថាអ្នកនោះនឹងកំព្រាមាតាបិតា បើសាច់កំពុងឡើង ទាយថាអ្នកនោះនឹងមានកូនល្អ កូនដំបូងនឹងមានវាសនា បើមានអញ្ជាញដែមួយចាក់ រហូតដល់បាទទី៦ ទាយថា មាតាបិតារបស់អ្នកនោះ ជាអ្នកមានទ្រព្យសម្បត្តិច្រើន បើមានអញ្ជាញដែត្រង់អំពីបាទនេះ ទៅដល់បាទទី៥ ទាយថា មាតាបិតាអ្នកនោះ នឹងត្រូវលំបាក (ឬជាអ្នកក្រពិការ) បើមានអញ្ជាញដែតាំងពីបាទនេះ ត្រង់ឡើងដល់បាទទី៧ ទាយថា អ្នកនោះច្រើនខ្សត់គ្នា, បើមានអញ្ជាញដែតាំងពីបាទនេះ ទទឹងដល់បាទទី៣ ទាយថា អ្នកនោះនឹងត្រូវព្រាត់ចាកទីលំនៅ

ហើយត្រូវទៅអាស្រ័យ នៅក្នុងទិសទីដ៏ទៃ បើក្នុងឋានទី១ នេះមានអញ្ជាញដែទទឹងច្រើន ទាយថា អ្នកនោះនឹង រក្សាសម្បត្តិដើមទុនមិនគង់ឡើយ ។

លក្ខណៈឋានទី២

២-លក្ខណៈឋានទី២ទោះទាប ឬស្លាកស្នាម ពិការ ទាយថាអ្នកនោះនឹងមិនបាន ទទួលទ្រព្យសម្បត្តិមត៌ករបស់ម្តាយ-ឪពុក បើឋាននោះមានសាច់កំពុងខ្ពស់ឡើង ទាយថា អ្នកនោះនឹងបានជំណាងវង្សត្រកូលមាតាបិតា, បើមានអញ្ជាញដែតាំងពីឋាននេះ ចាកត្រង់ទៅ ឋានទី៦ ទាយថា អ្នកនោះនឹងមានបុណ្យ មានទ្រព្យសម្បត្តិច្រើនណាស់ហោង ។ បើ មានអញ្ជាញដែតាំងពីឋាននេះ ឆ្សៀងឡើងដល់ឋានទី៥ ទាយថា មិនល្អ នឹងបង់ទ្រព្យ បើមានអញ្ជាញដែតាំងពីឋាននេះ ឆ្សៀងឡើងទៅដល់ឋានទី៧ ទាយថា នឹងបង់កូន ប្រពន្ធ និងញាតិខាងប្រពន្ធនឹងអន្តរាយ នឹងត្រូវមានគូដល់ទៅពីរបីហោង បើឋានទី២នេះ មានអញ្ជាញដែល្អិតដូចសរសៃសូត្រ ទាយថា អ្នកនោះនឹងបានភោគទ្រព្យនៃលោកអ្នកធំ បើទីនោះមានសរសៃអញ្ជាញត្រង់ តាំងពីដែរហូតទៅមិនដាច់ ទាយថា ល្អណាស់ ទោះជាអ្នកក្រនឹងគង់បានជាអ្នកគ្រាន់បើ នឹងតាំងខ្លួនៗឯងមានវាសនាហោង ។

លក្ខណៈឋានទី៣

៣-ទោះឋានទីនោះទាប ឬមានស្លាកស្នាម ពិការ ទាយថា អ្នកនោះគ្រាំបុងង នឹងចិញ្ចឹមកូនបានដោយក្រ បើមិនដូច្នេះទេ ពួកបងប្អូនច្រើនក្តីរង្គៀសរង្គោលចិត្តគ្នា, បើអញ្ជាញដែតាំងពីឋាននេះ ត្រង់ឡើងទៅដល់ឋានទី៤ ទាយថា អ្នកនោះនឹងបានត វង្សត្រកូលដើមរបស់ខ្លួនហោង ។

លក្ខណៈឋានទី៤

៤-បើឋានទី៤នេះទាបជ្រៃ ឬមានស្លាកស្នាម ពិការ ទាយថាអ្នកនោះអភ័ព្វ, បើឋានទី៤នេះខ្ពស់ មានសាច់កំពុងនឹងបរិបូណ៌គេហដ្ឋាននិងស្រែចំការ, បើឋាននេះមានអព្ជាញ្ជាប្រទាក់គ្នាច្រើន ទាយថា នឹងមានកូនជាអ្នកចិត្តរហ័ស បើមិនដូច្នេះទេ ច្រើនជាអ្នកមានជាតហោង ។

លក្ខណៈឋានទី៥

៥-បើឋានទី៥នេះទាបជ្រៃ ឬមានស្លាកស្នាម ពិការ ដោយប្រការឯណាក្តី ទាយថាអ្នកនោះនឹងសាបសូន្យចាកលាភ, បើមានឋាននេះខ្ពស់កំពុងឡើងសាច់មានឈាមក្រហម ទាយថា អ្នកនោះមានលាភច្រើន, បើសាច់ខ្ពស់កំពុងជាងទីដ៏ទៃល្អណាស់ នឹងមានលាភមកញឹកញាយ នឹងមានបុណ្យតាំងពីកាលនៅតូច បើមានជារូបដូច្នេះ មិនធ្លុះឡើងទៅដល់ម្រាមដៃ ទាយថា អ្នកនោះកំណាញ់ស្វិតស្វាញ មិនមានប្រណីដល់អ្នកណា មានទ្រព្យសម្បត្តិទុកគង់ បើអព្ជាញ្ជាដៃនោះធ្លុះចេញតាមខាងម្រាមដៃ ឬចង្អេកដៃ ទាយថា ទុកទ្រព្យមិនគង់, បើសរសៃខ្មៅផ្ទុះឡើងតាំងឋានទី៥ឆ្សៀងទទឹង ទៅដល់ឋានទី១ ទាយថាអ្នកនោះត្រូវរាសិរពិសខាំហោង ។

លក្ខណៈឋានទី៦

១-បើឋានទី៦នោះ ទាបជ្រៃ ឬមានស្លាកស្នាម ពិការ ទាយថាអ្នកនោះមិនមានយសសក្តិ ច្រើនជាអ្នកថោកទាប, បើឋានទី៦នេះខ្ពស់ឡើង ទាយថា អ្នកនោះនឹង

មានបុណ្យជាធំ បើមានសរសៃពណ៌ខ្មៅ តាំងពីឋានេះត្រង់ចុះទៅដល់ឋានទី២ ទាយថា អ្នកនោះនឹងស្លាប់ដោយការមិនបរិសុទ្ធហោង ។

លក្ខណៈឋានទី៧

៧-បើឋានទី៧នោះទាប ឬមានស្លាកស្នាម ពិការ ទាយថាអ្នកនោះមានអព្ជាញ ដៃប្រទាក់ឆ្វាក់ឆ្វាយឆ្គាមិនល្អ, បើតាំងទីនេះកំពុងខ្ពស់មានសាច់ដូចគេពូនឡើង ទាយថា ចិញ្ចឹមកូនងាយ នឹងមានកូនចៅច្រើន, បើមានអព្ជាញជាជើងក្អែក នៅឋាននេះ ទាយថា ល្អហោង ។

លក្ខណៈឋានទី៨

៨-បើឋានទី៨នេះទាបមិនមានសាច់ ឬមានស្លាកស្នាម ពិការ ទាយថា អ្នក នោះមានខ្ញុំកំដរបរិវារតិច បើទីនេះកំពុងខ្ពស់មានសាច់ដូចគេពូនឡើងមក ទាយថា អ្នកនោះ នឹងបរិបូណ៌ដោយខ្ញុំកំដរប្រុសស្រីហោង ។

ប្រការមួយទៀត លោកពិចារណាក្នុងឋានទី៥ ឋានទី៦ ទី៧ បើក្នុង៣ឋាននេះ ខ្ពស់កំពុងឡើងល្បឿងឆ្គាល្អណាស់ អ្នកនោះនឹងមានបុណ្យប្រសើរពេក ។ បើមានកំពុង ខ្ពស់អំតែមួយកន្លែងនៅឋានទី៧ គឺក្រោមចង្អុលចុះមក ទាយថា អ្នកនោះនឹងមានយសសក្តិ ខ្ពស់បរិបូណ៌ច្រើន បើមានកំពុង ខ្ពស់តែមួយកន្លែងនៅឋានទី៧ គឺក្រោមម្រាមកូនដៃចុះមក ទាយថា អ្នកនោះមានវាសនាល្អណាស់ នឹងបរិបូណ៌គ្រប់ប្រការហោង ។

បើឋានទី៧ ទី៨ មានអព្ជាញដូចខ្វែងជាក់ចៅ $\frac{\perp}{X}$ ដូច្នេះ ទាយថាច្រើន

មានលាភព្រោះស្រី, បើមានអញ្ជាញដែទាក់ខ្វែងធ្វើអោយបែកដាច់ទៅច្រើនធ្វើអោយខាតលាភព្រោះស្រី ។

បើឋានទី៤ មានអញ្ជាញច្រើន នឹងបានគូដែលជាមនុស្សទោសាកាចមាត់រប៉ិលរប៉ូចច្រើន បើមិនដូច្នេះជាមនុស្សច្រើនមានជំងឺហោង ។

បើឋានទី៧ មានអញ្ជាញដែជារូបដើងក្អែក ទាយថា អ្នកនោះនឹងមានលាភខាងផ្លូវអ្នកលង ។ បើដែស្រី ឋានទី៤ នោះខ្ពស់មានសាច់ទន់ល្មើយពណ៌ក្រហមស្រស់ថ្លា ឬមានអញ្ជាញជារង់មូលរៀងគ្នា ឬជារូបត្រា ទាយថា ស្រីនោះនឹងមានបុណ្យច្រើន មានវាសនាអំនាចច្រើនជាងប្រុស, បើឋានទោះទាបត្រែ ឬមានអញ្ជាញដែចាក់ចេញតាមចង្កែកដែ ទាយថា អ្នកនោះនឹងអភ័ព្វ ទុកទ្រព្យមិនគង់ហោង ។

លក្ខណៈឋានទី៩ អណ្តាលចាតដែ

៩-ឋានកណ្តាលចាតដែជាឋានទីសំខាន់ណាស់ ត្រូវនឹងដួងចិត្តរបស់ខ្លួន, បើកណ្តាលចាតដែរាបស្មើ ទាយថា ដួងចិត្តនោះសភាពរាបមិនសូវកង្វល់នឹងអ្វីៗ, បើកណ្តាលចាតដែមានអញ្ជាញត្រង់មិនក្រុងកក្រងក់ អ្នកនោះច្រើនជាអ្នកចិត្តត្រង់, បើកណ្តាលចាតដែមានអញ្ជាញជ្រៅ អ្នកនោះច្រើនជាអ្នកត្រិះរិះជ្រាលជ្រៅ, បើគន្លងរាក់សេចក្តីគិតក៏រាក់ច្រើនជាអ្នកត្រង់ ឬល្ងង់ បើអញ្ជាញទទឹងច្រើន ទឹកចិត្តមិនត្រង់, បើមានអញ្ជាញច្រើនអ្នកនោះនឹងជាអ្នកគិតច្រើន, បើអញ្ជាញដែតិចជាអ្នកគិតតិច, បើអញ្ជាញដែនោះជំពាក់ជំពិន ចិត្តក៏ជំពាក់ជំពិន, បើគន្លងដែនោះជាប់តៗ អ្នកនោះនឹងធ្វើការអ្វីបានងាយ ខួចក៏ងាយ, បើអញ្ជាញដែនោះខ្ជាត់ខាយមិនរួមគ្នា អ្នកនោះជាមនុស្សច្រើនខ្ជិលច្រអូស ។

បើលលក្ខណៈសុខទុក្ខ

បើអ្នកណាមានសម្បុរមុខខ្មៅជាំ តែច្រមុះស្រស់ថ្លា ចាតដៃឡើងឈាមក្រហមឆ្អិនល្អ ទោះបីនឹងទុក្ខ គង់បានសុខវិញហោង ។

បើសម្បុរមុខស្រស់ថ្លា តែច្រមុះស្រអាប់ខ្មៅជាំ ចាតដៃស្ងួតក្រៀមមិនមានឈាម ទោះបីនឹងសុខ ក៏គង់នឹងបានទុក្ខវិញហោង ។

បើស្ត្រីមានគភ៌ ចាតដៃមានឈាមពណ៌ខ្សេរ ក្រហមនៅជានិច្ច បុត្រក្នុងគភ៌នោះជាប្រុស, បើចាតដៃពណ៌ឈាមខ្មៅសនៅជានិច្ច បុត្រក្នុងគភ៌ជាស្ត្រី, បើចាតដៃ មានពណ៌ស្រស់ថ្លានឹងសំរាលងាយ បើស្ងួតក្រៀមនឹងសំរាលពិបាកហោង ។

លក្ខណៈមនុស្សគ្រុន

បើនឹងពិចារណាមើលអាការមនុស្សគ្រុននោះ សូម្បីមនុស្សគ្រុននោះមានរូបកាយស្គាំងស្គមដូចម្តេចក្តី តែម្រាមដៃទាំង១០ មានពណ៌ឈាមក្រហមស្រស់ថ្លា នឹងចុងច្រមុះដ៏ស្រស់ថ្លា ទោះបីមានអាការៈធ្ងន់ក៏មិនជាការអ្វី, បើនៅប្រជុំចិញ្ចើមពណ៌ខ្មៅស្រអាប់ខ្ចង់ច្រមុះពណ៌ខ្សេរ ត្រចៀកសងខាងខ្មៅស្រអំព្រ ដូចមានក្អែលចាប់ ភ្នែកទាំងពីរឈរគង់នឹងមិនរួចរស់បានឡើយ, បើក្រចកដៃទាំង១០ពណ៌ខ្មៅ អញ្ជាញដៃជារូបមឈូសដុះឡើងនៅឋានទី៣ នឹងដល់នៅអនិច្ចកម្មថ្ងៃនោះហោង ។

ឯលក្ខណៈដែលនឹងពិចារណាមើលអញ្ជាញដៃ ដែលមានច្រើនស្ថានដែលត្រូវទាយថា ល្អ និង អាក្រក់ ក៏មានច្រើនប្រការ បើនឹងអធិប្បាយអោយអស់វិធីតម្រាជើម

នោះ ក៏ឃើញថាជាការរញ៉ិមរញ៉ុំហួសកំលាំងនឹងកត់សំគាល់បាន ទើបស្រង់ចំពោះតែការសំខាន់ៗ ដោយសង្ខេបប៉ុណ្ណោះ ។

មើលលក្ខណៈម្រាមដៃ

សិទ្ធិការ្យ : នឹងពោលអំពីលក្ខណៈនៃម្រាមដៃ ដែលល្អ និង អាក្រក់ តាមតម្រាបុរាណ, លក្ខណៈម្រាមដៃដែលល្អនោះ ត្រូវប្រកបដោយលក្ខណៈ៧យ៉ាងគឺ : ១-ម្រាមដៃមូលក្តុំ, ២-ធាត់មានសាច់, ៣-ត្រង់មិនក្តឹកក្តក់, ៤-ម្រាមរៀវស្រួច, ៥-ចង្វែកម្រាមដៃជិតស្និទ្ធមិនមានប្រហោង, ៦-មានពណ៌ឈាមស្រស់ថ្លាមិនមានស្លាក ស្នាម, ៧-មិនផ្សែងផ្សេតទោខាងក្រោយ, ឯលក្ខណៈទាំង៧យ៉ាងនេះ រាប់ថា ជាលក្ខណៈដ៏ល្អ ។

លក្ខណៈនៃម្រាមដៃ ដែលអាក្រក់នោះ ប្រកបដោយលក្ខណៈ៧យ៉ាងគឺ : ១-ផ្សែងផ្សេមិនត្រង់, ២-ក្លៀបសំប៉ែត រឺតូចហួសប្រមាណ, ៣-ក្តឹកក្តក់ ឬខ្លី ហួសប្រមាណ, ៤-ទ្រុងឆតជាជ្រលង ឬស្លាកស្នាមដ៏ធំ, ៥-រូបម្រាមដែងឡើង ឬខុបចុះ, ៦-ចង្វែកដៃឃ្លាតគ្នាមានប្រហោងធ្ងន់ទៅខាងចុងម្រាមស្ថិតដូចក្បាលអង្រែ, ៧-ថ្នាំងម្រាមត្រមោងដូចគ្រាប់ថ្នោក, លក្ខណៈទាំង៧យ៉ាងនេះ ជាលក្ខណៈអាក្រក់ ។

ម្រាមដៃរៀចចេញក្រៅ ទាយថា អ្នកនោះច្រើនព្រាត់ប្រាសចាកទីលំនៅដើម បើមិនដូច្នោះទេ នឹងត្រូវតោកយ៉ាក ពិបាកព្រួយប្រាណ ទៅរកស៊ីនៅទីដ៏ទៃហោង ។

បើម្រាមដៃក្លៀប ទាយថា អ្នកនោះនឹងបង់ទ្រព្យសម្បត្តិហោង ។

បើម្រាមដៃតូចហួសប្រមាណ ទាយថា អ្នកនោះទោះបីនឹងទៅរកស៊ីនៅកន្លែង

ណា នឹងតាំងជាគោលចរិកមាំមួនពុំបានឡើយ ។

បើរឹតតែភ្លៀបហួសប្រមាណទៅទៀត ទាយថា អ្នកនោះបើធ្វើរាជការ នឹងអសារឥតការគ្មានយសសក្តិ, បើជាអ្នករកស៊ីធម្មតា នឹងធ្វើការរកស៊ី ក៏មិនបរិបូណ៌ឡើយ ។

បើម្រាមដៃខ្លីហួសប្រមាណ ទាយថា អភ័ព្វ ច្រើនជាអ្នកទីទាល់ក្រ បើក្រងិកខាងចុង ច្រើនជាអ្នកឆ្មើយឆ្មៃយល់ចាក ត្រូវត្រេកអើរធ្វើការរកស៊ីទៅគ្រប់ទិស ។ បើផតទ្រុឌជាជ្រលង ឬ បែក ទាយថា អ្នកនោះនឹងបង់ទ្រព្យសម្បត្តិដើម ឬជាអភ័ព្វ, បើមានស្លាកស្នាម ទាយថា នឹងបង់លាភ ប្រាថ្នាអ្វីច្រើនមិនសមបំណង បើម្រាមដៃអែន អ្នកនោះនឹងត្រូវប្រសព្វសេចក្តីទំលក់ត្រចំពោះខ្លួនម្នាក់ឯង នឹងពឹងអ្នកណាមិនបានទើសហោង ។

បើម្រាមដៃមានចង្វែកឃ្លាតគ្នា ទាយថា អ្នកនោះទោះបីមានញាតិក៏ច្រើនតែមិនស្រឡាញ់គ្នា, បើចង្វែកម្រាមដៃមិនជិតមានប្រហោងច្រើន ទាយថា អ្នកនោះទុកទ្រព្យមិនតង់, បើម្រាមរឹង ច្រើនអភ័ព្វ, បើថ្នាំងម្រាមកំប៉ោង ឬ ត្រង់កណ្តាលដៃផតដូចអង្រែបុកស្រូវ ទាយថា អ្នកនោះអាយុមិនយឺន, បើសាច់នៅខាងក្រចកនោះឃ្លាត អ្នកនោះក្នុងរវាងកន្លះជាតិ ទុកទ្រព្យមិនតង់ហោង ។

មួយទៀត បណ្តាលម្រាមទាំង៥ លើកម្រាមកូនដៃចេញ បើមានស្លាមអញ្ជាញ ព័ន្ធព័ទ្ធជុំម្រាមកូនដៃដូចសរសៃអំបោះព័ន្ធព័ទ្ធ ទាយថា មិនល្អ បើម្រាមកូនដៃមានស្លាមអញ្ជាញ ដូច្នេះ ទាយថា ល្អណាស់ ។ បើថ្នាំងម្រាមកណ្តាលមានអញ្ជាញប្រទាក់គ្នាជាជើងក្អែក ទាយថា ល្អហោង ។

បើម្រាមទាំង៥ចុងរឹងស្មើគ្នា ទាយថា ជាអភ័ព្វប្រាជ្ញា, បើម្រាមកណ្តាលរឹងស្មើនឹងចាតដៃល្អណាស់, បើម្រាមនោះខ្លីជាងចាតដៃ មិនល្អ, បើរឹងជាង ល្អណាស់ហោង

មួយទៀត ម្រាមកូនដៃ វាស់នឹងម្រាមមេដៃ បើវែងស្មើគ្នា ល្អណាស់, បើមេដៃវែងជាងក៏ល្អដែរ, បើម្រាមកូនដៃវែងជាងម្រាមដៃទាយថា បិតា ឬមាតាអ្នកនោះមិនមែនជាអ្នកមានត្រកូលខ្ពង់ខ្ពស់ប៉ុន្មានទេ បើម្រាមកូនដៃវែងជាងចង្អុលដៃ ទាយថាអ្នកនោះវល់អាយុច្រើនហើយ ទើបមានកូន កាលពីអាយុតិច ទ្រព្យសម្បត្តិបរិបូណ៌ វល់អាយុច្រើននឹងបានពីងកូន, បើម្រាមកូនដៃ និងម្រាមចង្អុលដៃខ្ចី ឬវែងស្មើគ្នាល្អ នឹងមានលាភញឹកញាប់ ។ បើម្រាមកូនដៃ និងម្រាមកណ្តាលខ្ចី ឬវែងស្មើគ្នា នឹងមានទ្រព្យច្រើន ហើយនិងបានកូនល្អ, បើម្រាមកូនដៃ និងនាងដៃខ្ចី ឬវែងស្មើគ្នា អ្នកនោះជាមនុស្សឆ្លាវឆ្លាតណាស់ នឹងមានបុណ្យសក្តិ នឹងបានទីពឹងហោង ។

មួយទៀត, បើម្រាមដៃផ្សែងទ្រេតមិនត្រង់ ទាយថា អ្នកនោះនឹងត្រូវធ្សើយព្រួយធ្វើការច្រើនតែមិនសំរេច, បើម្រាមកណ្តាលភ្លែងមិនត្រង់ ទាយថា អ្នកនោះមានទិដ្ឋិមានៈច្រើនប្រកាន់យកតែតាមចិត្តខ្លួន, បើម្រាមនាងដៃភ្លែងមិនត្រង់ ទាយថា អ្នកនោះនឹងមានកូន ដែលជាអ្នកប្រកាន់ទិដ្ឋិមានៈច្រើន, បើម្រាមកូនដៃផ្សែងមិនត្រង់ ទាយថា អ្នកនោះខ្សត់កូន ទោះបីនឹងមានក៏ត្រូវបែងទីលំនៅ នៅដោយខ្លួន, បើម្រាមចង្អុលដៃធំជាងម្រាមទាំងអស់ នឹងមានទ្រព្យច្រើន ទាំងនឹងបានតំណែងត្រកូលរបស់ខ្លួន អាយុក៏យឺនយូរហោង ។ បើម្រាមចង្អុលដៃខ្ចី ច្រើនខ្សត់ប្រពន្ធ, បើមិនដូច្នេះទេ ច្រើនខ្លាចប្រពន្ធណាស់ហោង។

មួយទៀត បើមនុស្សខ្ពស់ ម្រាមដៃខ្ចី ទាយថា ពិបាក មិនល្អ, បើមនុស្សទាប ម្រាមដៃវែង ចិត្តអ្នកនោះលោភលន់ បើគល់ម្រាមចង្អែកដៃឃ្លាតគ្នា ទុកទ្រព្យមិនគង់, បើចង្អែកខាងចុងឃ្លាតគ្នា នឹងពីងញាតិមិនបានឡើយ, បើចុងម្រាមដៃត្រមុះដូចអង្រែ អ្នកនោះនឹងត្រូវធ្សើយច្រើន ទាំងអាយុក៏មិនយឺនយូរ, បើម្រាមដៃរៀវដូចទំពាំង

ប្ញស្សី ដែលទើបនឹងដុះនឹងមានទ្រព្យ, បើម្រាមកូនដៃ និងម្រាមនាងថ្នាំងក្រោមស្មើគ្នា ទាយថា អ្នកនោះធ្វើការរាជការនឹងបានជានាហ្នឹនដោះចំណេះវិជ្ជា, បើម្រាមមេដៃ និង ម្រាមចង្អុលថ្នាំងក្រោមស្មើគ្នា ទាយថា អ្នកនោះបើធ្វើជារាជការ នឹងបានជានាហ្នឹន ខាងទាហាន ។

មួយទៀត, ម្រាមត្រូវជើងជាងចាតដៃ ទើបល្អ, បើចាតដៃ ជើងជាងម្រាមដៃ ទាយថា អ្នកនោះច្រើនត្រូវអ្នកផងមើលងាយ ប្រមាថនិន្ទា,បើម្រាមចង្អុលជើង ទាយ ថា អ្នកនោះចូលចិត្តសេពគប់នឹងអ្នកមានបណ្តាសក្តិ, បើម្រាមនាងដែជើង ទាយថា អ្នកនោះ ស្រឡាញ់អ្នកណាមិនស្មោះចំពោះនឹងអ្នកនោះ ចិត្តច្រើនរបើយរវាយ ។

ប្រការ១ ម្រាមទាំង៥ បើម្រាមឯណានិមួយមានភិន ឬមានស្លាកស្នាមពិការ ដូចម្តេចក្តី ក៏អោយទោសបានដែរ ។ បើម្រាមមេដែមានស្លាកស្នាមពិការ ទាយថា អ្នក នោះខ្សត់ញាតិអ្នកចំ ។ បើម្រាអកណ្តាលមានស្នាមពិការ ទាយថា អ្នកនោះនឹងខ្សត់ បុត្រហោង ។

អធិប្បាយលក្ខណៈនៃម្រាមទាំង៥

១-ម្រាមមេដែនោះបែកចេញជាពីរកំណាត់, បើនៅថ្នាំងម្រាមមេដែនោះមានស្នាម អញ្ជាញទទឹងប្រទាក់គ្នា ទាយថា បិតានឹងស្លាប់មុន , បើថ្នាំងម្រាមមេដែនោះ មាន ស្នាមអញ្ជាញដូចដាវជើង ទាយថា មាតានឹងស្លាប់មុនហោង ។

២-គឺម្រាមចង្អុល, ម្រាមចង្អុលនេះក៏ជាម្រាមមួយដ៏សំខាន់ ម្រាមចង្អុលនោះត្រូវ អោយរលឹងមូលក្តុំ ហើយត្រង់ឃ្យរទើបល្អ កុំអោយមានឃ្យែចវៃ ឬក្បៀបតូចខ្លីផតទ្រុឌ

ជ្រលងជាស្ពាកស្ពាម បើមានភាពដូច្នោះហើយជាហីនលក្ខណ៍មិនបរិបូណ៌ ។ មួយទៀត បើម្រាមចង្អុលនោះផ្សែងជ្រេចេញទៅខាងក្រៅ ឃ្លាតពីម្រាមកណ្តាល ទាយថា អ្នកនោះ នឹងបានសេចក្តីតោកយ៉ាកលំបាក បើផ្សែងជ្រេចូលទៅខាងក្នុងជិតម្រាមកណ្តាល ទាយថា អ្នកនោះ ទោះបីមានទ្រព្យសម្បត្តិល្មមនឹងចាយវាយគ្រប់គ្រាន់ ក៏ត្រូវនឿយព្រួយដើរគ្រប ទៅគ្រប់ទិស, បើម្រាមចង្អុលនោះតូចជាងម្រាមដៃ តែនឹងរកស៊ីបានដោយក្រ រកទីនៅ អាស្រ័យបានដោយពិបាក, បើម្រាមចង្អុលនោះក្បៀប នឹងបានសេចក្តីតោកយ៉ាកលំបាក ណាស់, បើខ្លីហួសខ្នាតនឹងខ្សត់ធ្ង បើមិនដូច្នេះទេ នឹងខ្លាចប្រពន្ធ ទ្រព្យសម្បត្តិក៏នឹង មានតែល្មមប្រមាណ, បើក្តិកនឹងត្រូវលំបាក ទៅរកស៊ីគ្រប់ទិស បើទ្រុឌរខិញរខុញ ច្រើនតែកំព្រានៅតែម្នាក់ឯង, បើមានស្ពាកស្ពាម ច្រើនធ្វើការអ្វីមិនសំរេច, លក្ខណៈ ទាំង៨យ៉ាងនេះ ជាលក្ខណៈដ៏អាក្រក់នៃម្រាមចង្អុលហោង ។

៣-គឺម្រាមដៃកណ្តាល ម្រាមកណ្តាលជាម្រាមសំខាន់ណាស់ នឹងមើលលក្ខណៈ នៃបុគ្គល ក៏ត្រូវមើលម្រាមកណ្តាលនេះ តែម្រាមនេះត្រូវអោយត្រង់ទើបល្អ បើខ្លីជាង បាតដៃ មិនល្អឡើយ គង់នឹងទៅជាអ្នកទីទ័ល ហើយជាអ្នកកំព្រាផង, បើវែងជាង បាតដៃទើបល្អ ។ បើមានតូចខ្លៅផង ទោះនឹងធ្វើការអ្វីច្រើនតែមិនសំរេច ម្រាមនេះ ត្រូវអោយមានពណ៌ឈាម ស្រស់ថ្លាទើបល្អ បើមានអញ្ជាញដូចសរសៃអចោះ ព័ន្ធព័ទ្ធ វង់ជុំម្រាមដៃ ទាយថា អ្នកនោះ ទោះបីនឹងមានសេចក្តីសុខ ហើយក៏ច្រើនតែមាន សេចក្តីភិតភ័យតក់ស្លុត ហើយនឹងមានគ្រោះថ្នាក់មករុំអុកជាញឹកញយ, បើម្រាមនោះ ផ្សែងទ្រេតមិនត្រង់ ទាយថា មិនល្អឡើយ ។

៤-គឺម្រាមនាងដៃ ម្រាមនេះជាទីសង្កេតនៃបងប្អូនកូនប្រពន្ធ និងវង្សាគណាញាតិ ហើយនិងជីវិតជីវា, តាំងពីអាយុ៤០ឡើងទៅខាងមុខ ថើម្លើងមិនរែបជិតនឹងម្រាមកណ្តាល ទាយថា បងប្អូនច្រើនទាស់អធ្យាស្រ័យគ្នា, ហើមិនដូច្នេះទេ ច្រើនខ្សត់គ្នា, ថើពណិសម្បុរផូរផង់ មិនមានស្លាកស្នាមទើបល្អ, ថើថ្នាំងម្រាមនោះមានអញ្ជាញដូចសារសែអំបោះពំនូតជុំវិញម្រាម មិនល្អ, ថើចង្កែកម្រាមនោះមិនមានប្រហោងធ្លុះ ទាយថាអ្នកនោះមានទ្រព្យបរិបូណ៌ក្នុងវ័យចាស់ជរាម្តងទៀត ពិតប្រាកដណាស់ហោង ។

៥-គឺម្រាមកូនដៃ ម្រាមកូនដៃនេះ ត្រូវដែងរៀវកុំអោយម្លើងខ្លែត ទើបល្អ ឬម្រាមនេះខ្លី តែកុងស្រួចមិនស្អីត ក៏ជាលក្ខណៈដ៏ល្អ, ថើម្រាមនេះ មានអញ្ជាញដូចវង់អំបោះពំនូតជុំវិញម្រាមល្អណាស់ នឹងមានអាយុយឺនយូរ, ថើម្រាមដ៏ទៃមានអញ្ជាញដូច្នេះមិនល្អឡើយ, ថើចុងម្រាមកូនតូចជាងម្រាមនាងដៃ ទាយថា អ្នកនោះនឹងមានបញ្ញាធ្វើជាជាងមានថ្វីដៃល្អ តែនឹងត្រូវអភ័ព្វបន្តិចបន្តួចហោង ។

លក្ខណៈគូថខ្លៅចំ៨

ម្រាមដៃទាំង១០ ថើមានគូថខ្លៅគ្រប់ទាំង១០ ទាយថា ប្រសើរណាស់ នឹងមានបុណ្យ, ថើមានតែម្រាម១ ក៏ល្អ នឹងមានទ្រព្យច្រើន, ថើមាន២ ទាយថាឡើយច្រើន ហើយជាអ្នកចូលចិត្តដើរ, ថើមាន៣ ឬ ៥ ល្អតិច អាក្រក់ច្រើន, ថើមាន៦, ៧ មិនល្អ, ថើមាន៨ គ្រាន់ថើ, ថើមាន៩ ល្អហោង ។

មើលលក្ខណៈក្រចក

សិទ្ធិការ្យ : នឹងពោលអំពីលក្ខណៈក្រចកដែ ដែលល្អ និង អាក្រក់ ក្រចក នោះជារបស់ជាប់មកអំពីឆ្អឹង ជាទីអោយសង្កេតដួងចិត្តរបស់បុគ្គល, បើអ្នកណាមាន ក្រចកវែងមុត អ្នកនោះទឹកចិត្តជាអ្នកប្រកាន់ឫកខ្ពស់ ជាមនុស្សចិត្តក្លាហាន ធ្វើការមិន រុញរា, បើអ្នកណាក្រចកនោះខ្លីទន់ អ្នកនោះចូលចិត្តខ្លាចគិតតែល្មមប្រមាណខ្លួន ជាអ្នក ចិត្តទន់ ធ្វើការច្រើនមិនសំរេច បើក្រចកស្រួចមុត ជាអ្នកវាយឫកខ្ពស់ ចង់បានមិនចេះ ស្កប់, បើក្រចកវែង ចិត្តក្លាហាន ធ្វើការអ្វីចត្តក្តៅដូចភ្លើង, ក្រចកទន់ធ្វើការច្រើនខ្ជិល ច្រអូស បើរៀនចំណេះវិជ្ជាវិញ ច្រើនវង្វេងភ្លាំងភ្លេច, ធ្វើការបានខាងដើមខូចខាងចុង បើក្រចកនោះរឹងស្រួចជាមនុស្សមានបញ្ញាច្រើន, បើក្រចកនោះក្រាស់រឹង នឹងមានអាយុ យឺនយូរ, បើក្រចកទាលគគ្រាត ជាមនុស្សល្ងង់ខ្លៅ, បើក្រចកនោះរិលបេចពុកស្លួយ ជាមនុស្សច្រើនមាន, បើក្រចកពណ៌ស៊ីឆ្ងាយឆ្លុះស្រមោលអ្នកនោះនឹងមានបុណ្យ, បើពណ៌ ខ្មៅហើយស្តើង ជាមនុស្សអ្នកទាបតូច (ឆុនអន់) បើក្រចកមានពណ៌ថ្លាឆ្លុះស្រមោល អ្នកនោះមានទឹកចិត្តខ្សោងក្រង់, បើក្រចកនោះពណ៌ស្អាត ជាអ្នកមានធុរៈតិច, បើក្រចក នោះមានរូបដូចបំពង់ពុះមួយចំហៀង ជាអ្នកមានថ្វីដៃល្អខាងការជាង បើរូបក្រចកនោះ ដូចសំបកឌុំឡឹក ដែលពុះមួយចំហៀង គឺមានចុងក្រងុក អ្នកនោះធ្វើការអ្វី ច្រើនមិនបាន សំរេច, បើក្រចកក្រាស់ អាយុយឺន, បើក្រចកស្តើង អាយុខ្លី, បើក្រចក ស្រួចមាន បញ្ញា, បើក្រចកបែក មិនល្អ, បើក្រចកស្រស់ថ្លា នឹងបរិបូណ៌ទ្រព្យសម្បត្តិ ណាស់ ហោង ។

លក្ខណៈប្រជ្រុយរបស់បុរស



១-បុរសណាមានប្រជ្រុយត្រង់ស្បែតផ្ការខាងស្តាំ ជាមនុស្សកំណាញ់ស្វិត បើនិយាយស្តីអ្វីបែបផែនអ្នកធំ មានមនុស្សកោតក្រែងរាប់អានច្រើន ហើយជាអ្នកមានទ្រព្យសម្បត្តិផង ។

២-បុរសណាមានប្រជ្រុយក្រោមរោមចិញ្ចើមខាងស្តាំ ជាមនុស្សមានរាសីថោកនឹងនិយាយការអ្វីៗ ច្រើនតែទំនាស់ចិត្តនៃអ្នកផង ហើយគេពុំសូវស្គាល់គេច្រើនធុញទ្រាន់

៣-បុរសណាមានប្រជ្រុយនៅថ្ងាសខាងស្តាំ ជាមនុស្សចិត្តក្លាហាន បើធ្វើអ្វីៗ ចង់អោយតែបានល្បីឈ្មោះ សេចក្តីប៉ងអ្វីក៏បានសំរេចដូចចិត្តប្រាថ្នាមែន ។

៤-បុរសណាមានប្រជ្រុយចំភ្លោងច្រមុះ ជាមនុស្សឫកជតាធ្លាក់ ច្រើនតែមានល្បិងរ៉ាវ ហើយយកល្បិងរ៉ាវទាំងនោះមករក្សាទុកជាក់ក្នុងខ្លួនជានិច្ច ។

៥-បុរសណាមានប្រជ្រុយនៅថ្ពាល់ខាងឆ្វេង (ក្បែរភីមបបូរមាត់) ជាមនុស្សមានកម្មក្រាស់ ច្រើនតែស្លាប់ក្នុងទឹក ឬក៏ស្លាប់ដោយហេតុណាមួយ ត្រូវប្រយ័ត្នខ្លួនឱ្យណាស់

៦-បុរសណាមានប្រជ្រុយនៅចន្លោះថ្ងាសខាងស្តាំ ឬខាងឆ្វេងជាមនុស្សអភ័ព្វកំព្រាឪពុកតាំងពីតូចមក ត្រូវចិញ្ចឹមជីវិតដោយខ្លួនឯងលំបាកណាស់ ។

៧-បុរសណាមានប្រជ្រុយនៅត្រង់កណ្តាលថ្ងាស អោយចូលទៅរកអ្នកចំសប្បុរសនឹងពីងអ្វីៗ អ្នកចំនោះនឹងអោយបុណ្យសក្តិ នឹងអោយលាភជាទីគាប់ចិត្ត ។

៨-បុរសណាមានប្រជ្រុយនៅថ្ពាល់ខាងឆ្វេង ឬខាងស្តាំ ជាមនុស្សមោហោកាចណាស់ ចិត្តហ៊ានសម្លាប់មនុស្សបាន, បើនឹងមានកូន ពឹងកូនក៏មិនបាន ហើយចិញ្ចឹមកូនល្មមតែធំ កូនដើរចោល ឬស្លាប់ចោលអស់ ។

៩-បុរសណាមានប្រជ្រុយនៅថ្ងាសខាងឆ្វេង ជាមនុស្សមានទ្រព្យសម្បត្តិច្រើន, បើនឹងនិយាយស្តីមានគេជឿច្រើន មានមនុស្សកោតក្រែងរាប់អានច្រើន ។

១០-បុរសណាមានប្រជ្រុយនៅត្រង់ក្រោមរោមចិញ្ចើមខាងឆ្វេង ជាមនុស្សអាប់រាសី បើនឹងគិតការអ្វីៗ ដូចគេអុំទូកក្នុងអាង ហើយកាន់ខ្លួនជាអ្នកចំផង ។

១១-បុរសណាមានប្រជ្រុយនៅត្រង់ចន្លោះប្រជុំចីញ្ចើម ទឹកមុខល្មមជាមហាស្នេហ៍ នឹងហាមាត់ទៅពីងពាក់អ្នកណា គេក៏ជួយបានដោយងាយ ហើយរកលាភក៏បានងាយ

ហើយបានដោយគន្លងធម៌ផង ។

១២-បុរសណាមានប្រជ្រុយនៅថ្ពាល់ខាងស្តាំ ត្រូវរកបង់មាត់ខ្លួនឯង ធ្វើការបែកញើសតាងជាទឹកក៏ពុំគ្រប់គ្រាន់ ទំនាយថាលំបាកណាស់ ។

១៣-បុរសណាមានប្រជ្រុយនៅត្រង់ទងត្រចៀកខាងក្រោមស្តាំក៏ដោយ ឆ្វេងក៏ដោយ ជាមនុស្សឆ្លៀវឆ្លាស មានសតិបញ្ញាច្រើន ហើយជាអ្នកមានកតញ្ញូឈ្មោះណាស់ ។

១៤-បុរសណាមានប្រជ្រុយនៅត្រង់ត្រចៀកខាងលើស្តាំ ឬឆ្វេង ច្រើនមានមនុស្សឆ្លាយនាំលាភមកអោយ ហើយនឹងមានអ្នកធំ ច្រើនអោយទ្រព្យសម្បត្តិ ជួយឧបការដល់ខ្លួនផង ហើយអាយុវែង ។

១៥-បុរសណាមានប្រជ្រុយនៅត្រង់កខាងស្តាំ ជាអ្នកមានមហាជោគជ័យ នឹងមានយសសក្តិ ជួយឧបត្ថម្ភអោយបានល្អ ពុំនោះសោតអ្នកធំនឹងចែកទ្រព្យអោយ ។

១៦-បុរសណាមានប្រជ្រុយនៅត្រង់ចំបំពង់ក នឹងមានលាភយសសក្តិ តែប្រយ័ត្នថានឹងមានមនុស្សឫស្យាអាក្រក់ នឹងអោយទោស ។

១៧-បុរសណាមានប្រជ្រុយនៅត្រង់កខាងឆ្វេង ជាមនុស្សមានចិត្តទូលាយ បើរកសម្បត្តិទ្រព្យអ្វី ក៏កើតឡើងដោយខ្លួនឯង ឥតមានពឹងអ្នកណាទេ ។

១៨-បុរសណាមានប្រជ្រុយជិតភ្នែក (ខាងក្រោម) ចូរប្រយ័ត្នខ្លួនអោយណាស់ បើនឹងធ្វើអោយមានឫកពារទន់ភ្លន់ ក៏នៅតែគេមើលមកថាមិនល្អ ហើយជាមនុស្សរាសីធ្លាក់ បើធ្វើគុណនឹងអ្នកណា អ្នកនោះក៏ពុំអោយផលឡើយ ។

លក្ខណៈប្រជ្រុយរបស់ស្ត្រី



១-ស្ត្រីណាមានប្រជ្រុយនៅស្បែតផ្ដាខាងឆ្វេង ឬ ខាងស្ដាំ ជាស្ត្រីច្រើនគិតក្រៅអំពីស្វាមី ហើយមានចិត្តក្បត់នឹងស្វាមីជានិច្ច ។

២-ស្ត្រីណាមានប្រជ្រុយនៅថ្ងាស បានប្ដីនឹងរាច់ឆ្នាក្នុងរវាង៥ខែ ឬយូរទៅនៅរួមផ្ទា ដល់មានកូនវ៉ោះក៏ពុំគង់ផែរ ។

៣-ស្ត្រីណាមានប្រជ្រុយនៅចន្លោះចិញ្ចើម ស្ត្រីនោះគ្មានបញ្ញាត្រូវពីងអ្នកដ៏ទៃ, ញាតិបងប្អូនគ្មានគេចូលចិត្ត ហើយជាមនុស្សគ្មានកូនផង, បើមានក៏ចិញ្ចឹមពុំរស់ដែរ ។

៤-ស្ត្រីណាមានប្រជ្រុយនៅត្រង់ត្រចៀកខាងស្តាំ ជាមនុស្សអាណោបអាណាបចេះគួរសម ទៅណាមកណា មានជនជាតិទាំងឮងរាប់អានច្រើន ហើយជាអ្នកមានកតញ្ញូផង

៥-ស្ត្រីណាមានប្រជ្រុយនៅច្រមុះ ជាមនុស្សខឹងច្រើនប្រកាន់ថាល្អតែខ្លួនឯង មិនយកតម្រាប់អ្នកដ៏ទៃ ។

៦-ស្ត្រីណាមានប្រជ្រុយនៅរឹមមាត់ខាងលើ ជាមនុស្សពាល មាត់អាក្រក់ ចូលចិត្តរកឃើង នាំអោយរំខានដឹងគ្នាឯងក្នុងផ្ទះជានិច្ច, បើនៅដឹងអ្នកឯណាក៏ពុំបានឈ្មួរ បើដឹងមានប្តីលែងគ្នាញយៗ ច្រើនធ្វើឫក្សជាស្ត្រីផ្តាមាសផង ។

៧-ស្ត្រីណាមានប្រជ្រុយនៅដើមភ្នែកខាងក្រោមខាងស្តាំ ឬ ខាងឆ្វេង ជាស្រីខាតលក្ខណ៍ ខាតថង់ ក្នុងចិត្តមានសេចក្តីក្តៅក្រហាយ ច្រើនធ្វើអោយទឹកភ្នែកហូរជាប់ជានិច្ច ។

៨-ស្ត្រីណាមានប្រជ្រុយនៅត្រង់ត្រចៀកឆ្វេង នាងនោះជាស្រីអ្នកមានបញ្ញាដ៏ស្រួចប្រសើរ, បើមានប្តីៗនោះនឹងបានអ្នកធំ ។

៩-ស្ត្រីណាមានប្រជ្រុយលើចិញ្ចើមខាងស្តាំ ឬ ខាងឆ្វេង ជាមនុស្សអភ័ព្វ ច្រើនពោលអួតថា ខ្លួនឯងល្អលើសគេ ថាគេអាក្រក់ជាងខ្លួន ។

១០-ស្ត្រីណាមានប្រជ្រុយនៅត្រង់បំពង់ក ជាមនុស្សមានចិត្តជាចោរ, បើមានសេចក្តីក្រេវក្រោធហើយ ប្តីរបស់ខ្លួនក៏ហ៊ានសំលាប់ចោលដែរ ។

១១-ស្ត្រីណាមានប្រជ្រុយនៅកខាងឆ្វេង ជាមនុស្សអភ័ព្វ ធ្វើគុណនឹងគេមិនបាន

បើធ្វើគុណអ្នកណា ច្រើនអ្នកនោះឯងអោយទោសច្រើន ស៊ូនៅម្នាក់ឯងល្អជាង ។

១២-ស្ត្រីណាមានប្រជ្រុយនៅដើមកខាងស្តាំ ជាមនុស្សមានស្នេហ៍ក្នុងខ្លួន ទៅកាន់ទីណាមានគេរាប់អាន ហើយគេថាស្ត្រីនោះមានកិរិយាល្អ ហើយជាមនុស្សមានវាសនាច្រើន, បើនឹងមានប្តីៗនោះឯងនឹងបានទៅជាអ្នកធំ ។

១៣-ស្ត្រីណាមានប្រជ្រុយនៅរឹមមាត់ខាងក្រោម ជាមនុស្សអភ័ព្វ ស៊ីមិនពេញពោះ, បើនឹងចេញទៅពឹងអ្នកដ៏ទៃបានដោយកំរ ត្រូវអោយខ្លួនទីពឹងខ្លួន ។

១៤-ស្ត្រីណាមានប្រជ្រុយនៅក្រោមដោះ ជាអហាស្នេហ៍ល្អណាស់ ច្រើនមនុស្សជិតឆ្ងាយនាំលាភមកអោយជានិច្ច ហើយមានបរិវារច្រើន ។

១៥-ស្ត្រីណាមានប្រជ្រុយនៅឋិតក្នុងទីកំចាំង នឹងល្បីឈ្មោះមានយសសក្តិ ហើយនឹងមានទ្រព្យច្រើន, បើមានស្វាមីៗនោះនឹងបានជាអ្នកធំ, បើមានកូនៗនោះនឹងមានបុណ្យយសសក្តិដ៏ខ្ពង់ខ្ពស់ ។

(បើប្រសិនណា បុរស-ស្ត្រីណា មានប្រជ្រុយខុសពីតម្រានេះបន្តិចបន្តួច លោកទុកជាមធ្យម) ។

ក្បួនសម្គ្រោះ

អោយលេខ១ទៅដល់លេខ៧ លុះដល់អាលុយើងប៊ុន្មានទៅលើលេខអ្វី អោយមើលតាមសម្លាក[1] ខាងក្រោមនេះ ។

១ ២ ៣ ៤ ៥ ៦ ៧

១-សេស១ មានគ្រោះចំពោះជាក់ក្រែងរាពណ៍ចាញ់ព្រះរាម លក្ខណ៍បង់ទីហាន ។

២-សេស២ សិតារ័តន៍កល្យាណ ប្រុសស្រីនឹងបានបុត្រកវិយា ។

៣-សេស៣ ក្របីអយ្យរាបុត្រ ក្រឡាលុតជើជំនកទិដ្ឋាន ពិតស្រេច ទើបស្តេចចរយាត្រា លីលារស្មីឆ្ពិនឆ្ពៅ ។

៤-សេស៤ នាកាលព្រះភូមិន្ទ្រ ស្តេចបានខះខឹម នគរធើតឆាយ ។

៥-សេស៥ ពិភេតបង់នគរឆ្ងាយ បង់បុត្របុញ្ញកាយខ្លួនចេញចរ ។

៦-សេស៦ នាកាលអនុថា ចេញធ្វើចរិយាចិត្តស្មោះ មានយក្ខិនីស្រីមេម៉ាយរូបល្អ ចង់បានភូចរធ្វើជាស្វាមិ ។

៧-សេស៧ នាកាលបុត្រប្រពៃណី ចាប់បានដួងចៃរាពណ៍នោះណាច្រចាច់ច្របល់ក្នុងហត្ថា លុះរាពណ៍មរណាក្សិណក្សយទៅ ។

១-សម្លាក ឬ សំណាក (មើលថាសំលោក) ន.ពាក្យថា ស្លាក, ប្រើចំពោះតែពាក្យរៀបសំរាប់ទាយលក្ខណៈមនុស្ស ឬ សត្វដូចឧទាហរណ៍ថា ជើងទិញធ្មេញល្អិត ស្តិកត្រចៀកកំប៉ិត ដំណើរប៉ែលឆៅល ។

ក្បួនរជ្ជគ្រោះ

(ជោគជំរិ)



អោយលេខ១ ទៅរៀលលេខ៨ ដល់គ្រប់អាយុ បើនៅលើលេខអ្វីអោយមើលតាមសម្គាកខាងក្រោមនេះចុះ ។

១	២	៣	៤	៥	៦	៧	៨

១-អាទិត្យ នៅប្រមោយហត្ថា មានលាភសព្វប្រការ អ្នកកល់ប្រក្រតី បើថ្កាត់ព្រោះតែចំណិ ព្រាយគ្រូនោះបំណងតែធ្វើ ។

២-ច័ន្ទ នៅលិនគុជសា មានមិត្តសង្ឃារ ស្រឡាញ់គាប់ចិត្ត បើថ្កាត់ថាមេបាធ្វើ

៣-អង្គារ បិតនៅបាទា ទោះចរយាត្រាទៅឆ្ងាយពុំបាន បើថ្កាត់ព្រោះតែចាកឋាន ទោសនោះ សឹងមានអារក្សក្នុងផ្ទះឯងធ្វើ ។

៤-ពុធ បិតនៅតែកន្ទុយ បើធ្វើគុណនឹងគេ ពុំបាន សឹងកើតទោស ។

៥-ព្រហស្បតិ៍ នៅវង់កាចា ឮពាក្យគេថា ប្រសើរពេកក្រែ ។

៦-សុក្រ នៅកញ្ឆោងពីជី មានលាភអំពីព្រះមហាក្សត្រអោយ ។

៧-សៅរ៍ បិតនៅជើងក្រោយ ប្រយ័ត្នកុំឆ្គោយ ក្រែងត្រូវចំណង បើថ្កាត់គ្រោះ កាចណាស់ហោង ថ្កាត់ខ្លួនឯងផង កុំបីប្រយែសឡើយណា ។

៨-រាហ៊ូ នៅនាភ្លុកហោង ឈ្នះអស់សត្រូវ ប្បែងប្បែងពុំបាន ។

ក្បួនឧទ្ធគ្រោះ

សំរាប់បុរស-ស្ត្រី មើលគ្រោះថ្នាក់ អោយរាប់ពីលេខ៧ ដល់លេខ២ អោយទាល់តែគ្រប់អាយុ បើនៅលើលេខអ្វី អោយមើលតាមសម្តែកដូចខាងក្រោមនេះ

៧ ៤ ៣ ៨ ៥ ៦ ៩ ១ ២

៧-សៅរ៍ អស្សុមុខី ជើរទេសរកប្តី ចែងចារម្តក្រមក្រែ ។

៤-ពុធ នៅលើធន្តន្តរសាណុផ្ករ ចាញ់ដកយកកន្ទុយ និង ភ្លុកទាំងអំណាច ។

៣-អង្គារ ពោធិតិមេ ចេញពីក្រឡាព្រះបន្ទំ ។

៨-រាហ៊ុ នៅនាមោគ្គល្លាន ចោរដំអស់គ្រាណ ដូចគេបែនបុក ។

៥-ព្រហស្បតិ នៅលើពុធិសែន ឧនោចតមន្ត្រ បង់នាងកង្រី ។

៦-សុក្រ នៅលើសក្កវាជ លះលែងអស់ពាក្យ បង់នាងបច្ចាវតី ។

៩-កេតុ នៅលើព្រះអនុរុទ្ធ ព្រាជ្ញាមោះមុត សំដែងព្រះធម៌ទេសនា ព្រះឥន្ទស្តាប់ហើយបូជា នាងទេពធីតា ថ្វាត់ថ្វាយផ្កាផង ។

១-អាទិត្យ ក្រុងរាពណ៌ឫទ្ធីសំត្តិបរាជ័យជាក់ កណ្តាលសង្គ្រាមរឿនរង្គ ។

២-ចន្ទ ព្រះជិនកម្រើសទ្រង់ ធ្លាយសំពៅក្នុងកណ្តាលសមុទ្រសាគរ នាងទេពធីតាបវរ នាំព្រះកុមរដំកល់ដាក់ត្រើយត្រាណ ព្រះអង្គបរិបូណ៌ក្សេមក្សាន្ត ឈ្មួលង់ទៅបានសោយរាជ្យនគរពីរហោង ។

សម្លោកនាមសត្វនៃឆ្នាំទាំង១២

ឆ្នាំជូតកណ្តុរជាដើមទៅ, ឆ្នាំឆ្លូវនាមគោឧសុភរាជ, ឆ្នាំខាលនាមខ្លាខ្លាំងឥតមេះ, ឆ្នាំថោះទន្សាយសម្ងួចលាជ, ឆ្នាំរោងឈោងនាមនាគរាជ, ម្សាញ់ឯងអាចនាមពស់ជែក ។ មមីបានទីប្រាក់ពីរតត់ សង្ឃតនាមសេះ ជាសត្វឯក, មមែពពែពិតពុំប្លែក, ឆ្នាំវក់អតិឯក ដោយពានរ ឆ្នាំវករាប់មកឆ្នាំរកា សញ្ញានាមមាន់ចេះបវរ កំណត់នាមសត្វក្នុងឆ្នាំចរ គឺឆ្កែឆ្មៅសេដង្ហែគ្នា ឆ្នាំកុរនាមជ្រូកលោកបញ្ចប់ ជាពីរដណ្តប់ ដោកពណ៌នាថាហែកុមារ ទាំងអស់គ្នា ចាំទុកបានជាប្រយោជន៍អើយ ! ។

សម្លោកទាយជំណើរមនុស្ស

សិទ្ធិការ្យ : ពោលថា វីមនុស្សថ្កាមខ្លាចង្កាខ្ចី
ជង្គង់ដូចសេកភ្នែកមាន់ព្រៃ ដំណើរអើរសំរិលល្អ ។
រាងធំកំចោងក្តោងសំពោធ ម្រាមដៃដូចទោចនោះច្រើនក្រ
មុខក្រោយថ្កាមក្រាញ់ច្រើនធ្វើចោរ មាត់សេកភ្នែកសក្រវល់ចាស ។
វីមនុស្សខ្លួនខ្ចីសំជីខ្ពស់ រាងទាបក្រអុសច្រើនអួតណាស់
មុខស្រស់ពព្រឹមចិញ្ចើមក្រាស់ ច្រើនចេះច្បាប់ណាស់លះសេចក្តី។
វីក្បាលទំពែកភ្នែកដូចស្វា ចិញ្ចើមដូចខ្លាច្រាផ្តាខ្ចី
មុខខ្លាញ់ភ្នែកខ្លោតអួតសំជី ឥតបីអ្នកណានឹងចានដូច ។
វីក្បាលទំពែកភ្នែកទន្សាយ ច្រើនចេះលែបខាយខាងខ្ចិលខ្ជូច

ឆាប់ខឹងៗណាស់រឹងស្មុគស្មាញ តែឈោចេះលួចៗទាំងថ្ងៃ ។
វីមនុស្សភ្នែកដាលក្បាលដូចខ្លា សំដីសារិកាក្រជ្រាយ
សាច់ស កជឹងសំឃបងរំ រាងដូចត្រីឥតខ្លាចគេ ។
វីមនុស្សមួយទៀតមាឃាទឹង រាងសំមកំព្រឹងឆ្អឹងទទេ
មុខខ្លាញ់ភ្នែកខ្លោតចង្កាវេហ ច្រើនបានជាមេគេទាំងឡាយ ។
សាច់ជ្រាយភ្នែកជ្រួកច្រើនឥតគិត ក្រឃើញគោលិទ្ធតំនិតងាយ
កដូចពស់រើកភ្នែកទន្សាយ មុខក្រោយច្រើនក្រពើព្រោះហៀ ។
សក់ភួញមុខរាច្រើនមានឫទ្ធិ ជើងធ្មេញញីកល្ងិតចិត្តល្អជា
ភ្នែកតូចដូចពស់ឯកពពា ចំណាំបានជាឧកញ្ញាធំ ។
វីមនុស្សក្តៅកោងឈោងគុជសា សក់ពុងដូចស្វាស៊ីឥតសម
បើភ័យបើភិតគិតតែឈឹ ជើងសក់ភ្នែកធំប្រមឹកស្រា ។
វីខ្លួនរាងកោងក្តោងកន្តឹក ជើងទេញធ្មេញញីកចិត្តឫស្សា
រាងទាបកន្តុញសុញក្រជ្រា ម្រាមរែងដូចខ្លាច្រើនឥតគិត ។
រាងចំខ្ពស់កោងឈោងដើរ មុខក្រៀមថ្ពាមខ្លីដូចឆ្មាពិត
ច្រមុះក្រពិតចិត្តទុច្ចរិត និយាយឥតគិតច្រើនកុហក ។
វីមនុស្សមាឌធាត់មាត់សំពោច មុខក្រោយភ្នែកទោចហ្គាំមាន់គក
ច្រមុះទន្សែងខ្លែងភ្ញោក ជើងកោងពងអេចោកគេស៊ី ។
វីមនុស្សមុខតូក កកុកក្រក សំឃបងស្លក់ ការវិវិ
សាច់សមុខតូចខូចឈលីទី ភ្នែតស៊ីក៏សមជាដោយឃើង ។

សំលេងឮង៉ូងដើមទ្រូងសត្វ　　កំចោងបួចក្អាត់ច្រើនភ្លេងក្អាង
ដំណើរបួចក្អែកភ្នែកឃុនឆាង　　ចិញ្ចាដោយយ៉ាងស៊ីជំនោរ ។
បើមានចំណេះចេះអ្វីក្តី　　អួតក្រែសំដីច្រើនពាលា
ឈានពានឥតគិតចិត្តលោភា　　ខាងឡើងជំនោរជោរចំណាប់ ។
រីមនុស្សខ្លងខើចសើចមុខស្ងួត　　ចង្កេះស្ងិតស្ងួចសំពីញាប់
អ្នកនោះចិត្តមុតខាងសំលាប់　　វាយចាញ់ចាក់កាប់ឥតកោតដែ ។
រីអ្នកពោះក្អាត់មាត់បួចសេះ　　ភ្នែកខ្ពោតក្លិនឆ្អេះថ្វាសពស់ព្រៃ
អ្នកនោះពារលោចោរចង្រៃ　　សាច់ញាតិដីទៃពឹងពុំបាន ។
រីមនុស្សពោះឆ្កែមុខមូលស្រួច　　រាងកោងដៃតួចខ្លួចមិនខាន
ចិត្តសោតឫស្យាពន់ប្រមាណ　　បានខាងលួចសើចលេងលេចលង់។
រីអ្នកភ្នែកទោច កមាន់ព្រៃ　　សាច់ខ្មៅរិស៍យភ្នែកមមង់
មមីសងស្ងើននោះច្រើនលង់　　ពូជពង្សក៏ច្រើនតែថោកទាប ។
រកមនុស្សថ្កាមខ្លាចង្កាហ៊ីង　　ពោះធំកំពឹងក្បាលត្រីផ្សេប
ភ្នែកពស់អ្នកនោះច្រើនសុភាព　　កិរិយារាបទាបចេះគួរសម ។
រីបួចពស់រំកភ្នែកសល្អក់　　ជើបទ្រុងសុនខាងស្តមទាប
កន្ត្រេលរាងរលេទាបទ្រនាប់　　នោះច្រើនមានទ្រព្យអភ័ព្វកូន ។
រីបួចទន្សាងខ្លងទន្សាយ　　សាច់ក្រៀមមុខក្រាយក្របងប្អូន
ភ្នែកសេកអ្នកនោះច្រើនតែងខ្លួន　　ចេះក្បួនច្បាប់ច្បាស់ចាំមាត្រា ។
បើធ្វើមន្ត្រីក៏ត្រីមត្រូវ　　មិនស្ងូវរកប្រាប់ពីអ្នកណា

បុណ្យសោតក៏យឺនច្រើនឈ្វេងឈារ ចិត្តសោតក៏ជានឹកដុំម៉ែ ។
បើមានទ្រព្យអ្វីក៏គង់ប្លុះ បើបានជាគ្រួក៏ពូតែ
បើធ្វើរង្គៀឈ្មួញជួញព្រៃ ជួញម្តេចក៏គង់តែចំណេញ ។
វីមនុស្សមាត់សេកឆ្នែកទន្សាយ កក្រាញ់មុខក្រោយទាបក្រតុញ
ជើងធ្មេញញីកល្ឿតចិត្តថប់ធុញ ប្រាជ្ញាក៏សុញឥតគណនា ។
វាណាស់តែធ្វើខាងខិលខូច កោងកាចឥតកោតអុកឯណា
ក្មានសណ្តានចិត្តផៅនៅមីងមា ចេះតែលោភូចចង្រៃ ។
វីថ្វាសត្រងាលក្បាលតូចស្រួច មាត់តូចក្រហួចចង្កេះខ្លី
មុខក្រោយថ្ពាមខ្លាចង្កាត្រី ចិត្តសោតស្អីយភ្លុតស្មរពូជ ។
ចោកប្រាសបញ្ញាតមិនឃល់ញាតិ មួយទៀតមាយាទអួចឆ្កែល្មួច
អ្នកនោះច្បៀសខ្ញុំតេមិនរួច ពីព្រោះខិលខូចលួចអ្នកផង ។
សម្តែកទំនាយទាំងនេះឯង មិនចែងពីចិត្តខ្ញុំកាលណា
ដោយចែងតាមបទក្បួនហោរា ទំនាយមកថាអ្វីច្នោះនែ ។
វីមនុស្សកើតមកក្នុងផែនភព រាល់រូបមានគ្រប់អួចទំនាយ
អ្នកណាមិនជឿគង់នឹកស្តាយ ចាស់ទុំណោកទាយមិនខុសទេ ។

ស្តាប់សូរក្អែកឫល (បទពាក្យ៧)

សូមឱនប្រណិតប្រណម្យផ្តង់ លើកករកំបង់អញ្ជលី
នឹកដល់បុរាណជាចមមុនី ឃ្យបចំតម្តីរចងទុកមក ។
ចងជាតម្រាក្អែកអោយឫក្ស ជាយាមពន្លឺកមើលជំយជោគ
គម្តីរសែយសាស្ត្រសំដែងមក ចូរសង្កេតរកឫក្សកាលល្អ ។
ដេញដោលឃាលឃីកយកភាសា សូរសំឮបក្សាក្អែកឫលបរ
បើឮវាយំ កា កា ក៏ នៅចំពោះមុខបានលាភលន់ ។
បើយំ កា អរ កា អរ ណា មានគេឫជាព្រះព្រោះបន់ស្រន់
បើ កា វា កក់ កា វា កក់ នឹងអន់ បង់ធនកើតទុក្ខមិនសុខចិត្ត ។
បើ កា វា កា វា មានថ្នាក់ មានកិច្ចចុរៈដល់ជីវិត
នឹងជាបដល់ជនទន់តំនិត វិបរិតឃាលរាលដាលដល់វង្ស ។
កា វ៉ កា វ៉ ចូរស្បើយទុក្ខ បានសុខរួមមិត្តញាតិផៅពង្ស
បានគូស្រករល្អរលង់ សមទ្រង់សមទ្រាយធាយឆវី ។
ក្អែកសត្វបក្សីជាប្រផ្ទួល ចេះមានចំណូលឫលពីរ។
ជាបញ្ជោកម្មផ្សាំសញ្ញី អ្នចថ្លែងវាទីទុកនេះអើយ !

ស្តាប់សូរតុកកែយំ

តុកកែយំមានគំរប់ប្រាំ　　ម្ចាស់ផ្ទះមានកម្មក្តៅក្រហាយ
ទុក្ខភ័យក្តីភិតភើតអន្តរាយ　　ទ្រព្យធនរលាយខ្ចាយចាចសាច ។
ចាវព្រាវព្រាសរត់ចោលឋាន　　កើតទោសរំខានរាមិនខ្លាច
រំពឹងគុំនុំប្រុងធ្វើកាច　　ចិត្តចើចកំណាចដូចអប្រិយ៏ ។
តុកកែយំគ្រប់ ប្រាំមួយដង　　ទីឋានផ្តាច់ត្រងជាប្រក្រតី
កើតកោឡាហលខ្វល់ឃ្យីងក្តី　　វិសំយមនុស្សព្រៃចិត្តអប្បលក្ខណ៏។
សម្បត្តិទ្រព្យធនធារមិនបាន　　កើតអន្តរធានមានគ្រោះថ្នាក់
លបលួចបន្តំគែទុកដាក់　　ជ្បើបុលចំពាក់ទារមិនបាន ។
តុកកែវាយំ ប្រាំពីរដង　　ទ្រព្យផងក្នុងផ្ទះអម្បាលម៉ាន
ចោរចាចបីចប្រើមិនចេះខាន　　បាត់បង់ផុងប្រាណខានខាតឈស។
សត្រូវនៅកិតចោមមើលងាយ　　សត្រូវមេម្លៃយណាយនឹងឈ្នោះ
ទ្រព្យអោយគេខ្ចីរឹតរណោះ　　ទារវិញកើតទោសពីទ្រព្យឯង ។
តុកកែយំឈ្ងរ ប្រាំបីម៉ាត់　　មូលទ្រព្យសម្បត្តិសព្វតំណែង
ស្រីង្គារបរិវារចិត្តកោតក្រែង　　ទីបនកន្លែងល្អតលាស់ឈប ។
ប្រកបមុខការបានផលធំ　　គេរាប់និយមបានសំរេច
ធ្វើច្រើនបានច្រើនតិចបានតិច　　គាល់នាហ៊ឺនស្តេចបានសក្តា ។

បើវាយំយាមគ្រប់ជ្រាំបួន　　នឹងមានបងប្អូនមិត្រវស្សា
នៅឆ្ងាយរលីកចរយាត្រា　　មកកាន់គេហាហៅយកទៅ ។
ប្រគល់ផ្តល់មុខសុខលាធំ　　បានសមគោលចិត្តគ៌តប៉ងដៅ
រីករាយសប្បាយគ្មានសត្រូវ　　ចរទៅបានទុនធ្ងនក្នុងចិត្ត ។
តុកកែសម្ងំពេលយាមដប់　　យំជប់ទ្រព្យធនមូលសម្បត្តិ
មាសប្រាក់ខោអាវមួកមុងឆ័ត្រ　　សេរីសុវត្ថិកុះកុមកប ។
ក្បៀវចោមជុំជិតចាំទទួល　　ខ្ចីខ្ចួលរាប់អានឱនប្រិតប្រប
ជញ្ជួនភ័ស្តុការរបស់ទ្រព្យ　　មកផ្តាច់ជាលាភប្រៀបមិនបាន ។
យំជប់មួយផងមានសណ្តាប់　　យសសក្តិឆ្លាប់ទាបឡើងដល់ឋាន
ខ្ពស់ធំសមសក្តិសភាពប្រាណ　　ពង្សាសន្តានបានពីងពាក់ ។
ធ្វើការសារពើក្នុងមន្ទីរ　　មួយកើនជា២ទ្វីឈើសថ្នាក់
ភស្តុការសួយសាបានទុកដាក់　　មាសប្រាក់កើនប្រែឈើសគេផង ។
បើយំបន្ថែមឈើសជាងជ្រាំ　　វាវេរាកម្មនាំអោយហ្មង
ចង្រៃឧបទ្រពចិត្តយង់ឃ្នង　　ភ័យផងរោគសោកមូលមានច្រើន។
ពុំនោះមានកាយកលពិការ　　គ្រោះកាចអបរាវីតវីកផ្តើន
ជំងឺឈឺចាប់ចុកគគ្លើន　　រោគរាលទន្លើនផ្តើនប្រលំឃ ។
វិបត្តិចោមរោមរាល់ពេលា　　មិនសូវបានជាៗប្រក្រតី
សម្បូណ៌សម្បុកណាស់តែភ័យ　　ឃ្យើងក្តីរាល់ថ្ងៃឥតបីខាន ។
ឃ្យៀបយំលាន់ក្រាតក្រាតដំបូង　　សូរនោះរំលងយកមិនបាន

យកតែសំលេងដែលចំណាន ជាសូរស្តាប់បានពេញសំលេង ។
សូរនេះរាលាន់ចេញមិនប្រាប់ សឆ្អត់ជាសំឡេងឯង។
មិនយកជាការថាជាល្បែង ព្រោះវាយំក្តែងក្តាយបន្តិ ។
អត អតដំបូងយំដំបួច តុកកែធំតូចវាថាផ្សំ
បើឮច្បាស់លាស់មិនស្ទាស្ទំ តុកកែវាខ្ចាំក្នុងថ្ងើមវា ។
មិនមានទោសគុណពីពាក្យនោះ ទុកជាពាក្យខុសក្រៅតម្រា
កុំបីផ្សែផ្សំយកជាការ ជឹងថាសុខទុក្ខក៏មិនកើត ។
បើបែរជាយំ ឮកែ កែ សូរឮស្រាលណ្តែទ្រង់ផ្តើត។
ស្អកស្អាកមិនល្អះហាក់ល្អាក់ល្អើត ព្រើត។ព្រាល។អាងមិនបាន ។
តុកកែជាសត្វមួយតូចទេ ប៉ុន្តែនាំសារការរិះធ្យាន
អោយមនុស្សឈោកដឹងកុំបំពាន ទោះបីទុក្ខក្សាន្តមានតម្រា ។
មនុស្សមានញាណដឹងកលកិច្ច គេមិនបំភ្លេចសច្ចរាចា
គេខំអន្តងចារណា កលការគេកែប្រែតម្រង់ ។

ស្តាប់សូរកណ្តុរយំ

សិទ្ធិការឮតម្រាពោលពីសំឡេងសូរ ចតុបាទកណ្តុរយំយប់ថ្ងៃ
ក្នុងឋានតំបន់នៅប្រក្រតី ជ័យជោគចង្រៃតាមតម្រា ។
ចូរសង្កេតស្តាប់សំឡេងសូរស្បែង ផ្តាត់ផ្តៀងអោយជាប់ល្បៈវគ្គឃ្លា
អោយបានច្រាកដទើបសញ្ជា កាត់អាថ៌ប្រស្នាជាប្រផ្នូល ។

(បទភាកតតិ)

កណ្តុរឈ្មោលញី ទាយតាមគម្ពីរ ថាយំចុក ចុក
គង់តែជួបលោភ សភាពយ៉ាងស្តុក ផុសចំពោះមុខ
គាប់កលបំណង ។

លាភផលភ័ស្តុភារ កើតកើនហួសហេ្វរ ច្រើនលើសច្រើនឆង
កើតទាន់ចិត្តគិត មិនបានផ្សារផ្សង យ៉ាងឈ្នះរំលង
ជ្រាំយាមទៅមុខ ។

បើយំ ខឹក ខឹក មានបើរវើរក កង្វល់ជាទុក្ខ
ទោសត្រូវទិសា មានការណ៍រំអុក ពុំនោះអផ្សុក
កើតឃាតាភ័យ ។

យំឮ ខុក ខុក មិនសូវបានសុខ ម្ខាស់ផ្ទះកុំបី
ចរទៅទីឆ្ងាយ អន្តរាយកើតក្តី នឹងមានមោះមៃ
មន្តិលផលប្រាណ ។

វាយំ ចេត ចេត ជាពុំនោលហេតុ អ្នកបរិភោគកើតមាន
ពេញមាត់ពេញក តាមទទួលទាន សឹងបរិបូណ៌ជាន
ដូចក្តីប្រាថ្នា ។

យំស្នូរ សុត សុត មានទោសចំហុត ប្រយុទ្ធកាលា
ចេញចរជំនួញ រួញចិត្តរអារ បើមានខកការ
ខាតដើមមិនខាន ។

សូរយំ ខ្សែត ខ្សែត មានក្តីខេចតវី ទោសខណ្ឌសាមាណ្យ
កើតទុក្ខយ៉ាងធំ ព្រោះក្តីរាប់អាន វាឆ្លើយបំពាន
ដាក់ទោសដល់ឯង ។
កណ្តុរជាសត្វ សំរាប់ខាំកាត់ ក្នុងផ្ទះសំបែង
វានាំរំណឹង គេពឹងសំដែង ឱនហើយតួរក្រែង
កុំក្រាញសាញនៅ ។

មើលកណ្តុរ[1] កាត់សំពត់ (បទពាក្យ៧)

ធម្មីរនិទានមានសញ្ញា បុរាណណាចារ្យចងទុកមក
ទុកជាតម្រាប់ត្រាប់កាន់យក ជាគ្រឿងរិះរកជោគរាស្ត្រា ។
វត្ថុធនធានមានសណ្តាប់ ជាទ្រព្យស្រឡះពេញចិន្តា
សត្វខាំកកេរកាត់ពស្ត្រា ផ្ទុះផ្តាយត្រង់ណាមានចំណាំ ។
ភ្លើងឆេះខ្លោចប្រេះដាចដោយដុំ មានរូបភាពផ្សំប្រជុំតាម
ទំនាយទាយទស្សន៍ជាទំនៀម តម្រាប្រាប់ប្រាមអភិប្រាយ ។
ស្នាមកាត់ដាច់ដូចរូបអ្វីៗ តម្រាចារ្យស្តីបទបរិយាយ
រង់មូលដូចច័ន្ទចរពណ្ណរាយ ណោកស្រាយទិទានទំនាយថា ។
ចានលាភលើសលប់ទាំងយប់ថ្ងៃ ថោកថ្លៃហូរចូលរាល់ទិវា
ធនធានបានកើនច្រើនវឌ្ឍន៍នា ភស្តុភារសាយភាយរាយរាល់ពេល។

១-តម្រាខ្លះថា កណ្តុរក្តី, គន្លាតក្តី, ភ្លើងឆេះក្តី មានន័យដូចគ្នា ។

ស្នាមកាត់ដូចកលនៃភ្លីស្រែ ឬមួយដូចខ្សែផ្តាយរង្វេល
លោកអោយឫជាយ៉ាងក្រាស់ក្រែល ទើបនៅពិសាលសុខសួស្តី ។
កាត់ស្នាមដូចជារូបរាងនាឡិ បណ្តាលបានគូស្រករថ្មី
មានមិត្តជិតឆ្ងាយមកប្រាស្រ័យ លាភផលសេរីរីករងថ្លា ។
កាត់ជារូបដូចដើរចូលទៅ នឹងទៅសាន្តសុខនិរទុក្ខា
សម្បូណ៌ហូរហៀរគ្រឿងបរិក្ខារ ប្រើការមិនអស់រលោះឡើយ ។
ស្នាមដូចព្រឹក្សាដុះលាស់ល្អត មានលាភរហូតមិនអស់ស្បើយ
បានមកទុកដាក់លាក់កន្តើយ គង់ហើយសុខទៀតឥតឃ្លាតឃ្លា។
កាត់ជាផ្កាអង្គាបុស្ស ធ្លុះដាចបានផលសោយសុខា
ក្បែរមក្បាន្តក្នុងឋានរួមគ្រួសារ ញាតិមិត្រសាមគ្គាមូលមេត្រី ។
កាត់ប្រឡាយឆ្ងាយប្រទាក់ ព័ន្ធពាក់ដូចពីងពាងវិស័យ
ល្អណាស់ជ្រះឧបទ្រពចង្រៃ នឹងមានស្នាដៃល្បីឮឆ្ងាយ ។
កាត់ដូចស្នាមជើងសុនខា វាស្នាឈ្បឺនលេចឃ្បែងធើតឆាយ
បានជាឃុនណាងឥតបីក្លាយ រូបកាយកើតសុខប្រាសទុក្ខភ័យ ។
ឃ្យរទៅគង់ដល់ជល់ស្ថានស្ថិត ប្រសិទ្ធិប្រសើរស្មើផែនដី
រុងរឿងវិទ្ធីទ្ធីពេញផ្ទៃ ល្បាញឈ្បីជាញជ័យជុំនគរ ។
បើកាត់ពិកលខ្វល់សញ្ញា ជារូបជនានឹងមិនល្អ
ជតាដាក់តាបភាពទ័លក្រ ទុក្ខធំស្មើរមរណាមែនពិត ។
ស្នាមដូចដួងច័ន្ទចរទើបរះ ឫជារហ័សបានសំរិទ្ធិ
សោយសុខសម្រាន្តបានក្បាន្តចិត្ត សំរាំងសិរីទ្ធបានសំរេច ។

បើកាត់ដាច់ដូចរូងដងធ្នូ គំគិតគួរជាកលកិច្ច
កើតសមច្រាថ្នាការម្តេចៗ ច្រើនមានទាន់ដូចច្រាថ្នា ។
កាត់ជារូបរាងដូចសំដួងជ័យ ច្រាថ្នាការអ្វីល្អអស្ចារ្យ
ចេញជួញឆ្ងាយជិតបានវឌ្ឍនា សក្តាកើតកបសព្វជំណែង ។
កាត់ជារូបទែនរត្នមណ្ឌល កើតផលប្រសិទ្ធិសំក្តិសមខែង
ផុសផុលកើតដល់ទីកន្លែង ជាក់ស្តែងទាន់ចិត្តគិតប៉ុនប៉ង ។

លក្ខណៈដែលសត្វខារកាត់ (បទពាក្យ៧)

កាត់សក់មានតក់ទាស់មន្ទិល កើតទុក្ខផ្តាច់ផ្តិលជីវិតផង
មាតាបិតាណាញាតិហោង សោកសៅក្តៅហ្អែងមានមកដល់ ។
កាត់ពីខាងខ្ពង់បង់ធនទ្រព្យ ជាការមិនគាប់កើតសាល់រលែ
ចោរលបលួចរាំចូលមណ្ឌល រចល់ចេញចាប់រាចេញរួច ។
កាត់ខាងមុខមានទុក្ខដល់ខ្លួន ខំសួនរក្សាការធំតូច
កុំទាស់ទែងគ្នាមានបើខូច ផ្តើមផ្តួចជាទោសទណ្ឌពំផ្សែរ ។
កាត់ជើរចោលពួកពងរ្សា បរិហារការព្រួយក្រែងកំព្រា
ច្រាសព្រាត់ឃ្លាតចាកចោលមិត្រភ្ងា មរណាពុំនោះនៅមិនសុខ ។
បើកាត់ចំក្បាលជង្គង់ធ្លុះ មានគ្រោះចោះចំនៅខាងមុខ
ប្រពន្ធកូនចៅផៃក្នុងស្រុក មរណៈជាទុក្ខទណ្ឌប្រល័យ ។

កាត់ថ្ងៃវិរវរជន　　បុណ្យសក្តិថ្កើងលន់លប់សើរ
ឡើងកាន់ឋានៈជានរបតី　　ថ្កើងឈសចារមីឥតគេស្មើ ។
ថ្ងៃចន្ទថែងកាត់អឃ្បមង្គល　　មានដល់ប្រពន្ធកូនម្រាក្សក្តើ
សន្តានព្យែនលានមានរំណើរ　　ស្តុនដើរតាមផ្លូវមានភ្លាត់ការណ៍ ។
កាត់ថ្ងៃអង្គារ៍ជាពន្លឺក　　សុខទុក្ខព្រឺកឈប់ព្រួយចិន្តា
ឪពុកម្តាយនៅឆ្ងាយរន្ទះសារ　　មានការផ្តាល់ខ្លួនពួនមិនជិត ។
ថ្ងៃពុធកាត់ឆាយដាចពេលនេះ　　គួរិះរក្សាមើលពិនិត្យ
ប្រពន្ធកូនចៅខ្លៅបៃណ្ឌិត　　មានភិតបានផលដល់ជននោះ ។
ព្រហស្បតិ៍កាត់ធ្លុះសុះសព្វសាច់　　កាត់ដាច់គឺដល់ជនសប្បុរស
ជាគ្រូអាចារ្យយើងស្រស់ៗ　　ទាបខ្ពស់ត្រូវខុសជាមិនខាន ។
បើកាត់ថ្ងៃសុក្រទុក្ខបរិហា　　កើតពីភស្តុភាទ្រព្យធនធាន
របស់ខ្លួនយើងមានប៉ុន្មាន　　ខំកែគិតអានកុំខ្ជិខ្ជា ។
ថ្ងៃសៅរ៍កាត់ដាចមានដល់ខ្លួន　　ទុក្ខសុខមាំមួនទោះកាចជា
លាភផលពីកលភេទពីការ　　ចំពោះអាត្មាថ្ងៃនេះហោង ។
សត្វកាត់ពស្ត្រាជាសង្ខេប　　តាមបែបបុរាណបានចែងចង
ចែងចារនិទានមានគន្លង　　ដើមអងដោមដាក់ជាក់ចែងចប់ ។

ឃើលលក្ខណៈពីងពាងគោះទ្រូង[1] (បទភាគតតិ)

ន៏ងពោលទំនាយ ទំនងឋវិយាយ ពីសត្វពីងពាង
វាព័ទ្ធពាក់មង ឱបពងពាក់ថ្មែង វានៅប្រចខាង
កន្លែងមនុស្សនៅ ។
ពាក់មងវង់ម្ចុល ក្នុងបន្ទប់ចូល ក្នុងផ្ទះនោះភ្លឺ
ទាយថាវិបត្តិ ភ្លាត់ការណ៍អាស្រូវ ពុំនោះក្តួលក្តៅ
ក្តីសៅសោកមាន ។
ចាវព្រាវចិត្តព្រួយ វាគិតភ្លាក់ផ្អើល ចោលចោលទីឋាន
ជើងឈ្លួលចង់ឈ្លះ ចិត្តមារឈ្លានពាន ឃ្លរទៅគង់បាន
សុខស្រួលរឿយហោង ។
បើព័ទ្ធមងនៅ លើដំណេកភ្លឺ មានគ្រោះធំធង
មានក្តីព្រាត់ប្រាស់ និរាសក្នុងត្រង ដោយសារវ៉ាប់រង
គ្រោះកម្មអាក្រក់ ។
គ្រោះកាលធំកាច រន្ធំបន្តាច ចូលមកឆាបឆក់
ផ្តាច់បង់ឥន្ទ្រីយ៍ ជីវិល្អោចល្អក់ កំព្រាតក់ម៉ក់
តែលតោលចោលការ ។

១-ន័យខ្លះថា ពីងពាងវាចំកោង បីពងជាប់នៅទ្រែង ព័ទ្ធមងនោះឯង ។

ព័ទ្ធមងពីលើ ទុកជាចង្ឈើ នៅលើត្តោងទ្វារ
នឹងមានឈើថ្កាត់ ប្រាសព្រាត់មេចា ពុំនោះកាយា
យើងមានពិកល ។
ព័ទ្ធខាងក្នុងផ្ទះ នៅចំខាងទិស បុព្វាមណ្ឌល
ទៀបក្បាលដំណេក ការប្លែកមានដល់ មិនឈ្លរតង់ដល់
ជួបមនុស្សកាឡី ។
វានាំបណ្តាល អោយឯងងាលរាល ជាការអប្រិយ៍
ពិធាធរាលដាល ពាសរាលស្បើមក្រែ ចាត់ជាចង្រៃ
កាឡកណ្ណីណាស់ ។
ព័ទ្ធពីខាងលិច មានហេតុច្រើនតិច កើតឃ្យឹងក្នុងផ្ទះ
ចាវច្រើនសព្វថ្ងៃ ចិត្តវាមានៈ ប្រកួតចង់ឈ្នះ
ចោកប្រាសរត់ចោល ។
រាសីខ្លួនដាក់ បណ្តាលគ្រោះថ្នាក់ រកស៊ីមិនស្រួល
មានតែខាតទុន ទាស់ទែងជើងឈ្នួល លក់ដូរមិនចូល
ដើមចុងចេញអស់ ។
ឃ្យឹងនេះតម្រា លោកទំនាយថា កុំប្រហែសសោះ
កុំអាងថាសត្វ មិនដឹងត្រូវខុស វាអោយកំហុស
យើងយ៉ាងម្តេចបាន ។

យើងហើយនិងវា ឃ្វាងវិស័យគ្នា ឆ្ងាយពន់ប្រមាណ
វាជាសត្វល្ង់ ល្ងិតស្តុងស្តាប់ញាណ ម្តេចមកប្រៀតប្រៀន
បំពេញយើងកើត ។
បើថាយ៉ាងនឹង បុរាណចេះដឹង ស្គាល់ជាតិកំណើត
លោកចែងចារមក ទុកជាលោកឆោត លោកពន្យល់ហេតុ
ថាយ៉ាងនេះនៃ ។
ស្រមោចតូចមួយ វាអាចចេះជួយ មានឧប៉ុនដើរ
វារចូលទៅខាំ ក្តៅព្រានេះវើ ធ្លាក់ព្រួញពីដៃ
អាល័យតែអេះ ។
ពាក្យនេះយ៉ាងខ្លី លោកធ្យេបសេចក្តី សូមលោកដំចេះ
ចូរពិចារណា តាមផ្លូវតម្រិះ ឃើញគួរដល់ចេះ
អញ្ជើញជ្រើចុះ ។

មើលញាក់ភ្នែក ~ ដៃ ~ ច្រមុះ ~ ត្រចៀក

- បុគ្គលណាញាក់ត្របកភ្នែកស្តាំខាងលើ នឹងមានគេនាំលាភមកអោយ ។
- ញាក់ត្របកភ្នែកខាងឆ្វេង (បើស្រីនិយាយដល់ញាក់ចំពាក់កណ្តាលភ្នែក) នឹងមានមនុស្សមករក ។
- ញាក់ត្របកភ្នែកឆ្វេងខាងក្រោម មានគេចោទប្រកាន់ ។

- ញាក់ច្រមុះ មានគេរកឃ្យីងរកហេតុ មិនល្អទេ ។
- ញាក់ត្រចៀកស្តាំ នឹងបានឮដំណឹងអាក្រក់ បើញាក់ត្រចៀកឆ្វេងនឹងមានលាភ។
- ញាក់ខាងស្តាំ នឹងបានកូនប្រុសជាទីគាប់ចិត្ត ញាក់ខាងឆ្វេង នឹងបានកូនស្រីជាទីស្រឡាញ់ ។
- ញាក់ភ្លៅខាងឆ្វេង នឹងមានលាភ, ញាក់ភ្លៅខាងស្តាំ នឹងមានឃ្យីងរាវី ។
- ញាក់ខ្នង នឹងបានធ្វើការនៅបន្តបន្ទាប់អ្នកធំ ។
- ញាកបបូរមាត់ស្តាំ មានលាភ, ញាក់បបូរមាត់ខាងក្រោម នឹងមានទុក្ខព្រោះញាតិ, ញាក់បបូរមាត់លើ នឹងបានបរិភោគអាហារឆ្ងាញ់ពិសារ, ញាក់ក្បែនខាងឆ្វេង ស្រីនឹងអោយលាភ, ញាក់ក្បែនខាងស្តាំ កើតជោគជាទីគាប់ចិត្ត ។
- ញាក់ដៃឆ្វេង ចាប់ពីកែងដៃចុះទៅក្រោម នឹងមានស្រីធ្វើទោស, ញាក់ខាងស្តាំ នឹងមានលាភពីចំងាយ ។
- ញាក់កែងដៃខាងស្តាំ នឹងមានមនុស្សស្រឡាញ់, ញាក់កែងខាងស្តាំមានបងប្អូនមករក ។
- ញាក់ដៃឆ្វេង តាំងពីស្មាចុះទៅក្រោម នឹងមានក្តីឈ្នោះ ។
- ញាក់ដៃខាងស្តាំ នឹងបានមាសប្រាក់ ។
- ញាក់ចង្កូលដៃ នឹងកូនដៃ នឹងមានឃ្យីងរាវី ។
- ញាក់ម្រាមកណ្តាល បងប្អូននឹងគិតដល់ ។
- ញាក់ជង្គង់ស្តាំ នឹងមានលាភ, ញាក់ជង្គង់ឆ្វេង នឹងបែកបាក់ប្តីប្រពន្ធ ។
- ញាក់ស្មាឆ្វេង នឹងមានទុក្ខ, ញាក់ស្មាស្តាំ បានសេចក្តីសុខ សំរាន្តក្សាន្តចាកទុក្ខភ័យន្តរាយ ។

ឥន្ទាយសត្វធ្លាក់

នេះនឹងទំនាយពីសត្វធ្លាក់ សូមអោយអស់លោក-អ្នកសង្កេតមើលតាមតម្រាថា នឹងកើតភយន្តរាយ ឬមានលាភដល់បណ្តាជនយ៉ាងណា ដូចតម្រាថា សត្វទាំងឡាយ មានសត្វ : ក្រឡាត, ខ្លឹស, ជីងចក់, ពស់, ត្រីង, ចាប, ព្រាប, ឆ្មាថ, ខ្លែ, តុកកែ, កណ្តុរ, ឃ្មុំ, ក្អែប, អំពិលអំពែក, មេអំពៅ, ពីងពាង...ជាដើម

បើសត្វទាំងនេះធ្លាក់ត្រង់កណ្តាលជំនុំ នឹងមានប្បីងរ៉ាវអាក្រក់កើតឡើងមិនខាន, បើស្លាប់ត្រង់ទីនោះ បណ្តាជននៅក្នុងទីនោះ នឹងសូន្យជីវិតអ្នកណាមួយមិនខាន ។

អង្គុយនៅម្នាក់ឯង ធ្លាក់ចុះត្រង់មុខ ទេព្តានឹងជួយអភិបាលរក្សានឹងបានលាភជាទីគាប់ចិត្ត ធ្លាក់ចុះខាងឆ្វេងខ្លួន នឹងកើតមានសេចក្តីទុក្ខព្រួយ ។

ធ្លាក់ចុះខាងស្តាំ បងប្អូនមកជួយប្រសព្វគ្នា ។

ធ្លាក់ចុះខាងក្រោយខ្នង នឹងមានមនុស្សបង្កហេតុចំពោះខ្លួន ។

ធ្លាក់ត្រូវក្បាល កុំខ្លាចមុខបានគេនាំយកសួយសាអាករមកជូន ។

ធ្លាក់ត្រូវមុខ បើប្រុសគប្បីខ្ចល់ខ្វាយស្វែងរកភរិយាជាទីស្រឡាញ់ បើស្ត្រីនឹងបានភស្តាជ័ជាទីស្នេហាស្មើជីវិត ។

ធ្លាក់ត្រូវកែងដៃឆ្វេង លោកទំនាយថា វង្សានឹងស្លាប់ពិតប្រាកដ បើមិនឬឆ្នោះទេ នឹងមានមនុស្សនាំយកទោសមកដាក់ខ្លួន ។

ធ្លាក់ត្រូវចុងដោះ បើស្ត្រីនឹងបានស្វាមី, បើប្រុសនឹងបានភរិយាល្អឯក ។

ធ្លាក់ត្រូវផ្ទិត លាភនឹងកើតមានដល់ខ្លួនយ៉ាងប្រចស្ស ចានក្ងន បើខ្យត់ក្ង នឹង ចានក្ង យ៉ាងជាក់ស្តែង ។

ធ្លាក់ត្រូវខ្លួន សូមប្រយ័ត្នអោយមែនទែន ។

ធ្លាក់ត្រូវត្រចៀក មិនល្អ សូមប្រយ័ត្នស្រី។ នឹងនាំទោសទុកមកអោយ ។

ធ្លាក់ត្រូវជើងឆ្វេង មិត្រភ័ក្ត្រនឹងនាំយកលាភមកអោយ ។

ធ្លាក់ត្រូវជើងស្តាំ សូមប្រយ័ត្ន ទុក្ខមានមុន ហើយនឹងចានលាភ ខាងក្រោយ

ធ្លាក់ចុះ ហើយវារឡើងមកលើខ្លួន រហូតដល់ក្បាល អ្នកធំនឹងអោយបណ្តាសក្តិ ជាទីគាប់ចិត្ត ។

ធ្លាក់ភ្លាម ហើយកំពុងតែវារឡើងមកលើខ្លួន អន្តរាយនឹងកើតឡើងដោយបងប្អូន របស់ខ្លួន ។

វារឡើងមកលើស្មាទាំងពីរ នឹងចានលាភសមបំណង ។

វារឡើងដល់ផ្ទិត ញាតិវង្សានុវង្សនៅឆ្ងាយ នឹងមកជួបគ្នា ។

វារឡើងដល់ចង្កេះ មិត្តសំលាញ់នឹងនាំយកលាភមកអោយ ។

ធ្លាក់វារទៅទិសអគ្នេយ៍ វារគេចរត់ទៅទិសឫតី ពួកចោរកំណាចនឹងលួច យកទ្រព្យរបស់ខ្លួន ។

ធ្លាក់វារទៅទិសអគ្នេយ៍ ទាំងទទួលសេចក្តីទុក្ខព្រួយ ព្រោះមិត្តសំលាញ់របស់ខ្លួន នឹងចានលាភក៏ព្រោះតែគេដែរ ។

ធ្លាក់វារទៅទិសបស្ចឹម បងប្អូននឹងមកធ្វើទុក្ខទោសដល់ខ្លួន ។

ធ្លាក់វារទៅទិសនិរតី នឹងចានលាភជាទីគាប់ចិត្ត ។

ធ្លាក់វារទៅទិសពាយព្យ លាភនឹងកើតមានជាអនេកអនន្ត ។

ធ្លាក់វារទៅទិសឦសាន នឹងបានលាភច្រើន តែខ្លួនត្រូវចេញចាកទីលំនៅ បើមិនដូច្នោះទេ លាភនឹងកើតឡើងនៅនានាប្រទេស ។

បើធ្លាក់នៅនឹងមួយស្របក់ វារវារពីស្តាំទៅខាងឆ្វេង កុំធ្វើដំណើរ លោកទំនាយទាយថា មិនល្អ ។

គ្រាន់តែធ្លាក់ភ្លាម ហើយវារពីខាងស្តាំទៅខាងឆ្វេងដោយរួសរាន់ នឹងមានឫទ្ធានុភាពឈ្នះអស់ពួកប្រជាករ ។

មួយវិញទៀត បើសត្វវារនាំមុខ សូមអញ្ជើញទៅចុះ ព្រោះលោកទំនាយថា នឹងមានជ័យជំនះ ។

សត្វជីងចក់ ឬ តុកកែធ្លាក់

ជីងចក់ ឬសត្វអ្វីៗ ធ្លាក់ទៅខាងមុខ សូមប្រញាប់ប្រញាល់អញ្ជើញទៅគង់នឹងមានជ័យជំនះ ពុំនោះសោត នឹងបានទទួលលាភដ៏ជាទីគាប់ចិត្ត ។

ធ្លាក់នៅខាងក្រោយខ្លួន សូមកុំធ្វើដំណើរ បើទៅនឹងបានទទួលសេចក្តីទុក្ខព្រួយសត្រូវនានា នឹងប្រែតប្រែន ។

ធ្លាក់ខាងឆ្វេងខ្លួន សូមអញ្ជើញទៅចុះ នឹងមានជ័យជំនះ ពុំនោះសោតទេ នឹងបានទទួលលាភដ៏ជាទីគាប់ចិត្ត ។

ធ្លាក់ខាងស្តាំខ្លួន សូមកុំធ្វើដំណើរ នឹងមានភ័យវល់ខ្លួន ។

ធ្លាក់ខាងលើខ្លួន សូមកុំធ្វើដំណើរទៅកន្លែងណាៗឡើយបើទៅក្រែងសូន្យជីវិតបង់

ធ្លាក់វារឡើងជើង សូមអញ្ជើញទៅចុះ នឹងមានជ័យជំនះមិនខាត ។

មើលលក្ខណៈសត្វឆ្លាក់ (ពាក្យកាព្យ)

សិទ្ធិការ្យចារចែង ជាដំណែងបទបរិយាយ
តម្រាចារ្យភិក្រាយ រាយទំនៀមតាមទំនង ។
ទំនុកពីទំនាស់ ទំនាយចាស់ព្រិទ្ធិព្រោងហោង
ទិទានពិសត្វផង ទំលាក់ខ្លួនជ្រុះចុះមក ។

ឧរធារីណា មានកលការណ៍ធីតវិវាទ សើរមង្គលជោគចូរប្រយោគតាមតម្រា ។

បក្សីហើរវង់ហាស៍ ក្នុងអាកាសជាធម្មតា លុះឆ្លាក់មកឋានណា នឹងមានការណ៍កើតរុំគាប់ ។

បក្សីសឹងមានឈ្មោះ សត្វទាំងនោះមានរស់ងាប់ ហេតុនេះបុរាណរាប់រាយនាមសត្វជាសញ្ញា ។

ចាមស្រុកត្រឡែកកាំ ព្រាបលលកក្រួចឆ្មាជ កុកក្លែងអកក្រសារ សត្វតូចណា ធីកន្លាត ។

កន្លង់ខ្លួយដីម៉ាល់ ធីងចក់ឈានលង់ចុងខ្នាត តុកកែជាដើមអាទិ៍ សត្វជាតិជាសត្រូវប្រជ្រួល ។

ទិសទីជាកំណត់ កំណើតបទតម្រាពោល ដំណឹងស្រួលមិនស្រួលដូចពុំនោលតទៅមុខ ។

ឆ្លាក់កណ្តាលជំនុំ មានការណ៍ធំក្នុងភូមិស្រុក បណ្តាលមានថ្នាក់ទុក្ខ បើឆ្លាក់ត្រូកសត្វនោះងាប់ ។

ឥរជនទាំងឡាយ ឪងបែកធ្លាយសុទ្ធឡយ៉ាងឆាប់ ផៅពងឃ្លុងក្រឡាប់ កោឡោហលខ្ទល់មិនស្រាក ។

បើសត្វនោះនៅរស់ គ្រាន់ត្រគោះត្រឹមព្រាត់ព្រាក ព្រាសគ្នាបែកចេញចាកលាភ ទៅកាន់ប្រទេសធ្លាយ អង្គុយ ឬឈរណា តែងការអប់រំកាយ សត្វធ្លាក់នៅខាងអាយ ចំពោះមុខមិនមានឈ្លែង ។

ទាយថាពេលនោះនៃ មានលាភជ័យជាសំណាង ទេវាជួយអះអាងរួមរក្សាជា ប្រក្រតី បើធ្លាក់នាឆ្វេងកាយ កើតអន្តរាយរោជ័យវិបត្តិកាត់សេរី បណ្តាលភ័យកាន់ បញ្ជា ។

ធ្លាក់ខាងស្តាំកាយកិត ចានជួបមិត្តពួកពង្សា រីករាយសប្បាយថ្លា នាំភស្តុភារ យកមកអោយ ។

ធ្លាក់ពីខាងក្រោយខ្លួង មានសៅហ្មងស៊ុនថ្លង់ឆ្ពោយ គេមកនាំអោយសិយសៀវ ខកការអសារបង់ ។

ធ្លាក់ចំពីលបីក្បាល គួរកុំអាលចេញពីក្នុង ចរទៅណាមានបង់លើមប្រយោជន៍ ប្រយោលការ ។

យសសក្តិធ្លាក់ឆ្ងាយឆ្ងុះ មកពីព្រោះតែអាត្មា ដើរផ្លូវក្រៅតម្រា ឃ្លាងតម្រាទំនាយ ព្រោង ។

ធ្លាក់ចំពីមុខប្រចក្ស ចានឡើងសក្តិយសតំណែង ប្រុសចានប្រពន្ធក្មេង ស្រីគង់ ខែងចានប្តីល្អ ។

ធ្លាក់ត្រូវដៃខាងឆ្វេង កើតសង្រេងសោកយំឡ បិតាមាតាមរណ៍ មានមោះមែ

ភ័យមន្ទិល ។

ឆ្នាក់ត្រូវខាងដៃស្តាំ តាមចំណាំបានលាភផល សម្បត្តិដ៏ធំបុល· បរិបូណ៌សាយ សព្វបរិក្ខារ ។

ត្រូវកំភួនដៃស្តាំ លាភផលធំកើតភោភា វត្ថុដែលប្រាថ្នាសំរេចដូចចិត្តគិត ។

ត្រូវកំភួនដៃឆ្វេង ឃើងផ្សេងៗគោងពិនិត្យ ក្រែងនាំអោយវិបរិត ពាលប្បែត ប្បែនបានទុក្ខា ។

ចាប់ទោសអ្នសងំណើរ វាគុំធ្វើអ្នអប្បរា ឯងទ្រមចាញ្ជ្រាកល់វា ឈ្លក់គំនិត គិតមិនទាន់ ។

បើត្រូវថ្ពាល់ខាងឆ្វេង ស្រីចាស់ក្មេងក៏គង់គ្រាន់ បានប្តីសមសោភ័ណ ប្រុស សំខាន់រូបរាងស្អាត ។

បើប្រុសត្រូវថ្ពាល់ស្តាំ គួរវង់ចាំកុអេភិវាទ ជាគួរត្រូវបទបាទ ឬកមាឃាទ ឃ៉ាងចំណាប់ ។

ឆ្នាក់ត្រូវត្រង់នាភីលាភផលអ្វីអោយមានធំរាប បើស្ត្រីភាពបានបុត្រាស្នេហាក្រៃ

ទោះស្រីសោកែចាស់ ពេលនឹងប៉ះត្រូវបានប្តី ភក្ត្រផង់ល្អប្រឹមប្រិយ កើតអាល័យ អាណោះលន់ ។

ឆ្នាក់ត្រូវត្រង់កាយា ចូរអក្សាខំថែថ្នូន ប្រឹតប្រែងប្រដៅខ្លួន ស្ងួនអោយស្ងប់ កុំងប់ងោក ។

ក្រែងងល់ងល់ចង្រៃ ជួបមនុស្សព្រៃចិត្តឈងជោគ វាកំហែងគំហក ធ្វើកំហល់ ទល់កំហឹង ។

ត្រូវត្រង់កំណាមិនល្អ ក្រែងបង្កកើតខេរឹង ស្រីខូចនាំផ្តួចប្តឹង ផ្តាលផ្តើមទោស ទាស់ផ្តេសផ្តាស់ ។

ធ្លាក់ត្រូវជើងខាងឆ្វេង លាភផ្សេងៗសន្ធឹកណាស់មិត្រភក្តិដល់ផ្ទះ បានរបស់ យ៉ាងគាប់ចិត្ត ។

បើធ្លាក់ត្រូវជើងស្តាំ មានចារម្ភខ្វល់តំនិត នាំទុក្ខមកប្រឌិត ដើរទៅភពនឹងភស្តុ ការ បានទុក្ខទោសជាមុន ទើបបានគុណជាក្រោយណា ទោះបរចេញយាត្រា ច្រើន ត្រីកត្រាក់ត្រហាក់ហត់ ។

ធ្លាក់ទើរលើសិរសា តាមតម្រាទាយកំណត់ អ្នកធំជួយបើកបទ បំបែកបានយស ខ្ពស់ថ្កើង ។

សត្វនោះធ្លាក់មកភ្លាម នៅមិនស្បើមវារវារឡើង តោងសិរីសានៃយើង បុណ្យ បានថ្កើងឡើងស្រស់ៗ ។

វារឡើងខាងកាយា គេផ្ញើសារមកចំពោះ ក្រាប់ដំណឹងចោទពីចាស់ទុំក្រុមញាតិ ផៅ ។

ថាមានភិនជាភេទ បណ្តាលហេតុចាស់សៅដៅ អុតដាលពីខាងក្រៅ អោយ ជុនដាបចាតដាល ។

វារឡើងខាងលើស្មា ស្តាំឆ្វេងណាតាមដំណាល ថាលាភយ៉ាងពិសាល លុតអុះ ដាលឈប់ផើមផង ។

វារឡើងដល់នាភី នឹងបានទីលំនៅគ្រប់គ្រង ញាតិមិត្រនៅឆ្ងាយផង ប៉ងមកជួយ នឹងយើងណា ។

វារឡើងត្រីមចង្កេះ កន្លែងនេះណាស់សា ញាតិមិត្រនាំបណ្តាការមកអោយ ដោយមេត្រី ។

បើធ្លាក់ហើរលូនវារទិសបុព្វានឹងមានក្តី ចោរគិតប្រុងក្រញីលួចរបស់ញាត់សំពាយ

មានរឿងពីញាតិមិត្រ នាំអោយគិតរាយមាយ ទោសនោះនឹងប្រែក្លាយទៅជា លាភតាប់ខាងក្រោយ ។

វារលូនទៅខាងលិច មានរឿងក្តីចក្តក់ញាយៗ ដំណឹងថ្លស់ឆ្ពោយធ្លាក់ទោសទណ្ឌ អល់ផៅពងរ ។

វារលូនទៅខាងនិរតី បានលាភថ្មីថ្លៃច្រើនផង សឹងសុខប្រសើរហោង តាប់បំណង ប៉ងបំណាច់ ។

លូនទៅខាងពាយ័ព្យ របស់ទ្រព្យទោះច្រើនតិច មានមកមិនចេះដាច់ច្រើនពេញ ពោរជាជួនជាប់ ។

ទៅឦសានទិសា បានលាភាច្រើនហួសរាប់ បើចរចេញជួញឆាប់បានយសលាភ លាស់ផុសភ័យ ។

បើលូនលើដំណេក ទៅមុខបែកគេចក្រោយដៃ បានលាភពីស្រុកឆ្ងាយ នឹងសប្បាយ បានសម្បូរ ។

ឃ្យបចរចេញដំណើរ ឈានជើងដើរទៅឆាប់ឈ្មរ ឃើញសត្វវារលូនវ្រវែ កាត់ មុខស្តាំមកឆ្វេង ។

ដំណើរមានទំនាស់ អាក់ខានចុះកុំទៅឈង នឹងលង់លាញវង្វេងនាំសល់រឹល អំពល់ឃ្លាំ ។

លុនកាត់ទទឹងមុខ ល្បឿនត្រសុះឆ្វេងមកស្តាំ ទៅចុះផុសលាភធំ ឫទ្ធិអំណាច មានតេជៈ ទៅប្រកបកិច្ចការ មានជយាឫទ្ធិតបៈ សត្រូវទាំង៤ទិស ទាល់ចាក់បបខួបខ្ចាចអើយ !

ឃ្យឹងនេះស្តែះទុកសិន ព្រោះទាក់ទិនឃ្យឹងខាងក្រោយ ច្រើនបែបណាស់ណោកអើយ ដូចមានពោលតទៅមុខ ។

តម្រាមនុស្សគ្រោតមាត់ និង ជីងចក់ធ្លាក់ ក្នុងទីជាឱកាស

(បទកាកគតិ)

សិទ្ធិការ្យវាទី	និងពោលអំពី	ជីងចក់វាធ្លាក់
តាមបុរាណព្រេង	ណោកចែងចងជាក់	ចារជាអំណាក់
	អំណតមក ។	
ជីងចក់សត្វពួច	មិនចេះខិលខូច	លបលួចឆាបឆក់
របស់ទ្រព្យអ្វី	អោយគេសំឡក់	មិនល្អមិនអាក្រក់
	នៅជាមួយមនុស្ស ។	
បើធ្លាក់ចំមុខ	មិនមានទង្គុក	ហើយរត់រហ័ស
ណោកថាមានជ័យ	ចានក្តីជំនះ	សត្រូវបីងប៉ះ
	ពាល់ខ្លួនមិនបាន ។	
ធ្លាក់ពីក្រោយខ្នង	ច្រើនមានការស័យ	កើតឆ្លោយរំខាន
កុំចរទៅណា	មានការណ៍ផ្ទាល់ក្រាណ	សត្រូវឈ្លានពាន
	ប៉ះពាល់ផ្តល់ទោស ។	

ទោះបីមានការណ៍ សត្រូវឥឡូ វាចាប់កំហុស
ធ្វើអោយសោកសៅ មួម៉ៅក្តៅស្នុះ បង្កើតជំលោះ
រាលឆាលថ្កោលឫក្ស ។
បើធ្លាក់ខាងឆ្វេង តម្រាសំដែង ជោគលាភសន្ធឹក
សព្វវត្ថុផល ផុសលាស់គគ្រឹក ត្រូវត្រង់គិតនឹក
បំណងប្រាថ្នា ។
ធ្លាក់បែរខាងស្តាំ បើតាមចំណាំ កុំចរលីលា
មានបើប៉ះទុក្ខ ទោសទល់វេទនា ពុំនោះភ្លាត់ការណ៍
ដោយសារសត្រូវ ។

ពីធីមើលលក្ខណៈសត្វទុំផ្ទះ (បទពាក្យ៧)

ពួកសត្វផ្ទះមានមន្តិល មានល្បឿងរេចរិលតែងអន្តរាយ
តម្រាចារ្យចងពាក្យបរិយាយ ដោះស្រាយស្រង់ទុកតាមសេចក្តី។
សត្វត្មាតកុកសាប់ឃ្មុំនឹងព្រួត ត្រកួតឥន្ទ្រ និង ពស់ព្រៃ
ចុះចូលទុំផ្ទះមានចង្រៃ ល្អអាក្រក់ស្រដីទៅតាមទិស ។
ហើរមកពីខាងទិសបូពា៌ ទុំឈើគេហាមានទោមនស្ស
ទោសទណ្ឌវិបត្តិកើតស្រស់ៗ ពុំនោះនឹងមានក្តីចរិហារ ។
ម្ខាស់ផ្ទះមានទុក្ខទោសអប្រិយ កើតកាឡកណ្ណីក្នុងថានា
យ៉ាងយូរត្រាំពីរសត្តិវ៉ា មានការពុំគាប់ជាប់ដល់ខ្លួន ។

បើទុំចំខាងទិសអគ្នេយ៍ មានហេតុភាន់ប្រែព្រាត់បងប្អូន
ភ្លើងព្រៃកាចរាលឆាបឆេះសូន្យ ប្រយ័ត្នខំស្ងួនអោយមាំមួន ។
គ្រោះក្រៃបែបនេះវិនាសណាស់ អស់ថ្នះសម្បែងខាតខ្ទេចខ្ទាំ
ទ្រព្យរបស់ណោះរលាយត្រាំ ទ្រព្យនាំអោយនៅទុក្ខា ។
បើទុំនៅខាងទិស ទក្សិណ មានបើទាក់ទិននឹងឃាតា
ព្យាធិជោគឈឺជាប់លាប់ក្តៅផ្សា វេទនារ៉ាំរ៉ៃខែជីវី ។
ទុំទើរខាងទិស និរតី ចោរការចង្រៃច័ងយាយី
ចាំយាមលបលាក់ចូលដល់ទី នាំគ្នាសែងលីចេញល្បីនរ ។
បើទុំពីខាងទិស បស្ចឹម លោកថ្មឹមថាដូចស្តេចរាជសីហ៍
បានលាភពីខាងពួកស្រីៗ អោយដែរដើរចំសមបំណង ។
ទុំទិស ឧត្តរ និងពាយ័ព្យ បានទ្រព្យសម្បត្តិច្រើនគន្លង
ឥស្សរជនចូលមករាប់រង ជួយអ្នកាងជ្រុំជ្រែងអោយលាភយស។

តម្រាមើលជីពចរណ្តុ ~ អាក្រក់

ជីពចរនៅត្រង់ : អោយទាយថា :

ត្របកភ្នែកខាងស្តាំ នឹងមានគេយកលាភមកអោយ ។
ត្របកភ្នែកខាងឆ្វេង មានស្រីនិយាយដើម ។
ចំកណ្តាលភ្នែក នឹងមានគេមករកដល់ទីកន្លែង ។
ខាងក្រោមភ្នែកឆ្វេង មានគេមករកឈ្លោះហេតុ (ទាស់) ។

ច្រមុះ	មានគេមកសម្តីងមើលទោសមិនល្អ ។
ត្រចៀកឆ្វេង	មានលាភយ៉ាងសំខាន់ ។
ត្រចៀកស្តាំ	ចាន់ឮដំណឹងអាក្រក់មកដល់ ។
កស្តាំ	នឹងចាន់កូនប្រុសយ៉ាងតាប់ចិត្ត ។
កឆ្វេង	នឹងចាន់កូនស្រីយ៉ាងតាប់ចិត្ត ។
ភ្លៅកឆ្វេង	ចានលាភពីទីឆ្ងាយ ។
ភ្លៅកស្តាំ	ឃ្យើងរ៉ាវនឹងលេចឮមកដល់ ។
បេះឆ្វង	នឹងត្រូវទោសទុក្ខ ។
ខ្នង	នឹងមានអ្នកផ្តាប់បុណ្យ ។
មាត់ស្តាំ	មានលាភ ។
កណ្តាលមាត់	មានទុក្ខព្រោះញាតិទៅឆ្ងាយ ។
ឈើមាត់	នឹងចានបរិភោគវត្ថុត្រូវមាត់ ។
កំប៉ោះតូចឆ្វេង-ស្តាំ	ស្រីនឹងអោយលាភតាប់បំណង ។
ស្នងឆ្វេង-ស្តាំ	ស្រីប្រុងអោយទោស ។
កំភួនដៃស្តាំ	លាភនឹងចានពីឆ្ងាយ ។
ត្រង់កំភួនដៃឆ្វេង	ស្វាមីភរិយានឹងអរិចិត្តនឹងគ្នា ។
កែងដៃខាងឆ្វេង	មានមនុស្សស្រឡាញ់មេត្រី ។
កែងដៃខាងស្តាំ	បងប្អូនឆៅឆ្ងាយមករក ។
ចាតដៃឆ្វេង	បើជាខុនណាចានឡើងយស ។

ចាតដៃខាងស្តាំ	តទៅខាងមុខនឹងបានប្រាក់មាស ។
ម្រាមនាងដៃ ឬចង្អុល	នឹងកើតក្តីអំពល់ ។
ម្រាមកណ្តាល	នឹងទីពឹងដល់បងប្អូន ។
ម្រាមនាងដៃឆ្វេង	តទៅមុខនឹងមានប៉ះហេតុ ។
ម្រាមដៃស្តាំទាំង៥	នឹងមានបង់ខាតប្រាក់មាស ។
ជង្គង់ស្តាំ	នឹងបានលាភសក្ការៈ ។
ជង្គង់ឆ្វេង	មានការទាស់ទែងនឹងស្រី ។
ខ្នងជើងឆ្វេង	មានគេប៉ងអោយទោស ។
ខ្នងជើងស្តាំ	បានលាភជាទីស្រឡាញ់ ។
តូចស្តាំ	នឹងត្រូវទោស ។
តូចឆ្វេង	ត្រូវការទៅឆ្ងាយ ។
ដោះទាំងគូ	បានស្រីធ្វើជាមិត្រ នឹងបានជាធំ ។
ស្មាឆ្វេង	នឹងនិរាសដូចនាងសិតាក្រាសពីព្រះរាម។
ឆ្កាស្តាំ	នឹងបានទុក្ខយ៉ាងក្រដល់ខ្លួន ។

ជីតចរប្រចាំថ្ងៃ

(បទពាក្យ៧)

អាទិត្យឋិតនៅឰដ៏ក្បាល	ថ្ងៃចន្ទ វិសាលនៅចង្កា
អង្គារ ឋិតនៅនាថនា	ថ្ងៃពុធ សោភានៅដងខ្លួន ។
ព្រហស្បតិ៍ ឋិតនៅត្រង់ហត្ថា	សុក្រ ឋិតនៅនាលិនតាមក្បួន
សៅរ៍នៅត្រង់ជើងតាមសំនួន	កម្រៃតាមក្បួនហោរាសាស្ត្រ ។

តម្រាកាត់សក់

(បទកាកគតិ)

បើនឹងកាត់សក់ លោកអោយលែលក រកសួស្តីភាព
អាទិត្យមានជន្ម យឺនយូរសណ្តាប់ ចំន្ទបានបង្គ្រាប
ឬគាជាស្បើយ ។

អង្គារាសី ដាក់ទាបដល់ដី ជ័យជោគថោកទាប
ថ្ងៃពុធអប្បលក្សណ៍ ជតាដាក់ដោយ ព្រហស្បតិ៍អ្នកអើយ
ទេព្តារក្សា ។

សុក្រមានភ័ក្ត្រផង់ សៅរ៍មង្គលគង់ ប្រសើរសាភា
បើនឹងកាត់កោរ ត្រូវកាលវេលា សិរីសុខា
ដោយការកាត់សក់ ។

ម្រែងចន្ទ្រក្រចេះ ស្តដោយវិសេស ឃ្យៀបបម្រុងខ្លួន
អាទិត្យឃ្យៀបចំ ផ្សំដាក់សំនួន ចន្ទ្រមានភ័ក្ត្រភួង
ត្រូវចិត្តជនផង ។

អង្គារណោកហាម កុំស្តកុំផ្សំ ក្រែងកើតវិបត្តិ
ពុធមានសិរី សិរីសមសក្តិ បានសុខឥតអាក់
ព្រហស្បតិ៍មានជ័យ ។

ស្តសុគន្ធសោ សុក្រសុភោជន បរិបូណ៌ឆ្អែតឆ្អន់
សៅរ៍វិសុទ្ធោ ប្រសិទ្ធិជោគ វិសេសថ្លៃថ្នូ
ជយៈជយោសុខោលាភា។

តម្រាមើលថ្ងៃកាត់សក់ (បទពាក្យ៧)

កាត់សក់ថ្ងៃអាទិត្យសិទ្ធិជោគ ជាស្តោកអាយុយឺនធារធន់
ថ្ងៃចន្ទមានសេរីសោភ័ណ ជាធាតុអាសន្នរាល់យប់ថ្ងៃ ។
កាត់ថ្ងៃអង្គារវាសីជាក់ មានថ្នាក់ធ្លាក់បុណ្យអន់ចារមី
ថ្ងៃពុធអប្បលក្ខណ៍លាស់លុតភ័យ ព្រហស្បតិ៍ជាថ្ងៃទេពរក្សា ។
ថ្ងៃសុក្រសុវត្ថិវឌ្ឍន៍ ភ័ក្រធង់ដូចផាត់សុគន្ធា
ថ្ងៃសៅរ៍សួស្តីជយា បើសិនសៅហាប្រសើរក្រៃ ។
កាត់សក់ជាការពិសេសមួយ ព្រោះមានតម្រូវបុរាណនំយ
ចងចារជាតម្រាសេចក្តី គ្រាន់ជនប្រុសស្រីស្តាប់កាន់យក ។

តម្រាមើលថ្ងៃអ៊ុតសក់

ថ្ងៃអាទិត្យ អ៊ុតសក់ល្អ នឹងបានតេជៈតបៈវិទ្ធិ ។
ថ្ងៃចន្ទ អប្បរាជ័យមែនពិត មានគ្រោងគំនិតនាំអាប់យស ។
ថ្ងៃអង្គារ អ៊ុតចុះមានជោគជាក់ ទុក្ខសោកថ្នាំថ្នាក់នឹងស្បើយគ្រោះ ។
ថ្ងៃពុធ ចង្រៃមានកំហុស មានទាស់មន្ទិលវិលរំណាច ។
ថ្ងៃព្រហស្បតិ៍ ហូរលាភផលជាប់ ឡើងឋានៈសក្តិគាប់គួរគេស្ញើច ។
ថ្ងៃសុក្រ ប្រសើរចិត្តអង់អាច ជាស្តេហ៍ល្អជាច់ថ្ងៃទាំងឡាយ ។
ថ្ងៃសៅរ៍ កុំអ៊ុតកើតអាស្រូវ មានទោសទណ្ឌមានទៅជាប្រក្រតី ។
ចូរជ្រើសរើសយកសិរី មង្គលជោគជ័យជានិរន្តរ៍ ។

តម្រាមើលថ្ងៃកាត់ក្រចក

(បទពាក្យ៧)

បើកាត់ថ្ងៃអាទិត្យមានសួស្តី ថ្ងៃចន្ទសើរចានលាភឈ្មឹន
អង្គារសាបរិទ្ធិលែងរុងរឿង ថ្ងៃពុធផុតជើងជាមធ្យម ។
ព្រហស្បត្តិ៍ត្រូវទុក្ខចំណួនិន្នា ថ្ងៃសុក្រអាហារចានយ៉ាងចំ
ថ្ងៃសៅរ៍មានឈោកទ្រូងក្រៀមក្រំ មានគ្រោះនាយនាំអោយមានពិស ។

តម្រាកាត់ក្រចកមួយបែបទៀត

(បទភាកកតិ)

កាត់ក្រចកជង ឈោកគ្រាប់ទំនង រកពេលសើរ
អាទិត្យសុវត្ថិ ពិភទ្ធសិទ្ធិជ័យ សសិប្រពៃ
នឹងមានលាភលន់ ។
អង្គារពុំគាប់ នឹងសាបសូន្យទ្រព្យ បុរាណចានចែង
ចូរចាំអោយចប់ ចូរឈប់អោយក្រែង ថ្ងៃពុធនេះឯង
មានភ័យអផ្សុក ។
ព្រហស្បត្តិ៍ឈោកហាម នឹងមានទុក្ខតាម ត្រូវត្រង់មុខ
ឋិរភាគអាជន ឋិបូណ៌ថ្ងៃសុក្រ សៅរ៍មានភ័យទុក្ខ
ទោសជានិរន្តន៍ ។

៨ឆ្នើមរស់ប្រចាំថ្ងៃ

(បទរ៉ុំនោល)

អាទិត្យឋិតនៅឧត្តរ ថ្ងៃចន្ទបវរ ឋិតនៅនាទិសនិរតី ។
អង្គារ, ពុធ, លោកស្រដី ល្ងាសានទិសទី ព្រហស្សត្តិ៍នៅត្រង់ទិសឫបូ៌ ។
ថ្ងៃសុក្រ អាច្ចេយ៌ទិសា សៅរ៍ទក្ខិណា ត្រូវតាមតម្រាបុរាណ ។

៨ឆ្នើមស្លាប់ប្រចាំថ្ងៃ

(បទភុជង្គលីលា)

អាទិត្យឋិតនៅទក្ខិណា ថ្ងៃចន្ទសោភា នៅទិសល្ងាសាន ។
អង្គារ និងពុធស្មោះស្មាន ឋិតនៅត្រង់ឋាន នាទិសនិរតី ។
ព្រហស្សត្តិ៍ បុរាណស្រដី ឋិតនៅត្រង់ទី នាទិសបច្ឆឹម ។
ថ្ងៃសុក្រ ពាយ័ព្យទិសា ថ្ងៃសៅរ៍សោតណា នៅទិសឧត្តរ ។

ថ្ងៃអន្សាប្រចាំឆ្នាំកំណើត

(បទពាក្យ៧)

ថ្ងូត និងមមែ ទន្សាយអាទិត្យ រកឆ្កូវពីរពិតទន្សាចន្ទ ខាល និងរកា អង្គារស្បាន់ថោះ ចរ សោភ័ណពុធច្រាកដ ។ ឋាង កុរ ព្រហស្សត្តិ៍ ជាទន្សាយ ឆ្នាំម្សាញ់ នោះណាសុក្រកំណាត់ មមី ទន្សាយសៅរ៍ច្រាកដ តាមឈរឈ្មោះបទ ពីបុរាណ ។

ថ្ងៃលិច ~ ថ្ងៃអវ័ណ្ណត ~ ថ្ងៃកណ្ដាល

ខែ	ថ្ងៃអវ័ណ្ណត	ថ្ងៃលិច	ថ្ងៃកណ្ដាល
ចេត្រ	អង្គារ	ព្រហស្បត្តិ៍	អាទិត្យ
ពិសាខ	សុក្រ	អាទិត្យ	ពុធ
ជេស្ឋ	សៅរ៍	ចន្ទ	ព្រហស្បត្តិ៍
អាសាធ	អាទិត្យ	អង្គារ	សុក្រ
ស្រាពណ៍	ចន្ទ	ពុធ	សៅរ៍
ភទ្របទ	អង្គារ	ព្រហស្បត្តិ៍	អាទិត្យ
អស្សុជ	ពុធ	សុក្រ	ចន្ទ
កត្តិក	ព្រហស្បត្តិ៍	សៅរ៍	អង្គារ
មិគសិរ	សុក្រ	អាទិត្យ	ពុធ
បុស្ស	សៅរ៍	ចន្ទ	ព្រហស្បត្តិ៍
មាឃ	អាទិត្យ	អង្គារ	សុក្រ
ផល្គុន	ចន្ទ	ពុធ	សៅរ៍

ថ្ងៃអវ័ណ្ណត ធ្វើការមង្គល ឬពិធីបុណ្យជ័ងល្អ

ថ្ងៃលិច ហាមមិនអោយធ្វើការជាមង្គល ។

ថ្ងៃកណ្ដាល ត្រូវចេញដំណើរយាត្រាទៅផ្លូវទឹក ... ។

ជួលឈួលប្រើ

ថ្ងៃអាទិត្យ	នឹងបានកើតកើនចំណែនទ្រព្យ	។
ថ្ងៃចន្ទ	នឹងមានជំងឺកាត់ផ្សេងៗ	។
ថ្ងៃអង្គារ	នឹងកើតហេតុជាច្បាំងក្តីក្តាំ	។
ថ្ងៃពុធ	នឹងបានសម្បត្តិ	។
ថ្ងៃព្រហស្បត្តិ៍	នឹងបែកបញ្ជារកស៊ីធ្វើការ	។
ថ្ងៃសុក្រ	នឹងរត់ចោលការ	។
ថ្ងៃសៅរ៍	មានសួស្តីជ័យលាភ	។

ហានមិនអោយគប់

មក សម្បុរស សក់ញឹក	។
លាវ មាឧធំ មុខក្រពើរ	។
ចិន សម្បុរសខ្មៅ សំឡេងពីរ , ពោះជ្រោង	។
ស្បៃម មាឧតូច កផ្សែង	។

ពណ៌សំពត់ស្លៀកតម្រូវតាមថ្ងៃ

(បទពាក្យ៧)

អាទិត្យក្រហមខ្ចី ឬ ចាស់	ច័ន្ទផ្កាស់ឈ្មីងទុំ, ស្វាយអង្គារ
ថ្ងៃពុធស៊ីឈ្ងៀបសមសោភា	ព្រហស្បត្តិ៍ជាបៃតង ត្រួយចេកខ្ចី ។
ពណ៌ខៀវក្រឡៀវប្រើថ្ងៃសុក្រ	ពណ៌និលព្រឹលទុកសៅរ៍សីរី (ព្រឹងទុំ)
តែងខ្លួនតាមក្បួនលោកស្រដី	ចំណែនសិរីជ័យជោគអើយ ។

កំលាំងថ្ងៃ

អាទិត្យ	កំលាំង	៦	ស្លៀកពណ៌ក្រហម	។
ចន្ទ	-	១៥	- ឈឺង	។
អង្គារ	-	៨	- ស្វាយ	។
ពុធ	-	១៧	- ស៊ីឈៀប	។
ព្រហស្បតិ៍	-	១៩	- បៃតងខ្ចី	។
សុក្រ	-	២១	- ខៀវ	។
សៅរ៍	-	១០	- ខ្មៅ (ព្រឹងទុំ)	។

ជោគល្អ អាក្រក់ ស្លៀកសំពត់ថ្មី

(បទកាកគតិ)

បើស្លៀកពាក់ថ្មី អាទិត្យសម័យ មានជ័យតេជៈ
សត្រូវខ្ជះខ្ជាច អំណាចវិទ្ធិតបៈ
ឈ្នះមារឈង់ឃ្លង ។
សសីសេនហា មន្ត្រីរាជការ គាប់ចិត្តកន្លង
អង្គារនឹងបាន ទុក្ខទោសសៅហ្មង
ដល់អង្គអាត្មា ។
ព្រហស្បតិ៍ទោះស្លៀក ពាក់មានសុវត្ថិសំត្តិ សុក្របានទ្រព្យា
សៅរ៍តម្រាកាត់ ដាច់ខាតណាស់ណា ប្រយ័ត្នអង្គារ
ថាអាប់សិរី ។

អោយរបស់ផ្សេងៗទៅអ្នកដទៃ

(បទកាកគតិ)

បើអោយរបស់ជាទាន មានសុខសុវត្ថិ ឫរាណាបានចាត់
ទុកជាសំគាល់ អាទិត្យកុំអោយ សត្វរស់នៅឡើយ
ចំន្ទកុំថយទូក ចេញផុតពីផែ មានភ័យភ្ជាត់ក្តួត
អង្គារកុំឈរឈាត អោយវែកឡើយណា ។
ពុធកុំអោយបុណ្យ ក្នុងរបៈភូមិភាគ ព្រហស្បតិ៍កុំអោយទុន
ដើមធនទ្រព្យា សុក្រ សៅរ៍កុំពារ អោយមាសមិនល្អ ។

មើលសីរាសីទៅប្រចាំថ្ងៃ

ថ្ងៃអាទិត្យ រាសីនៅប្រចាំត្រង់ អណ្តាត ។
ថ្ងៃចន្ទ - ថ្ងាស ។
ថ្ងៃអង្គារ - ច្រមុះ ។
ថ្ងៃពុធ - មាត់ ។
ថ្ងៃព្រហស្បតិ៍ - ស្មា ។
ថ្ងៃសុក្រ - ខ្នង ។
ថ្ងៃសៅរ៍ - នៅដៃ ឫ ស្មងជើង ។

មើលរាសីប្រចាំកាយ

(បទកាកគតិ)

រាសីមនុស្ស តម្រាចារ្យរំាស ទុកជាតម្រាប់
តាមដោយរយៈថ្ងៃ លែជាលំដាប់ រាសីសំរាប់
គ្រប់រូបប្រុសស្រី ។

សុរិយៈអណ្តាត តាំងទុកជាអាទិ៍ ដើមរយៈថ្ងៃ
ចំន្ទនិងអង្គារ ពិតជាពិសី នៅច្រមុះនៃ
នរជនរាល់រូប ។

ពុធបហេរមាត់ តម្រាចែងចាត់ កាត់ដោយសួរសម
ព្រហស្បតិ៍នៅស្មា ថ្ងៃសុក្រណោកក្រាប់ ថានៅជិតជាប់
នឹងពោះនោះឯង ។

ថ្ងៃសៅរ៍រាសី នៅកំមេនៃ ពិតអួចថ្ពាល់ថ្លែង
គ្រប់រូបស្រីប្រុស មិនខុសឆ្គាផ្សេង ខុសតែនៅកន្លែង
តែងតាំងរាសី ។

គប្បីបដិបត្តិ ដើម្បីអោយមានសិរី

១- ព្រឹក សិរីនៅត្រង់មុខ អ្នកទាំងឡាយត្រូវលប់លាងមុខ ។

២- ថ្ងៃត្រង់ សិរីនៅត្រង់ដើមទ្រូង អ្នកទាំងឡាយយកក្រឿងក្រអូបលាបទ្រូង ។

៣- ព្រលប់ សិរីនៅត្រង់ជើង អ្នកទាំងឡាយយកទឹកលាងជើងដៃមុនចូលដេក ។

១- អោយបុរសទាំងឡាយ គប្បីជៀរចាកកាមគុណក្នុងថ្ងៃ ៧, ៨, ១៤, ១៥ ខែត-រនោច និងថ្ងៃសង្ក្រាន, សុរិយាគ្រាស, ចន្ទគ្រាស, ថ្ងៃកំណើត ។

២- អោយបុរសទាំងឡាយ អង្គុយបែរមុខទៅទិសបូព៌ា កាលនឹងបរិភោគភោជនាហារ

៣- អោយបុរសទាំងឡាយ អង្គុយបែរមុខទៅកាន់ទិសបស្ចឹម កាលនឹងបន្ថោរបង់ឧច្ចារៈ

៤- អោយបុរសទាំងឡាយ អោយស្រីដេកខាងឆ្វេងខ្លួន ហើយកុំអោយកន្តុងជើង ។

៥- អោយបុរសទាំងឡាយ ស្គាល់ការស្លៀកពាក់សំពត់ពេលថ្ងៃ ពេលយប់កុំស្លៀករួមជាមួយគ្នា ចំណាំជាយអោយជាក់ ។

មើលជួលចាវប្រើប្រាស់

(ពាក្យកាព្យ)

បើនឹងជួលចាវ ប្រុសស្រីសុទ្ធសាវ តាមសម្ដៅកស្មោះ
បុរាណពោលទុក ថាជារបស់ ល្មមអោយចិត្តអស់
អញនិងចាវព្រាវ ។

អាទិត្យល្អពេកក្រៃ ជួលមនុស្សប្រុសស្រី ប្រើប្រាស់ក្នុងក្រៅ
ចំបើនធនទ្រព្យ ស្រីម្ដាគាល់ហៅ ចំឆ្កែកុំសៅរៅ
លោះខ្ញុំកំរេរ ។

មានរោគាច្រើន ឈឺថ្កាត់ផ្តើនៗ រវល់តែឈឺ
មិនបានការអ្វី អង្គារច្រើនវេរ កើតច្បឹងតៗ
ច្បាំរហែមិនចាត់ ។

ពុធពិតចេញល្អ ទ្រព្យធនជន់ជោរ ដូចកាំរីជាតិ
ព្រហស្បតិ៍នឹងមាន វិទ្យាសិល្បសាស្ត្រ ប្រសើរស្អាងស្អាត
សុក្រជានាយយើង ។

ឆោរឆំឆោតសូន្យ ឧត្តមសិរី ប្រសើរអុងច្បឹង
តម្រាចាប្រចង អាចថោកថ្នុំថ្នើង ទើបបានលើកឡើង
ជាក្បួនតម្រា ។

តម្រាធ្វើស្រែ ~ ចំការ

សិទ្ធិការ្យ : របៀបធ្វើស្រែ ឬរាណាបានកែ តម្រាទុក ជាច្បាប់ត្រាប់ត្រៀន ប្រយោគ្គរយក តម្រាប់ត្រាប់រក របរការស្រែ ។ ព្រោះសាបស្នងស្រូវ ផ្សំតាមរដូវ នឹងខែ ខះខំឱ្យហាត សង្វាតមើលថែ ទើបបានផ្កាផ្លែ ពីស្រែស្រូវនោះ :

ថ្ងៃអាទិត្យ ឈោកថាបើភ្ជួរដីស្រែ បានផលល្អណាស់ ។

ថ្ងៃចន្ទ - ល្អតែដើម និងសន្ទឹក ។

ថ្ងៃអង្គារ - ស្រូវមានព្រលឹងល្អ ។

ថ្ងៃពុធ - បានស្រូវដាក់លានល្អ ។

ថ្ងៃព្រហស្បតិ៍ - យកស្រូវដាក់ជង្រុកល្អ ។

ថ្ងៃចន្ទ និងថ្ងៃសៅរ៍ កាត់ឈើធ្វើសសរ ស្រាប់ចោកបែនស្រូវល្អ ។

ថ្ងៃចន្ទ និងថ្ងៃពុធ ធ្វើដំហៀត រឺ ចោកបញ្ជាន់ស្រូវល្អ ។

កាលពេលាដែលឈោកថា គួរភ្ជួរស្រែបានលទ្ធផលបរិបូណ៌នោះ គឺចាប់ភ្ជួរជាដំបូង ដែ មានតែ៣ថ្ងៃទេគឺ : ថ្ងៃអាទិត្យ១, ថ្ងៃសុក្រ១, ថ្ងៃសៅរ៍១ លើកដំបូង ឈោកអោយធ្វើជម៩សន្ទឹក យកទៅដាក់បូជានាគ. ហើយវាសតាមកន្ទុយនាគ បាន៣ជុំ សុំដោះនឹម, ដោះហើយកុំយកនង្គ័លចេញពីកន្លែង ត្រូវផ្តែកទុកប្រមាណ១សន្ទុះ ធំ, បើធ្វើយ៉ាងនេះបាន នឹងបានលាភផលប្រសើរជាទីបំផុត ។

ថ្ងៃសុក្រ ធ្វើស្រែមានព្រលឹងស្រូវល្អ ។

ថ្ងៃសៅរ៍ អោយយកស្រូវថ្វាយទេព្តា៨ទិស ថ្វាយរួចកើបស្រូវទុក, មុននឹងកើបទុក ត្រូវបែងជាពុំទ្ធតា៣ រួចយកពំទ្ធតនោះទៅដាក់ក្នុងជង្រុក ។

ថ្ងៃចំន្ទ មុននឹងឃ្វៃបលានអោយបែរឈមមុខទៅរកទេព្តា យកដី១ដុំទៅដាក់កណ្តាលលាន បើកើបស្រូវដាក់ជង្រុក ពេញជាល្អ ។

ថ្ងៃអាទិត្យ កុំលក់ស្រូវ ក្រែងអប្រិយ៍ ទុយសងល់ខ្លួន ។

ថ្ងៃចំន្ទ កុំលក់សំពត់ នឹងមានជងឺឈឺធ្ងន់ ។

ថ្ងៃអង្គារ កុំលក់ដែក នឹងមានអន្តរាយដល់គ្រឹះស្ថាន ។

ថ្ងៃពុធ កុំរានស្រែ កុំឃ្វៃបចំសួនច្បារ នឹងកើតឧត្បាតដល់ខ្លួន ។

ថ្ងៃព្រហស្បតិ៍ កុំលក់គ្រឿងសរិទ្ធ និងថិល្លៃន ។

ថ្ងៃសុក្រ កុំលក់ដីស្រែ និងគ្រឿងមាស ។

ថ្ងៃសៅរ៍ កុំលក់សត្វជើង២ ជើង៤ ឡើយ ។

ផែនទីដាំដើមឈើប្រចាំទិស



= ទិសឫពាំ អោយដាំដើមសិរមាន់

= ទិសអគ្នេយ៍ អោយដាំដើមល្ពុត

= ទិសទក្សិណ អោយដាំដើមខ្នុរ

= ទិសនិរតី អោយដាំដើមស្វាយ

= ទិសបស្ចឹម អោយដាំដើមពុទ្រា

= ទិសពាយ័ព្យ អោយដាំដើមក្រូច

= ទិសល្ងសាន អោយដាំដើមអង្ករ

= ទិសឧត្តរ អោយដាំដើមអំពិល

ផែនទីដាំដើមឈើប្រចាំទិស



ថ្ងៃ១ ដាំត្រប់, ម្នេស, ជីរ, ស្លឹកត្រែ, ម្អម (ពេលល្ងាច) ។

ថ្ងៃ២ ដាំចេក, អំពៅ, ត្រាវ, ដំឡូង (ពេលល្ងាចល្អ) ។

ថ្ងៃ៣ ដាំត្រសក់, ឪឡឹក (ពេលសាយំណ្ណល្អ) ។

ថ្ងៃ៤ ដាំដើមផ្កាគ្រប់មុខ (ល្អស្អាត) ។

ថ្ងៃ៥ ដាំសណ្តែក, ស្រូវ, ហោត, ល្ង, សាលី ។

ថ្ងៃ៦ ដាំឈើរឹង, សន្តឹក, កូន ល្អសោភា ។

ថ្ងៃ៧ ដាំឈើទាំងពួង (ពេលព្រឹកយកសន្តឹក ពេលល្ងាចយកកូន ពេលរសៀលយកមែក) ។

គំនូសផែនទី

មើលស្លៀកសំពត់, អោយរបស់, ដាំដើមឈើ, រាសីប្រចាំកាយ, លោះចាវ, ទទួលប្រាក់មាស បំប្លួសនាគ ។

ថ្ងៃ	ស្លៀកសំពត់	អោយរបស់	ដាំដើមឈើ	រាសី	លោះចាវទទួលប្រាក់មាស បំប្លួសនាគ
១	មានជ័យ	កុំអោយសត្វ	យកប្លួស	អណ្តាត	មិនល្អ
២	រសនហោះ	កុំអោយទ្វក	យកមែក	មុខ	ល្អណាស់
៣	មានទុក្ខ	កុំអោយរំពក	យកស្លឹក	ច្រមុះ	ល្អណាស់
៤	សុវត្ថិ	កុំឱ្យបុណ្យ	យកផ្កា	មាត់	ល្អណាស់
៥	មានបញ្ហា	កុំអោយទុន	យកក្អូន	ស្មា	ស្មើខ្លួន
៦	បានប្រពន្ធ	កុំអោយខ្ញុំ	យកពួជ	ពោះ	ស្មើខ្លួន
៧	គេប្រទុស្ត	កុំអោយប្រាក់	យកស្លឹក	ត្រចៀក	ល្អណាស់

គំនូសដែនដី

មើលកាត់សក់, ស្ពប្រែង, កាត់ក្រចក, ដេរសំពត់, កណ្តុរកាត់សំពត់, សង់ផ្ទះ

ថ្ងៃ	កាត់សក់	ស្ពប្រែង	កាត់ក្រចក	ដេរសំពត់	កណ្តុរ កាត់សំពត់	ស្រះក្បាល	សង់ផ្ទះ
១	អាយុយឺន	ខូចសិរី	ល្អ	មិនល្អ	មានជ័យ	អាយុយឺន	មិនល្អ
២	មិនល្អ	ជាស្នេហ៍	មានលាភ	មិនល្អ	សុវត្ថិ	មិនល្អ	ប្រសើរ
៣	ប្រសើរ	និងថ្កាត់	មិនល្អ	មិនល្អ	មានទុក្ខ	ប្រសើរ	កុំសង់
៤	ល្អ	ចំរើន	ចំរើន	ចំរើន	កើតឡើង	មិនល្អ	ប្រសើរ
៥	ស្នេហ៍	មានជ័យ	មានទុក្ខ	មានជ័យ	ឈឺថ្កាត់	ល្អ	ល្អណាស់
៦	ល្អ	បានលាភ	បានលាភ	បានលាភ	បានលាភ	ស្នេហ៍	លើកសសរ
៧	ល្អ	ល្អ	មិនល្អ	មិនល្អ	ចាញ់អ្នកធំ	ល្អ	កុំសង់

តម្រាសង់គ្រឹះស្ថាន

សិទ្ធិការ្យ : បុព្វាចារ្យព្រេងនាយ លោកចងទុកថា : បើសង់ផ្ទះ, កុដិ, វិហារ, សាលា, មន្ទីរស្នាក់, មណ្ឌលវាំង, ឃាងគោ ក្របី ដំរី សេះ, ឃាងចាយ, ទឹក លោកអោយសង្កេតមើលតម្រានេះជាមុន ដើម្បីជីសរកសុវត្ថិមង្គល សេរីសួស្តី ត្រជាក់ត្រជុំដួចតទៅនេះ :

សង់ក្នុងខែ ៥ នឹងមានទុក្ខភ័យន្តរាយផ្សេងៗដល់ខ្លួន ។

- ៦ នៅជាសុខសប្បាយ មនុស្សជាតិដទៃយកលាភមកអោយ ។
- ៧ នឹងបង់ទ្រព្យរបស់ មានគ្រោះដល់រាងកាយ ។
- ៨ នឹងមានក្តៅចិត្ត សម្បត្តិបានមកទុកដាក់មិនគង់ឡើយ ។
- ៩ នឹងបានយសសក្តិ ទ្រព្យសម្បត្តិចំរើនយឺនយូរ ។
- ១០នឹងអន្តរាយសម្បត្តិទ្រព្យ មានឃាតឈឺថ្កាត់ឥតល្ហែ ។
- ១១ត្រូវប៉ះពារនឹងសេចក្តីទុក្ខលំបាក គេចោកបញ្ឆោត ។
- ១២នឹងមានមាសប្រាក់ ខ្ញុំកំរែ ស្រែភ្លឺ ។ល។
- ១ នឹងបានជាសេដ្ឋី បរិបូណ៌ដោយសេចក្តីសុខគ្រប់យ៉ាង ។
- ២ មានសត្រូវប៉ងនឹងប្រទូស្ត ប្លែតប្លែន ញាំាញី ។
- ៣ ភយន្តរាយ ព្រមទាំងសេចក្តីអាប់យសនឹងមានដល់ខ្លួន ។
- ៤ មានសេចក្តីសុខកាយសប្បាយចិត្ត ព្រមទាំងសេរីយស ។

តម្រាមើលថ្ងៃដែលនឹងសង់

សង់ក្នុងថ្ងៃ	អាទិត្យ	សង់ហើយច្រើនមានទុក្ខនៅក្នុងចិត្ត ឧត្បាតចង្រៃ កើតមានមិនសូវដាច់ ។
-	ចន្ទ	ធ្វើហើយគំរប់២ខែ នឹងមានលាភផ្សេងៗ ។
-	អង្គារ	ធ្វើហើយ៣ថ្ងៃ នឹងកើតជំងឺដង្កាត់ ពុំនោះភ្លើងឆេះផ្ទះ
-	ពុធ	សង់ហើយ នឹងបានលាភដ៏ជាទីពេញចិត្ត ពុំនោះសោតមានអ្នកធំជួយជ្រោមជ្រែង ។
-	ព្រហស្បតិ៍	ធ្វើហើយ៥ខែ នឹងមានលាភ បានសុខសម្រាន្តតទៅ
-	សុក្រ	ធ្វើហើយ២ខែ នឹងបានលាភបន្តិចបន្តួច សេចក្តីទុក្ខនិងសុខមានស្មើគ្នា ។
-	សៅរ៍	ធ្វើហើយ៤ខែ នឹងមានទុក្ខលំបាក នឹងមានកើតរោគបណ្តាលអោយឈាមហូរចេញពីខ្លួន ។

(តម្រានេះ មានពិស្តារក្នុងព្រហ្មជាតិភាគទី១)

តម្រាសង់ផ្ទះលើកជាពាក្យភាព្យ

(បទកាកគតិ)

ទោះនឹងសង់ផ្ទះ លោកអោយជម្រះ រកពេលាកាល
អាទិត្យសង់កាច ចិត្តមិនត្រកាល ចំន្ទសូស្តីរិសាល
អង្គារមានរាង ។
បើសង់ថ្ងៃពុធ ព្រហស្បតិ៍បរិសុទ្ធ ជាសុខដោយយ៉ាង
សុក្រសិទ្ធិជោគ សៅរ៍លោកកុំសាង កុំសង់ផ្ទុំរាង
ក្រែងមានទ្រេតទ្រោត។
តំរង់មិនត្រង់ ទោសខុសទំនង ប្រៀចវេរវិត
ម្យ៉ាងមានទោសទាស់ ហៅថាផ្ទះខ្មោច នឹងមានហិនហោច
ខូចខាតរបស់ ។
អ្នកយហៅផ្ទះមនុស្ស៍ មួយហៅផ្ទះសត្វ ចាត់ជាទាបខ្ពស់
តាមចិត្តជីសកុះ ចង់យកផ្ទះណា ។

(ចប់តម្រាសង់ផ្ទះ)

ពិធីរាប់អាយុ

សិទ្ធិការ : បុរាណចារ្យលោកបានបំព្រួញពិធីរាប់អាយុអោយបានខ្លីងាយរាប់ជាទីបំផុត ដល់អ្នកដែលត្រូវការចង់ដឹងថា តាំងពីកើតមកទល់នឹងឆ្នាំនេះ តើបានអាយុប៉ុន្មានឆ្នាំហើយ ? បើគេប្រាប់ឆ្នាំ យើងងាយនឹងរាប់ទេ (គឺរាប់តាមសេចក្តីពន្យល់ខាងក្រោម)។ បើគេមិនចាំឆ្នាំ ហើយគេអោយយើងរាងរកអាយុនិងឆ្នាំគេ នោះយើងត្រូវមើលដូច្នេះថា តើមនុស្សនោះមានសាច់ឈាមស្រចាលណា មានចំណាស់ប្រហែលជាប៉ុន្មានឆ្នាំហើយ គួររាប់បញ្ចូលទៅក្នុងវ័យណាសម បឋមវ័យ, មជ្ឈិមវ័យ រឺ បច្ឆិមវ័យ ។

ឧទាហរណ៍ មានមនុស្សម្នាក់កើតឆ្នាំរោង មានអាយុប្រហែលជា២០ជាយឆ្នាំ ប៉ុន្តែមិនដឹងថា២០ប៉ុន្មាន ? នោះលោកអោយរាប់ដូច្នេះ គឺរាប់តាំងពីរោងជាឆ្នាំកំណើតតទៅ : រោង (១), ម្សាញ់ (២), មមី (៣), មមែ (៤), វក (៥), រកា (៦), ច (៧), កុរ (៨) អោយគ្រប់៨ឆ្នាំ (៨ឆ្នាំនេះ លោកកំណត់ជា២០ឆ្នាំ) រួចលោកឱ្យរាប់ពីឆ្នាំកុរតទៅទៀត ទៅទល់ឆ្នាំនឹងឆ្នាំថ្មី សេសប៉ុន្មានឆ្នាំ លោកទុកឆ្នាំដែលសេសនោះជាប្លាយ គឺ២៥ឆ្នាំប្លាយ រឺថា២៦ឆ្នាំប្លាយ ថាតាមឆ្នាំដែលលើសនោះតរៀងទៅ ។

ឆ្នាំឯទៀតៗ ក៏មានវិធីដូចៗគ្នាដែរ ដូចមានពិធីរាប់តទៅនេះ :

រវាងអាយុ ១០ឆ្នាំ	លោកឱ្យរាប់ ១០	រវាងអាយុ ៦០ឆ្នាំ	លោកឱ្យរាប់ ១២
- ២០	- ៨	- ៧០	- ១០
- ៣០	- ៦	- ៧០	- ៨
- ៤០	- ៤	- ៨០	- ៦
- ៥០	- ២	- ៩០	- ៤

ឥន្ទាយតម្រាដែលមានលេខចាក់ផ្សេង
នៅក្របខាងក្រោយនេះ

១- នឹងកើតផលល្អ សមតាមប្រាថ្នា ។

២- នឹងបានទទួលសេចក្តីសុខ ប៉ុន្តែត្រូវបង់ទ្រព្យ ។

៣- បានកើតផលល្អរាល់ថ្ងៃ ហើយបានលាភ ។

៤- នឹងកើតវិវាទរវាងញាតិ (គ្រោះមិនល្អ) ។

៥- នឹងបានគ្នា ការងារនឹងចំរើនឡើង ។

៦- ជោគល្អ នឹងរួចចាកឃាតភ័យ បានទ្រព្យ ប៉ុន្តែយូរ ។

៧- របស់ដែលរបូតពីដៃ នឹងត្រឡប់បានមកវិញ មិនបាច់ខ្វាយខ្វល់ទេ ។

៨- គ្រោះអាក្រក់ ត្រូវតែលំបាក ។

៩- នឹងបានងារនឹងបានរង្វាន់ នឹងទទួលរួចសេចក្តី ជួយឈឺឆ្អាលពីអ្នកផង ។

១០- ខាតទុនច្រើនយ៉ាង ថាបើចេញដំណើរទៅណាមិនសំរេច ។

១១- នឹងសំរេចដូចសេចក្តីប្រាថ្នា ប៉ុន្តែយឺតយូរ ។

១២- របស់ដែលរបេះពីដៃទៅ នឹងបានមកវិញដោយសេចក្តីប្រឹងប្រែង ។

១៣- ចុះថយដៃក្នុងពេលនេះ មានភ័យពីសត្រូវ ។

១៤- អ្នកចំនឹងជួយឈឺឆ្អាល ។

១៥- កិច្ចធុរៈនឹងបានសំរេចសុភផល ការលក់ដូរនឹងបានចំរើន ។

១៦- មានឈឺថ្កាត់ នឹងមានសេចក្តីសុបសៅ នឹងបង្កើតជាទោសហេតុ ។

១៧- មិត្រនឹងជួយឈឺឆ្ពាល របស់ដែលចាក់ផុតពីដៃទៅត្រូវបាននឹញ ។

១៨- មិនសំរេច ផលការរបស់អ្នកនឹងខាតហើយ ។

១៩- បានសំរេចដូចសេចក្តីប្រាថ្នា នឹងបានបុត្រ ។

២០-ការចេញដំណើរទៅល្អ នឹងបានលាភពិធី ។

២១- ទៅនឹងធ្លាក់ទៅក្នុងដៃអ្នកដទៃ ។

២២-នឹងបានរួមក្សាន្តជាមួយនឹងបងអ្នក បានទទួលរបស់ជាសិទ្ធិនៃលោក ។

២៣-កិច្ចរៈដែលអន់ដៃ និងត្រូវរឿយហត់ ។

២៤- ត្រូវបង់ទ្រព្យ នឹងឈឺខ្លាង កើតម្យ៉ាងហេតុ ។

២៥- នឹងសំរេចដូចសេចក្តីប្រាថ្នា នឹងមានស្ត្រីជួយឈឺឆ្ពាល ។

២៦- កិច្ចមុខរៈដែលចាត់ការជាដំណើរយឺតយូរ ប៉ុន្តែបានជ័យជំនះទូវក្តី ។

២៧-ផ្តាយព្រះព្រះអនុកូល កិច្ចការកើតជាសម្រិទ្ធិ ។

២៨- ដើរផ្លូវឆ្ងាយនឹងបាននូវប្រយោជន៍ ។

២៩- នឹងកើតវិវាទព្រោះស្រីក្រមុំ នឹងបង់ទ្រព្យ ។

៣០-នឹងសាបសូន្យអាជីព កិច្ចការមិនជាផលសំរេច ។

៣១- ត្រូវបានបុត្រ កិច្ចការនឹងបានសំរេច ។

៣២-នឹងកើតឈ្លោះវិវាទ ឃ្លើសឃ្លងញាតិ ក្លាយទៅជាសត្រូវ ។

៣៣-កំពុងធ្លាក់ទៅក្នុងសេចក្តីលំបាកម្យ៉ាង តែគង់មានជ័យ ។

៣៤-នឹងសំរេចសមដូចសេចក្តីប្រាថ្នា ។

៣៥- នឹងរួចពីសេចក្តីលំបាក តែគង់បានទទួលសេចក្តីទុក្ខព្រោះតែស្រី ។

៣៦- នឹងកើតវិវាទខាងក្នុងមណ្ឌល ត្រូវផ្តាស់កន្លែង ។

៣៧- កំពុងលំចាកពីឯចម្ងៃតព្រោះរឿងមួយ តែគង់រួចពីទុក្ខ ។

៣៨- នឹងបានទទួលសេចក្តីសុខ ក្នុងផ្លូវចិញ្ចឹមជីព ប៉ុន្តែគង់មានជ័យ ។

៣៩- កុំរអាចិត្ត នឹងមានជ័យជាមិនខាន ។

៤០- នឹងកើតសេចក្តីទុក្ខពីឯជាប់ចិត្ត មានអន្តរាយពីសត្រូវ ។

៤១- នឹងបានបុត្រ ការងារនឹងកើតផល ។

៤២- នឹងបានសេចក្តីមេត្រី កិច្ចការនឹងបានសំរេច ។

៤៣- កើតភ័យចោរលួច ឈឺថ្កាត់នឹងខាតទុន ។

៤៤- នឹងបានលាភពីស្ត្រី ។

៤៥- ចុះដៃធ្វើបានកុំសង្ឃឹម តែគង់ខ្ចប្រាក់កាសខ្លះ ។

៤៦- នឹងកើតអន្តរាយព្រោះហ្មឺនភ័ក្តិ ។

៤៧- ទាល់តែយូរទៅទើបសំរេច ។

៤៨- ត្រូវតែជឿស្តាប់មនុស្សម្នាក់ៗ ។

៤៩- កិច្ចធុរៈនឹងដំណើរអែអង់ ពន្យាពេល ។

៥០- យូរៗនឹងបានសេចក្តីសុខ ។

៥១- នឹងកើតឈ្លោះទាស់គ្នា តែមិនជាអន្តរាយ ។

៥២- វត្ថុបំណងគង់បានសំរេច តែយូរ ។

៥៣- កិច្ចការមិនបានសំរេចផល ។

៥៤- ត្រូវលះទ្វេរភ្ញុំហ្មឺន ទើបបានរួចចាកទុក្ខ ។

៥៥- ធុរៈដែលចាត់ការចេញទៅ នឹងសំរេចផលប្រយោជន៍បាន ។

៥៦- ជើរឡើយអត់អំពើ ។

៥៧- នឹងបានស្ត្រី រីជានាយការចេញទៅចាត់ការនឹងបានសំរេចជាផល ។

៥៨- សេចក្តីទុក្ខរីតតែត្រួតច្រើនឡើង ។

៥៩- ការស្តាបនានឹងកើតផលសំរេច ។

៦០- ធុរៈដែលចាត់ហើយនឹងសំរេច តែយូរ ។

៦១- នឹងសំរេច បើធ្វើដំណើរនឹងបានផលប្រសើរ ។

៦២- នឹងខាតទុនបន្តិចបន្តួច ។

៦៣- មានភ័យពីអ្នកធំ នឹងមានទុក្ខមកដល់ខ្លួន ។

៦៤- នឹងបានលាភពីស្ត្រីម្នាក់ ។

៦៥- ចិត្តជាទុក្ខ ប៉ុន្តែបើទៅនឹងមានសេចក្តីសុខ ។

៦៦- សេចក្តីគិតទុកមុខជាមិនសំរេច នឹងត្រឡប់ទៅជាអាក្រក់ ។

៦៧- ឈោកតំពុងមានទុក្ខ តទៅមុខនឹងបានទទួលសេចក្តីសុខ ។

៦៨- កិច្ចការសំរេចផលតាមក្រាថ្នា នឹងមានលាភ ។

៦៩- វត្ថុដែលឃាតចេញទៅ នឹងត្រឡប់បានមកជាវិញ ។

៧០- បើឧស្សាហ៍ប្រើឱសថនឹងបានសុខយឺយ៉ា ។

៧១- ថាបើលះបង់ទ្រព្យវិញនឹងបាន ទើបបានសុខយ៉ាងទូលំទូលាយ ។

៧២- ទិញដីបានដោយស្រួល ។

៧៣- ខាតទុន បង់ទ្រព្យ រហែងរហោងនឹងញាតិបងប្អូន ។

៧៤- ប្រាក់មាសនឹងបាតបង់ខ្លះមិនខាន ។

៧៥- កើតមានរឿងក្តីក្តាំងនឹងបានឈ្នះគេ ។

៧៦- កុំគប្បីជំទាស់នឹងពាក្យណែនាំរបស់មិត្រ ។

៧៧- គប្បីលើកលែងធ្វើក្រុមហ៊ុនជាមួយគ្នា នឹងបានសុខ ។

៧៨- នឹងបណ្តាលជាឈ្លោះប្រកែកគ្នា តែជួនជាជោគល្អ ។

៧៩- ត្រូវធ្វើបង្ហើពិធីរំដោះគ្រោះ ទើបបានល្អឡើងវិញ ។

៨០- ឃើងដែលគិតហើយនោះ មិនជាផលសំរេចឡើយ ។

៨១- ឃើងដែលគិតទុកនឹងបានសំរេច ប៉ុន្តែទាល់តែបង់ទ្រព្យខ្លះ ។

៨២- មានរឿងខ្វល់ចិត្ត ។

៨៣- ការសាបព្រោះ នឹងចំរើនល្អឡើង ។

៨៤- វត្ថុដែលប្រាថ្នា នឹងវិលមកដល់ដៃ ។

៨៥- កើតរឿងរ៉ាវចាត់បង់ព្រោះឈ្លោកឯងជាហេតុ ។

៨៦- នឹងបានទ្រព្យ កិច្ចការបានលទ្ធផល ។

៨៧- នឹងបានទទួលសេចក្តីសុខ អស់ទៅនូវសេចក្តីក្រវាយក្រវល់ ។

៨៨- ផ្តាយព្រះគ្រោះជាបដិកូល ។

៨៩- នឹងខាតទុនបាត់បង់ច្រើនប្រការ ។

៩០- នឹងមានកេរ្តិ៍ឈ្មោះគាប់ប្រសើរ ។

៩១- កើតក្តីនឹងឈ្នះ ធាតនឹងជាសះស្បើយ ។

៩២- សេចក្តីត្រិះរិះនឹងសំរេច ប៉ុន្តែយឺតយូរ ។

៩៣- មានអ្នកដឹងទៃជួយឈឺឆ្អាល ។

៩៤- ប្បឹងរែលគិតទុក ជាការមិនសំរេច ។

៩៥- ការរែលត្រៀមទុកបានសំរេច ឧបាតនឹងស្ងប់ ។

៩៦- ការងារបានផលដ៏ប្រពៃ ។

៩៧- មានប្បឹងនាំអោយក្រវល់ក្រវាយចិត្តយ៉ាងក្រៃលែង ។

៩៨- អ្នករែលច្រាសគ្នា នឹងបានត្រឡប់មក នឹងបានសំរេចពេញបំណង ។

៩៩- នឹងកើតវិវាទគ្នា តែបែរជាល្អវិញ ។

១០០- សេចក្តីផ្សះផ្សងបានសំរេចដូចប្រាថ្នា ។

១០១- មិនគួរទុកចិត្តឡើយ ។

១០២- នឹងបានអស់ទៅនូវសេចក្តីព្រួយរំខាន ។

១០៣- មិនមានភ័យន្តរាយ ។

១០៤- របស់រែលជ្រុះធ្លុតពីរែ នឹងបានមកវិញ ។

១០៥- ត្រូវអាក្រក់ នឹងបានទទួលសោកក្តីទុក្ខច្រើន ។

១០៦- នឹងមានកូនចៅតរៀងរ្រកូល ។

១០៧- អ្នករែលមេត្រីនឹងគ្នា ក្លាយទៅជាសត្រូវនឹងគ្នាវិញ ។

១០៨- សេចក្តីត្រិះរិះ នឹងបានកំរែផលដ៏ថ្កើងថ្កាន ។

~ ចប់ ~

តម្រាសហទេពសាស្ត្រសំរាប់ចាក់ផ្សង

សិទ្ធិការ : បើលោក-អ្នកចង់ដឹងជោគជតា គ្រោះល្អ-អាក្រក់យ៉ាងណាៗ ឬ ចង់ជ្រាបនូវហេតុផលដូចម្តេចៗ ក្នុងឆ្នាំនេះ, ចូរតាំងចិត្តរងធិដ្ឋាន សម្រឹងរំពៃនឹកចំពោះព្រះរតនត្រ័យ ព្រមទាំងទេវតា និងវត្ថុសក្តិសិទ្ធ ហើយសច្ចាប្រណិធាន ដោយធ្មេចភ្នែក ចង្អុលចាក់ត្រង់ចន្លោះតារាងលេខ, បើចាក់ត្រូវចន្លោះលេខណា សូមឱ្យមើលខ្ជង់ទំនាយប្រចាំលេខនោះចុះ នៅទំព័រខាងក្នុងនឹងមានទំនាយ លេខជូនអស់លោក-អ្នកស្រាប់ ។



យើងខ្ញុំជាកូន ខ្ញៅ ឃុនសំរ៉ង ខ្ញៅ យ៉ាតណៃ ខ្ញៅសុខផល ខ្ញៅ វិសាល ខ្ញៅ វ៉ាមុន
ខ្ញៅ ភារាដា ខ្ញៅ ចំរើន ខ្ញៅ ភារី

បានឧបត្ថម្ភការផ្សាយសៀវភៅនេះជា eBook
ដើម្បីឧទ្ទិសកុសល់ដល់វិញ្ញាណក្ខន្ធ ឧបាសក ខ្ញៅ ពាញ និង ឧបាសិកា ឈរ យឿន

ការផ្សាយសៀវភៅនេះជា eBook បានបង្កើតឡើងដោយ

មូលនិធិខ្មែរសម្រាប់ការសិក្សា និង ករុណាខ្មែរ

ដើម្បីបម្រើប្រយោជន៍ជាសាធារណៈ ដោយមិនគិតកម្រៃ

ស្តេន ជា eBook ដោយ **ចាន់ នីតា**

សីហា ឆ្នាំ ២០១៥

បើលោក-លោកស្រីចង់បានសៀវភៅនេះ ឬអានបន្តទៅទៀត សូមទិញ ឬជាវពីអ្នកនិពន្ធ
ឬបណ្ណាគារដោយផ្ទាល់ដើម្បីគោរព "រក្សាសិទ្ធិ" របស់អ្នកនិពន្ធ។
យើងខ្ញុំ ពុំមានការព្រាស្រ័យទាក់ទង ដោយប្រភេទណាមួយជាមួយអ្នកនិពន្ធ ឬបណ្ណាគារទេ។

សូមអរគុណ

ខ្ញៅ ឃុនសំរ៉ង

ប្រធាន

មូលនិធិខ្មែរសម្រាប់ការសិក្សា

www.elibraryofcambodia.org